# មហាសតិបដ្ឋានសូត្រ

# Mahā Satipaṭṭhāna Sutta

វិជ្ជាស្ថានស្រាវជ្រាវវិបស្សនាអន្តរជាតិ
VIPASSANA RESEARCH INSTITUTE

វិធីវិបស្សនាកម្មដ្ឋាន

តាមប្រពៃណីរបស់លោកគ្រូ*សាយាគ្យីអ៊ូបាខិន*

បង្រៀនដោយលោកគ្រូ **ស្រីសត្យានារាយ័ន-ហ្គោអ៊េនកា**

លោកតា មហាមុនីវិសិទ្ធិ ទេពវង្ស

ភិក្ខុ អ៊ុំសុ-ឈាវ័

( ឧត្តមធម្មោ )

# មហាសតិបដ្ឋានសូត្រ

Mahā Satipaṭṭhāna Sutta

[illegible]:

[illegible]

[illegible]

[illegible]

In the tradition of Sayagyi U Ba Khin as taught by S.N.Goenka

អត្ថបទជាភាសាបាលីនិងអត្ថបទជាភាសាខ្មែរនេះ
បានបកប្រែមកពីអត្ថបទជាភាសាអង់គ្លេសសម្រាប់សិស្សប្រើក្នុង
ធម្មសិក្សាអំពីសតិបដ្ឋានសូត្របង្រៀនដោយ
លោក *ស. ន. ហ្គោអេនកា*

ការស្រាវជ្រាវមួយរបស់
*វិជ្ជាស្ថានស្រាវជ្រាវវិបស្សនា*

ទិដ្ឋិ ទិដ្ឋិ-សាទិដ្ឋិ

( [illegible] )

**វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច**
**អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា**
**អនុបាទាវិមុត្តោ ភិក្ខវេ តថាគតោ**

*ទីឃនិកាយ.១.៣៦.ព្រហ្មជាលសូត្រ*

ម្នាលភិក្ខុទាំងឡាយ, ដោយបានដឹងនូវការកើតឡើង
និងការរលត់បាត់ទៅវិញនៃវេទនាទាំងឡាយ តាមភាពពិតប្រាកដរបស់វា,
ដោយបានដឹងនូវការសប្បាយរីករាយជាមួយវេទនា,
នូវគ្រោះថ្នាក់របស់វេទនានិងការរួចផុតអំពីវេទនា,
តថាគតបានរួចរំដោះពេញបរិបូណ៌
ហើយបានរួចផុតអំពីការប្រកាន់ខ្ជាប់ទាំងអស់ ។

*(ទីឃនិកាយ,១.៣៦,ព្រហ្មជាលសូត្រ)*

# វិសយសូចី


| អត្ថបទ | ទំព័រ |
| --- | --- |
| ១.ឧទ្ទេសោ | 18 |
| ២.កាយានុបស្សនា | |
| ក.អានាបានបព្វំ | 20 |
| ខ.ឥរិយាបថបព្វំ | 24 |
| គ.សម្បជានបព្វំ | 26 |
| ឃ.បដិក្កូលមនសិការបព្វំ | 28 |
| ង.ធាតុមនសិការបព្វំ | 32 |
| ច.នវសិវថិកបព្វំ | 34 |
| ៣.វេទនានុបស្សនា | 52 |
| ៤.ចិត្តានុបស្សនា | 56 |
| ៥.ធម្មានុបស្សនា | |
| ក.នីវរណបព្វំ | 60 |
| ខ.ខន្ធបព្វំ | 68 |
| គ.អាយតនបព្វំ | 70 |
| ឃ.ពោជ្ឈង្គបព្វំ | 76 |
| ង.ចតុសច្ចបព្វំ | 84 |
| ង.១.ទុក្ខសច្ចំ | 86 |
| ង.២.សមុទយសច្ចំ | 96 |
| ង.៣.និរោធសច្ចំ | 108 |
| ង.៤.មគ្គសច្ចំ | 120 |
| ៦.សតិបដ្ឋានភាវនានិសំសោ | 128 |

# មាតិកាធម៌


| អត្ថបទ | ទំព័រ |
|---|---|
| វេទនាក្នុងការបដិបត្តិសតិប្បដ្ឋាន ........ | 8 |
| មហាសតិប្បដ្ឋានសូត្រអំពីការតាំងស៊ប់នៃសតិមឹង | |
| ១. សេចក្តីផ្តើម ........ | 19 |
| ២. ការពិនិត្យមើលកាយ | |
| ក. ផ្នែកស្តីអំពីដង្ហើម ........ | 21 |
| ខ. ផ្នែកស្តីអំពីឥរិយាបថនៃកាយ ........ | 25 |
| គ. ផ្នែកស្តីអំពីការយល់ច្បាស់ជាប់ជានិច្ចចំពោះសេចក្តីមិនទៀង... | 27 |
| ឃ. ផ្នែកស្តីអំពីការត្រិះរិះពិចារណាអំពីភាពខ្ពើមរអើមនៃកាយ .. | 29 |
| ង. ផ្នែកស្តីអំពីការត្រិះរិះពិចារណាអំពីរូបធាតុ ........ | 33 |
| ច. ផ្នែកស្តីអំពីការពិនិត្យមើលទីសូសាន៩យ៉ាង ........ | 35 |
| ៣. ការពិនិត្យមើលវេទនា ........ | 53 |
| ៤. ការពិនិត្យមើលចិត្ត ........ | 57 |
| ៥. ការពិនិត្យមើលធម៌ទាំងឡាយ | |
| ក. ផ្នែកស្តីអំពីធម៌រាំង ........ | 61 |
| ខ. ផ្នែកស្តីអំពីខន្ធ៥ ........ | 69 |
| គ. ផ្នែកស្តីអំពីអាយតនៈ ........ | 71 |
| ឃ. ផ្នែកស្តីអំពីអង្គ៧នៃការត្រាស់ដឹង ........ | 77 |
| ង. ផ្នែកស្តីអំពីអរិយសច្ច៤ ........ | 85 |
| .សេចក្តីពិតអំពីទុក្ខ ........ | 87 |
| .សេចក្តីពិតអំពីមូលហេតុរបស់ទុក្ខ ........ | 97 |
| .សេចក្តីពិតអំពីការរលត់ទុក្ខ ........ | 109 |
| .សេចក្តីពិតអំពីមាគ៌ា ........ | 121 |
| ៦. លទ្ធផលនៃការចំរើនសតិប្បដ្ឋាន ........ | 129 |
| .អត្ថាធិប្បាយពាក្យយោង ........ | 132 |

# ទេសនាក្នុងការប្រតិបត្តិសតិបដ្ឋាន
## (វិជ្ជាស្ថានស្រាវជ្រាវវិបស្សនា)

នៅក្នុងព្រះសូត្រជាច្រើន ព្រះពុទ្ធទ្រង់បានសរសើរអំពីការប្រតិបត្តិ សតិបដ្ឋាន ៤យ៉ាង គឺការតាំងស៊ប់នៃសតិមឹង ។ នៅក្នុងមហាសតិបដ្ឋានសូត្រ ព្រះអង្គបានសំដែង អំពីភាពសំខាន់របស់សតិបដ្ឋាន ដោយទ្រង់មានព្រះពុទ្ធដីកាហៅថា : « ឯកាយនោ មគ្គោ » គឺផ្លូវមួយតែមួយគត់ដើម្បីធ្វើសត្វឱ្យបរិសុទ្ធដើម្បីឱ្យបានរួចផុតពីសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្សដើម្បីឱ្យបានសម្រេចនូវមាគ៌ានៃ សេចក្តីពិត ហើយពិសោធឃើញព្រះនិព្វាន : ការរួចរដោះពីទុក្ខ (1) ។

នៅក្នុងព្រះសូត្រនេះ ព្រះពុទ្ធទ្រង់បានបង្ហាញវិធីប្រតិបត្តិមួយ ដើម្បីឱ្យស្គាល់ ខ្លួនឯងតាមរយៈ :

- កាយានុបស្សនា : ការពិនិត្យមើលកាយឱ្យបានជាប់ជានិច្ច
- វេទនានុបស្សនា : ការពិនិត្យមើលវេទនាឱ្យបានជាប់ជានិច្ច
- ចិត្តានុបស្សនា : ការពិនិត្យមើលចិត្តឱ្យបានជាប់ជានិច្ច
- ធម្មានុបស្សនា : ការពិនិត្យមើលធម៌ឱ្យបានជាប់ជានិច្ច(2)

ដើម្បីរករកឱ្យឃើញសេចក្តីពិតអំពីខ្លួនឯង យើងត្រូវពិនិត្យមើលថា : ទាំងកាយ ទាំងចិត្តតើយើងជាអ្វី ? យើងត្រូវរៀនពិនិត្យមើលវាដោយផ្ទាល់នៅក្នុងខ្លួនរបស់យើង។ ដោយហេតុនេះយើងត្រូវតែគិតជានិច្ចទៅលើចំណុចពីរយ៉ាង :

១.ការពិតអំពីកាយអាចប្រត្យក្ស(2a) បានដោយការសញ្ជឹងគិត, ប៉ុន្តែដើម្បីពិសោធឱ្យ ឃើញវាផ្ទាល់,គេត្រូវធ្វើការជាមួយវេទនា(2b) ដែលកើតមានឡើងនៅក្នុងក្របខ័ណ្ឌនៃកាយ។

២.ដូចគ្នានេះដែរ ការពិសោធន៍ឃើញចិត្តពិតប្រាកដអាចធ្វើទៅបានតែដោយសារ ការធ្វើការជាមួយអ្វីៗដែលកើតមានឡើងនៅក្នុងចិត្ត(2c) ។ ដូច្នេះតាមរបៀបដូចគ្នានេះ

---

(1) ទីឃនិកាយ II វិជ្ជាស្ថានស្រាវជ្រាវវិបស្សនា (VRI) ទំព័រ 373,PTS ទំព័រ 290 (2)L.O.C,C.I.T - VRI : Vipassana Reseach Institute; PTS : Pali Text Society .(2a) អានថាប្រមិតឬប្រមិត:តាំងនៅជាប់លាប់,(2b) គឺកាយវេទនាទាំងឡាយ (2c) គឺគំនិតអ្វីមួយ

ដែរ ដោយហេតុថាគេមិនអាចពិសោធឃើញកាយនិងវេទនាទាំងឡាយដាច់ដោយឡែកពីគ្នា បាននុ៎ះ គេក៏មិនអាចពិសោធឃើញចិត្តដាច់ដោយឡែកអំពីអ្វីៗដែលមាននៅក្នុងចិត្ត នោះបានដែរ ។

៣. ចិត្ត និង កាយ មានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធណាស់ រហូតទាល់តែអ្វីៗ ដែលកើតឡើងនៅក្នុងចិត្ត តែងតែបញ្ចេញខ្លួនវាមកជាវេទនានៅលើកាយ ។ ហេតុនេះ ហើយបានជាព្រះពុទ្ធបានត្រាស់ថា :

« វេទនាសមោសរណា សព្វេ ធម្មា (3) » អ្វីៗដែលកើតឡើងនៅក្នុងចិត្ត តែងមានដំណើរហូរទៅជាមួយវេទនា ។ ហេតុដូច្នេះ ការពិនិត្យមើលវេទនាជាមធ្យោបាយ ( ហើយក៏ជាមធ្យោបាយតែមួយគត់ ) ដើម្បីពិនិត្យមើលសភាវៈខ្លួនយើងទាំងមូល. ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត ។ ជាទូទៅព្រះពុទ្ធទ្រង់សំដែងអំពីវេទនា៥យ៉ាង :

១. សុខា វេទនា : វេទនាទាំងឡាយជាទីរីករាយផ្លូវកាយ
២. ទុក្ខា វេទនា : វេទនាទាំងឡាយជាទីមិនរីករាយផ្លូវកាយ
៣. សោមនស្ស វេទនា : វេទនាជាទីរីករាយផ្លូវចិត្ត
៤. ទោមនស្ស វេទនា : វេទនាជាទីមិនរីករាយផ្លូវចិត្ត
៥. អទុក្ខមសុខា វេទនា : វេទនាមិនមែនជាទីរីករាយ

ឬមិនជាទីមិនរីករាយទាំងឡាយតាមផ្លូវកាយឬតាមផ្លូវចិត្ត ។

ក្នុងការសំដែងទាំងអស់អំពីវេទនា នៅក្នុងសតិបដ្ឋានសូត្រ ព្រះពុទ្ធបានត្រាស់ថា : សុខាវេទនា, ទុក្ខាវេទនាចំពោះវេទនាផ្លូវកាយ, ឬអទុក្ខមសុខាវេទនាដែលតាមអត្ថបទនេះ សំដៅយកវេទនាអព្យាក្រឹត ខាងផ្លូវកាយដែរ ។

មានការសង្កត់យ៉ាងខ្លាំងទៅលើវេទនាផ្លូវកាយទាំងឡាយ ព្រោះវាដើរតួជាផ្លូវត្រង់ ឆ្ពោះទៅរកមគ្គផលគឺព្រះនិព្វានស្របទៅតាមច្បាប់ឧបនិស្ស័យ ឧបនិស្សយបច្ចយេន បច្ចយោ - គឺបច្ច័យយ៉ាងជិតបំផុតដើម្បីការរំដោះរបស់យើង ។

រឿងនេះ ត្រូវបានលើកយកមកពន្យល់ដោយសង្ខេបនៅក្នុង : បដ្ឋាន ដែលជា គម្ពីរទី៧នៃអភិធម្មបិដក ត្រង់វគ្គ បកតូបនិស្សយ ដែលថែងថា :

(3) អង្គុត្តរនិកាយ , ទសកនិបាត VRI II 58 - PTS ទំព័រ 5,107

កាយិកំ សុខំ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយបច្ចយេន បច្ចយោ ។

កាយិកំ ទុក្ខំ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយបច្ចយេន បច្ចយោ ។

ឧតុ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយបច្ចយេន បច្ចយោ ។

ភោជនំ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយបច្ចយេន បច្ចយោ ។

សេនាសនំ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយបច្ចយេន បច្ចយោ (4) ។

*តាមច្បាប់ឧបនិស្សយបច្ច័យ សេចក្ដីស្រណុកកាយ ទាក់ទងជាមួយវេទនាជាទីរីករាយរបស់កាយ, ជាមួយវេទនាជាទីមិនរីករាយរបស់កាយ ហើយនិងជាមួយការសម្រេចមគ្គផលគឺព្រះនិព្វាន ។*

*តាមច្បាប់ឧបនិស្សយបច្ច័យ សេចក្ដីលំបាកកាយទាក់ទងជាមួយវេទនាជាទីរីករាយរបស់កាយ, ជាមួយវេទនាជាទីមិនរីករាយរបស់កាយ ហើយនិងជាមួយការសម្រេចមគ្គផលគឺព្រះនិព្វាន ។*

*តាមច្បាប់ឧបនិស្សយបច្ច័យ រដូវឬបរិយាកាសជុំវិញ ទាក់ទងជាមួយវេទនាជាទីរីករាយរបស់កាយ, ជាមួយវេទនាជាទីមិនរីករាយរបស់កាយ ហើយនិងជាមួយការសម្រេចមគ្គផលគឺព្រះនិព្វាន ។*

*តាមច្បាប់ឧបនិស្ស័យបច្ច័យ ចំណីអាហារ ទាក់ទងជាមួយវេទនាជាទីរីករាយរបស់កាយ, ជាមួយវេទនាជាទីមិនរីករាយរបស់កាយ ហើយនិងជាមួយការសម្រេចមគ្គផលគឺព្រះនិព្វាន ។*

*តាមច្បាប់ឧបនិស្សយបច្ច័យ, ទីកន្លែងនិងគ្រឿងដេក-អង្គុយដូចជាគ្រែពូក,ខ្នើយ ឬឥរិយាបថដេកអង្គុយ ទាក់ទងជាមួយវេទនាជាទីរីករាយរបស់កាយ, ជាមួយវេទនា*

(4) បដ្ឋាន Vol.1 កុសលត្តិក .VRI. 324

ជាទីមិនរីករាយរបស់កាយ ហើយនិងជាមួយការសម្រេចមគ្គផលគឺព្រះនិព្វាន ។

ព្រះពុទ្ធដីកាខាងលើនេះ បង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីសារៈសំខាន់របស់វេទនានៅលើមាគ៌ានៃការរំដោះ ។ សេចក្តីស្រណុកនិងលំបាកកាយ.បរិយាកាសនៅជុំវិញ (ឧតុ).ចំណីអាហារដែលយើងបរិភោគ (ភោជនំ) និងឥរិយាបថដេក អង្គុយ ពួកឬឡើយ( សេនាសនំ) ជាហេតុដែលនាំឱ្យមានវេទនាផ្លូវកាយបែបណាមួយ ។ កាលណាគេពិសោធឃើញវេទនាដោយត្រឹមត្រូវ ដូចជាព្រះពុទ្ធទ្រង់បានពន្យល់នៅក្នុងមហាសតិបដ្ឋានសូត្រនេះ វេទនាទាំងនោះនឹងប្រែទៅជាបច្ច័យអាស្រ័យផ្ទាល់យ៉ាងជិតបំផុត ដើម្បីការរំដោះរបស់យើង ។

ធម្មជាតិរបស់យើងមានសភាវៈសំខាន់៤យ៉ាងគឺ កាយ. វេទនារបស់កាយ. ចិត្ត និងអ្វីៗដែលមាននៅក្នុងចិត្ត គឺ ធម៌ ។ សភាវៈទាំង៤យ៉ាងនេះ ផ្តល់នូវផ្លូវ៤ សម្រាប់ការតាំងសិប់នៃសតិដឹងក្នុងសតិបដ្ឋាន ។ ដើម្បីឱ្យការពិនិត្យមើល បានពេញបរិបូណ៌ យើងត្រូវតែពិសោធឱ្យឃើញគ្រប់សភាវៈទាំងអស់ ជាការដែលយើងអាចធ្វើបានតាមរយៈវេទនាតែប៉ុណ្ណោះ ។ ការរុករកឱ្យឃើញសេចក្តីពិតនេះ នឹងរំលើងចោលនូវការភាន់ច្រឡំដែលយើងមានអំពីខ្លួនយើងនេះ ។

តាមរបៀបដូចគ្នានេះដែរដើម្បីកំចាត់ការភាន់ច្រឡំអំពីលោកខាងក្រៅ យើងត្រូវរុករកឱ្យឃើញនូវរបៀបដែលលោកខាងក្រៅប្រាស្រ័យទាក់ទងជាមួយបាតុភូតនាមនិងរូបរបស់យើង ជាមួយខ្លួនយើងផ្ទាល់ ។ លោកខាងក្រៅចូលមកប្រាស្រ័យទាក់ទងជាមួយមនុស្សម្នាក់ៗបានតែតាមទ្វារវិញ្ញាណទាំង៦ប៉ុណ្ណោះគឺ : ភ្នែក.ត្រចៀក.ច្រមុះ.អណ្តាត.កាយនិងចិត្ត ។ ដោយហេតុថា ទ្វារវិញ្ញាណទាំង៦ស្ថិតនៅក្នុងកាយ ការប៉ះនឹងលោកខាងក្រៅទាំងអស់ត្រូវប្រព្រឹត្តឡើងនៅថ្នាក់កាយ ។

មុនសម័យព្រះពុទ្ធ.ក្នុងសម័យព្រះពុទ្ធនិងសម័យក្រោយតមកទៀត.គ្រូអប់រំចិត្តតាមប្រពៃណីនៅប្រទេសឥណ្ឌាបាននិយាយពន្យល់ថាតណ្ហាជាហេតុនាំឱ្យកើតទុក្ខ ហើយដើម្បីកំចាត់ទុក្ខ គេត្រូវវៀរចាកអារម្មណ៍ទាំងឡាយរបស់តណ្ហា ។

ជំនឿនេះ នាំឱ្យគេប្រព្រឹត្ត ទុក្ករកម្ម ផ្សេងៗហើយនិងតមយ៉ាងហួសហេតុនូវអ្វីៗដែលជាថ្នាំផាស់នៅខាងក្រៅ ។ ដើម្បីពង្រឹងការធ្វើចិត្តមិនឱ្យប្រកាន់ខ្ជាប់. ព្រះពុទ្ធ

ទ្រង់បានប្រើរបៀបមួយផ្សេង ។ ដោយទ្រង់បានចេះពិនិត្យមើលដល់ទីជម្រៅនៃចិត្តរបស់ព្រះអង្គ, ព្រះពុទ្ធទ្រង់បានឃើញថា នៅចន្លោះអារម្មណ៍នៅខាងក្រៅនិងការធ្វើប្រតិកម្មរបស់ចិត្តជាតណ្ហា មានចំណងក្រវិលមួយ គឺវេទនា ។ រាល់ពេលដែលយើងជួបប្រទះនឹងរបស់អ្វីមួយតាមទ្វារវិញ្ញាណទាំង៥ ឬ តាមផ្លូវចិត្ត, វេទនាមួយ ត្រូវតែកើតមានឡើង ហើយដោយមកអំពីវេទនានេះ,តណ្ហាក៏កើតមានឡើង ។ បើវេទនាជាទីរីករាយ យើងមានចិត្តចង់ឱ្យវាស្ថិតនៅតទៅទៀត ។ បើវេទនាជាទីមិនរីករាយ យើងមានចិត្តចង់តែបោះបង់វាចោល ។ នៅក្នុង បដិច្ចសមុប្បាទ (ធម៌ដែលកើតមានឡើងដោយសារបច្ច័យ) ព្រះពុទ្ធទ្រង់បានសម្តែងអំពីការរកឃើញយ៉ាងជ្រៅរបស់ព្រះអង្គថា :

សឡាយតនបច្ចយា ផស្សោ *អាយតនៈទាំង៦ជាបច្ច័យនាំឱ្យកើតសម្ផស្ស*

ផស្សបច្ចយា វេទនា *សម្ផស្ស ( ឬការប៉ះ ) ជាបច្ច័យនាំឱ្យកើតវេទនា*

វេទនាបច្ចយា តណ្ហា (5) *វេទនាជាបច្ច័យនាំឱ្យកើតតណ្ហា ។*

ដូច្នេះហេតុជាបន្ទាន់ដែលនាំឱ្យកើតតណ្ហា ហើយនិងជាយថាហេតុនាំឱ្យកើតទុក្ខ មិនមែនជារបស់នៅក្រៅខ្លួនយើងទេ គឺពិតជាវេទនាដែលកើតមានឡើងនៅក្នុងខ្លួនយើងហ្នឹងឯង ។

ដូច្នេះ ការយល់អំពីវេទនា ជាការចាំបាច់ដើម្បីឱ្យយល់អំពីការប្រាស្រ័យទាក់ទងគ្នារវាងចិត្តនិងកាយនៅក្នុងខ្លួនយើង, យ៉ាងណាមិញ ការយល់អំពីវេទនាដដែលនេះក៏ជាការចាំបាច់ដើម្បីឱ្យយល់អំពីការប្រាស្រ័យទាក់ទងគ្នារវាងលោកខាងក្រៅនឹងមនុស្សម្នាក់ៗនុះ ក៏យ៉ាងនោះដែរ ។

បើគេសាកល្បងរករឱ្យឃើញសេចក្តីពិតដោយការសញ្ជឹងគិត ឬដោយការត្រិះរិះតាមប្រាជ្ញាឈ្លាសវៃ,គេអាចភ្លេចតួនាទីសំខាន់របស់វេទនាបានដោយងាយ ។ ប៉ុន្តែចំណុចសំខាន់នៃការប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺចាំបាច់ត្រូវតែយល់សេចក្តីពិត ដែលមិនមែនគ្រាន់តែនៅថ្នាក់ប្រាជ្ញាឈ្លាសវៃទេ តែតាមការពិសោធន៍ផ្ទាល់ផងដែរ ។ អាស្រ័យហេតុនេះហើយបានជាគេឱ្យន័យវេទនាដូចតទៅនេះ :

យា វេទេតិ តិ វេទនា សា វេទយិត លក្ខណា អនុភវនរសា (6)...

អ្វីដែលស្គាល់ឃើញអារម្មណ៍ហៅថាវេទនា ។ ចរិតលក្ខណៈរបស់វាគឺទទួលអារម្មណ៍

(5) វិន័យ, មហាវគ្គ VRI. ទំព័រ 1,PTS ទំព័រ 2

វាជារសជាតិចាំបាច់សំខាន់នៃការពិសោធន៍ ។

ប៉ុន្តែការគ្រាន់តែស្គាល់ឃើញវេទនានៅក្នុងខ្លួនមិនគ្រប់គ្រាន់ដើម្បីកំចាត់បង់ការយល់ច្រឡំរបស់យើងបានទេ ។ ការចាំបាច់គឺត្រូវយល់អំពី ត្រៃលក្ខណ៍ ( ចរិតលក្ខណៈទាំងបីយ៉ាង) របស់បាតុភូតទាំងអស់ ។ យើងត្រូវពិសោធឱ្យឃើញផ្ទាល់នូវ : អនិច្ចំ ( សេចក្តីមិនទៀង) , ទុក្ខំ ( សេចក្តីទុក្ខ) , អនត្តា( ភាពមិនមែនខ្លួន) នៅក្នុងខ្លួនរបស់យើង ។ ក្នុងចំណោមលក្ខណៈទាំងបីនេះ, ព្រះពុទ្ធទ្រង់បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់ នៃសេចក្តីមិនទៀងគឺ អនិច្ចា ពីព្រោះកាលណាយើងពិសោធឃើញ ចរិតលក្ខណៈនៃសេចក្តីមិនទៀងនៅក្នុងទីជម្រៅ នោះការពិសោធន៍ឃើញចរិតលក្ខណៈពីរទៀតនឹងសម្រេចបានដោយងាយ ។ ក្នុង គម្ពីរឧទាន, មេឃិយសូត្រ, ព្រះពុទ្ធបានត្រាស់ថា :

**អនិច្ចសញ្ញិនោ ហិ មេឃិយ អនត្តសញ្ញា សណ្ឋាតិ**
**អនត្តសញ្ញី អស្មិមានសមុគ្ឃាតំ បាបុណាតិ ទិដ្ឋេវ ធម្មេ និព្វានំ** (7)

ម្នាលមេឃិយ ! បុគ្គលដែលបានដឹងអំពីសេចក្តីមិនទៀងមានការដឹងអំពីភាពមិនមែនខ្លួន តាំងស៊ប់នៅក្នុងខ្លួនរបស់គេ ។ បុគ្គលដែលដឹងអំពីភាពមិនមែនខ្លួន បានគាស់រំលើងឫសគល់នៃអស្មិមានះចេញអស់នៅក្នុងជាតិនេះហើយដោយហេតុនេះ គេត្រូវបានសម្រេចព្រះនិព្វាន ។

ដូច្នេះក្នុងការប្រតិបត្តិសតិប្បដ្ឋាន ការពិសោធន៍ឃើញអនិច្ចា គឺសេចក្តីមិនទៀងដែលកើតឡើងហើយរលត់បាត់ទៅវិញ, ដើរតួនាទីសំខាន់មួយ ។ ការពិសោធន៍ឃើញសេចក្តីមិនទៀងតាមភាពដែលវាបញ្ចេញខ្លួនឱ្យឃើញនៅក្នុងចិត្តនិងកាយនេះ គេហៅថា វិបស្សនា ។ ការប្រតិបត្តិវិបស្សនាគឺដូចគ្នានឹងការប្រតិបត្តិសតិប្បដ្ឋានដែរ ។

មហាសតិប្បដ្ឋានសូត្រចាប់ផ្តើមឡើងជាមួយការពិនិត្យមើលកាយ ។ ក្នុងនេះមានសេចក្តីពន្យល់អំពីចំណុចផ្សេងៗជាច្រើននៃការចាប់ផ្តើម : ការពិនិត្យមើលដង្ហើម, ការយកចិត្តទុកដាក់នឹងចលនាផ្សេងៗនៃកាយ ។ល។ គឺចាប់ផ្តើមពីចំណុចទាំងនេះហើយដែលយើងអាចប្រតិបត្តិវេទនានុបស្សនា, ចិត្តានុបស្សនា និង ធម្មានុបស្សនា ជាលំដាប់

---

(6) អភិធម្មត្ថសង្គហោ សេចក្តីបកប្រែជាភាសាហិណ្ឌូនិងអត្ថាធិប្បាយរបស់ភិក្ខុ បណ្ឌិត រេវត ធម្ម: វានសេយ សំស្ក្រឹត វិស្វ វិទ្យាល័យ វារណសី Vol.1,P.101 តាមការប្រើសព្ទ អនុគាមិនោ អ្នកធ្វើសេចក្តីអធិប្បាយបានបង្ហាញថា សារៈសំខាន់នៃការពិសោធន៍ដោយខ្លួនឯង ពីវេទនានៅលើរូបកាយ ។

(7) ឧទាន VRI. ទំព័រ 31,PTS ទំព័រ37

លំដោយ ។ ប៉ុន្តែទោះបីយើងចាប់ផ្តើមធ្វើដំណើរពីចំណុចណាមួយក៏ដោយ ក៏យើងត្រូវតែឆ្លងកាត់តាមចំណុចផ្សេងៗនៅលើផ្លូវរហូតទាល់តែដល់ទីដៅចុងបំផុត ។ ចំណុចទាំងនេះត្រូវបានរៀបរាប់ក្នុងប្រយោគសំខាន់ៗជាពាក្យដដែលៗមិនមែនគ្រាន់តែនៅចុងវគ្គនីមួយៗនៃផ្នែកកាយានុបស្សនានោះទេ តែនៅចុងវគ្គនៃផ្នែកវេទនានុបស្សនា, ចិត្តានុបស្សនា និងវគ្គនីមួយៗនៃផ្នែកធម្មានុបស្សនាផងដែរ ។ ចំណុចទាំងនោះគឺ :

១.សមុទយធម្មានុបស្សី វា វិហរតិ : គេតាំងនៅពិនិត្យមើលបាតុភូតនៃការកើត ។

២.វយធម្មានុបស្សី វា វិហរតិ : គេតាំងនៅពិនិត្យមើលបាតុភូតនៃការរលត់បាត់ទៅវិញ ។

៣.សមុទយវយធម្មានុបស្សី វា វិហរតិ : គេតាំងនៅពិនិត្យមើលបាតុភូតនៃការកើតនិងការរលត់បាត់ទៅវិញ (8) ។

ប្រយោគទាំងនេះបញ្ចេញឱ្យឃើញសារៈសំខាន់នៃការប្រតិបត្តិសតិបដ្ឋាន។ បើយើងមិនបានពិសោធឃើញសេចក្តីមិនទៀងទាំងពង្វាក់នេះទេយើងមិនអាចធ្វើឱ្យបញ្ញាញាណ_ភាពឧបេក្ខាដែលមានការពិសោធន៍សេចក្តីមិនទៀងជាមូលដ្ឋាន រីកចំរើនបានឡើយ ។ បញ្ញាញាណនាំយើងទៅរកការធ្វើចិត្តមិនឱ្យប្រកាន់ខ្ជាប់, នាំយើងទៅរកការរំដោះទុក្ខ ។ ហេតុដូច្នេះដើម្បីប្រតិបត្តិសតិបដ្ឋានណាមួយក្នុងចំណោមសតិបដ្ឋានទាំង៤នេះ យើងត្រូវតែខំពង្រីកការយល់យ៉ាងច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀងដែលពាក្យបាលីហៅថា សម្បជញ្ញៈ ។

ជាញឹកញយណាស់ គេមានការយល់ខុសចំពោះន័យរបស់ពាក្យ សម្បជញ្ញៈនេះ ។ តាមភាសាធម្មតាក្នុងសម័យនោះ សម្បជញ្ញៈ មានន័យថា ដោយចេតនា ។ ដូចយ៉ាងដូចជាព្រះពុទ្ធបានសំដែងអំពី : សម្បជានមុសា ភាសិតា (9) និង សម្បជានមុសាវាទ (10) ដែលមានន័យថា ពោលពាក្យកុហកដោយដឹងខ្លួន ដោយចេតនា ។ ក្នុងរឿងធម្មតា ន័យនេះរបស់ពាក្យនេះគ្រប់គ្រាន់ហើយ ។ ប៉ុន្តែកាលណាព្រះពុទ្ធបានសម្តែងអំពីវិបស្សនា,អំពីការប្រតិបត្តិដើម្បីធ្វើចិត្តឱ្យបរិសុទ្ធ ឱ្យបានសម្រេចព្រះនិព្វាន

(8) ទីឃនិកាយ II VRI. ទំព័រ 374-404,PTS ទំព័រ292-314

(9) ទីឃនិកាយ III VRI. ទំព័រ 62,PTS ទំព័រ45; អង្គុត្តរនិកាយ I តិកនិបាត VRI. ទំព័រ28,PTS ទំព័រ128

ដូចជានៅក្នុងសតិបដ្ឋានសូត្រនេះ, ចុះសម្បជញ្ញៈមានន័យបច្ចេកទេសមួយទៀតដោយឡែក។

ដើម្បីស្ថិតនៅជា សម្បជានោ ( គុណនាមរបស់ពាក្យសម្បជញ្ញៈ) គេត្រូវចំរើនកម្មដ្ឋានជាមួយ ការកើត និង ការរលត់បាត់ទៅវិញ នៃបាតុភូត( អនិច្ចលោក), ពិនិត្យមើលចិត្តនិងកាយដោយឥតលំអៀងដោយឥតប្រតិកម្ម ។ ការពិសោធន៍ឃើញ សមុទយវយធម្មា ( សេចក្តីមិនទៀង (11) ) មិនអាចសម្រេចបានដោយការសញ្ជឹងគិត ដែលគ្រាន់តែជាដំណើរប្រព្រឹត្តទៅមួយរបស់គំនិតឬដោយ ការប្រាជ្ញ ឬដោយជំនឿនុ៎ះទេ ។ គេត្រូវតែប្រព្រឹត្តធ្វើតាម បច្ចុតតោតិ(11a) ការពិសោធន៍ផ្ទាល់ដែលជា យថាភូតញ្ញាណទស្សន ( ការយល់សេចក្តីពិតតាមភាពពិតរបស់វាដោយការពិសោធន៍) (12) ។ នៅទីនេះការពិនិត្យមើលវេទនា ដើរតួនាទីសំខាន់បំផុត ព្រោះអ្នកចំរើនកម្មដ្ឋានពិសោធឃើញយ៉ាងច្បាស់ជាក់ស្តែងនូវ(សមុទយវយ) ការកើតនិងការរលត់បាត់ទៅវិញតាមរយៈវេទនា ។ តាមការពិតសម្បជញ្ញៈ ទទួលដឹងផ្ទាល់អំពីការកើតនិងការរលត់បាត់ទៅវិញ នៃវេទនាដែលនៅក្នុងនោះ មានរួមបញ្ចូលទិដ្ឋភាពទាំង៤នៃខ្លួនរបស់យើងផង ។

ដោយមកពីហេតុនេះហើយទើបគុណសម្បត្តិសំខាន់ទាំងពីរស្ថិតនៅជា អាតាបី (យ៉ាងសិប់,ខ្ជាប់ខ្ជួន),សម្បជានោ និង សតិមា (សតិដឹង) . បានត្រូវសំដែងដដែលៗ នៅគ្រប់សតិបដ្ឋានទាំង៤ ។ ដូចដែលព្រះពុទ្ធបានពន្យល់ស្រាប់ សម្បជញ្ញៈ គឺការពិនិត្យមើល ការកើតនិងការរលត់បាត់ទៅវិញនៃវេទនា (13) ។ ដូច្នេះក្នុងការប្រតិបត្តិសតិបដ្ឋាន គេមិនត្រូវបំភ្លេចតួនាទីសំខាន់របស់វេទនាឡើយ ។ ពុំនោះសោតការប្រតិបត្តិសតិបដ្ឋាននេះមិនបានគ្រប់គ្រាន់ទេ ។ ព្រះពុទ្ធបានត្រាស់ថា :

**តិស្សោ ឥមា, ភិក្ខវេ, វេទនា, កតមា តិស្សោ ? សុខា វេទនា, ទុក្ខា វេទនា, អទុក្ខមសុខា វេទនា ។ ឥមា ខោ, ភិក្ខវេ, តិស្សោ វេទនា, ឥមាសំ ខោ, ភិក្ខវេ តិស្សន្នំ វេទនានំ បរិញ្ញាយ ចត្តារោ សតិបដ្ឋានា ភាវេតព្វា** (14)។

---

(10) វិនយ បាចិត្តិយ VRI. ទំព័រ3,PTS ទំព័រ2,(11) គឺការកើតឡើងហើយរលត់បាត់ទៅវិញជាធម្មតា.
(11a) មជ្ឈិមនិកាយ I VRI. ទំព័រ 455, សំយុត្តនិកាយ មហាវគ្គសំយុត្ត VRI ទំព័រ512 823 FF 839FF
(12) អង្គុត្តរនិកាយ VRI. ទំព័រ 11, ឆក្កនិបាត 24,168, សត្តកនិបាត 65,VRI ទំព័រ111, អដ្ឋកនិបាត_81; PTS III ទំព័រ19,200 PTS IV ទំព័រ99,336 (13) សំយុត្តនិកាយVRI III. មហាវគ្គសំយុត្ត 401, PTS V ទំព័រ180

ម្នាលភិក្ខុទាំងឡាយ. វេទនាក្នុងកាយទាំងឡាយមាន៣យ៉ាង ។ តើវេទនាក្នុងកាយទាំង៣ នោះមានអ្វីខ្លះ ? វេទនាជាសុខ. វេទនាជាទុក្ខ. វេទនាមិនមែនទុក្ខមិនមែនសុខ ។ ម្នាលភិក្ខុទាំងឡាយ. ចូរប្រតិបត្តិសតិបដ្ឋានទាំង៤ ដើម្បីឱ្យបានយល់ទាំងស្រុងអំពីវេទនាទាំង៣ យ៉ាងនេះ ។

ការប្រតិបត្តិសតិបដ្ឋាន ដែលជាការប្រតិបត្តិវិបស្សនានឹងបានគ្រប់គ្រាន់ពេញបរិបូណ៌ទៅបាន លុះត្រាតែកាលណាគេពិសោធឃើញ សេចក្តីមិនទៀងដោយផ្ទាល់ ។ វេទនាផ្តល់នូវទីប្រជុំមួយដែលនាមនិងរូបត្រូវបញ្ចូលឱ្យឃើញថាជាបាតុភូតមិនទៀងមួយដែលនាំទៅរកការរំដោះទុក្ខ ។

(14)IBID, VRI III ទំព័រ415,PTS V ទំព័រ 180

កំណត់សំគាល់ : សេចក្តីយោងជាភាសាបាលី យកមកពីឆដ្ឋសង្គាយនា របស់ការបោះពុម្ពផ្សាយព្រះត្រៃបិដក ផ្សាយជាសាធារណៈដោយវិទ្យាស្ថានស្រាវជ្រាវវិបស្សនា VRI ។

# មហាសតិបដ្ឋានសូត្រ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមថ្វាយបង្គំដល់ព្រះដ៏មានព្រះភាគ
ព្រះអង្គជាព្រះអរហន្ត
ទ្រង់ត្រាស់ដឹងដោយពេញបរិបូណ៌
ដោយព្រះអង្គឯង ។

# ១-ឧទ្ទេសោ

ឯវំ មេ សុតំ ។

ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម កុរូនំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ, «ភិក្ខវោ» តិ (1) ។ «ភទន្តេ» តិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច :

ឯកាយនោ អយំ, ភិក្ខវេ, មគ្គោ សត្តានំ វិសុទ្ធិយា, សោកបរិទេវានំ សមតិក្កមាយ, ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ, យទិទំ ចត្តារោ សតិបដ្ឋានា (2) ។

កតមេ ចត្តារោ ? ឥធ, ភិក្ខវេ, ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ (3) សតិមា, វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា, វិនេយ្យ លោកេ អភិជ្ឈា ទោមនស្សំ ។ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា, វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា, វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ (4) ។

# ១.សេចក្ដីផ្ដើម

ខ្ញុំបានស្ដាប់មកហើយថាយ៉ាងនេះ :

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅជាមួយជនជាតិ កុរុ នៅ កម្មាសធម្ម ជាទីផ្សាររបស់ជនជាតិកុរុ ។ នៅទីនោះព្រះដ៏មានព្រះភាគបានត្រាស់ហៅភិក្ខុទាំងឡាយ ថា : «ម្នាលភិក្ខុ(1)ទាំងឡាយ» ហើយភិក្ខុទាំងឡាយក៏បានឆ្លើយតបថា : «បពិត្រព្រះអង្គដ៏ចំរើន» ។ រួចហើយ ព្រះដ៏មានព្រះភាគទ្រង់បានត្រាស់ដូចតទៅ :

.នេះគឺជាផ្លូវតែមួយគត់ ដើម្បីធ្វើសត្វឱ្យបរិសុទ្ធ,ដើម្បីឱ្យបានរួចផុតអំពីសេចក្ដីសោក(1a)និងសេចក្ដីខ្សឹកខ្សួល,ដើម្បីរលត់នូវទុក្ខ(1b)និងទោមនស្ស(1c)ដើម្បីឱ្យបានសម្រេចផ្លូវនៃសេចក្ដីពិត,ដើម្បីឱ្យបានពិសោធឃើញព្រះនិព្វាន ។ផ្លូវនេះគឺសតិបដ្ឋាន៤យ៉ាង (2)។

តើសតិបដ្ឋាន៤យ៉ាងនោះមានអ្វីខ្លះ ? ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះភិក្ខុតាំងនៅយ៉ាងខ្ជាប់ខ្ជួនប្រកបដោយសតិដឹងត្រូវនិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្ដីមិនទៀង(3)ពិនិត្យមើលកាយក្នុងកាយដោយបានកំចាត់បង់នូវលោភៈនិងទោសៈក្នុងលោក(3a)នេះ, ភិក្ខុតាំងនៅយ៉ាងខ្ជាប់ខ្ជួនប្រកបដោយសតិដឹងត្រូវ និងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្ដីមិនទៀង,ពិនិត្យមើលវេទនាក្នុងវេទនាទាំងឡាយ ដោយបានកំចាត់បង់នូវលោភៈនិងទោសៈក្នុងលោក(3a)នេះ, ភិក្ខុតាំងនៅយ៉ាងខ្ជាប់ខ្ជួនប្រកបដោយសតិដឹងត្រូវនិងការយល់ច្បាស់ជាប់ជានិច្ច អំពីសេចក្ដីមិនទៀង ពិនិត្យមើល ចិត្តក្នុងចិត្ត ដោយបានកំចាត់បង់នូវលោភៈនិងទោសៈក្នុងលោក(3a)នេះ, ភិក្ខុតាំងនៅយ៉ាងខ្ជាប់ខ្ជួនប្រកបដោយសតិដឹងត្រូវនិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្ដីមិនទៀង,ពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ ដោយបានកំចាត់បង់នូវលោភៈនិងទោសៈក្នុងលោក(3a)នេះ (4)។

## ២-កាយានុបស្សនា
### ២-ក-អានាបានបព្វ

កថញ្ច បន, ភិក្ខវេ, ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ?

ឥធ, ភិក្ខវេ, ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា, ឧជុំ កាយំ បណិធាយ, បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ, សតោ វ បស្សសតិ ។ ទីឃំ វា អស្សសន្តោ «ទីឃំ អស្សសាមី» តិ បជានាតិ,(5) ទីឃំ វា បស្សសន្តោ «ទីឃំ បស្សសាមី» តិ បជានាតិ ។ រស្សំ វា អស្សសន្តោ «រស្សំ អស្សសាមី» តិ បជានាតិ រស្សំ វា បស្សសន្តោ «រស្សំ បស្សសាមី» តិ បជានាតិ ។ «សព្វកាយបដិសំវេទី អស្សសិស្សាមី» តិ សិក្ខតិ, «សព្វកាយបដិសំវេទី បស្សសិស្សាមី» តិ សិក្ខតិ ។ «បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមី» តិ សិក្ខតិ, «បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមី» តិ សិក្ខតិ ។

សេយ្យថាបិ ភិក្ខវេ ទក្ខោ ភមការោ វា ភមការន្តេវាសី វា ទីឃំ វា អញ្ឆន្តោ «ទីឃំ អញ្ឆាមី» តិ បជានាតិ, រស្សំ វា អញ្ឆន្តោ «រស្សំ អញ្ឆាមី» តិ បជានាតិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ទីឃំ វា អស្សសន្តោ «ទីឃំ អស្សសាមី» តិ បជានាតិ, ទីឃំ វា បស្សសន្តោ «ទីឃំ បស្សសាមី» តិ បជានាតិ, រស្សំ វា អស្សសន្តោ «រស្សំ អស្សសាមី» តិ បជានាតិ, រស្សំ វា បស្សសន្តោ «រស្សំ បស្សសាមី» តិ បជានាតិ ។ «សព្វកាយបដិសំវេទី អស្សសិស្សាមី» តិ សិក្ខតិ, «សព្វកាយបដិសំវេទី បស្សសិស្សាមី» តិ សិក្ខតិ, «បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមី» តិ សិក្ខតិ, «បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមី» តិ សិក្ខតិ ។

# ២_ការពិនិត្យមើលកាយ
## ២_ក_ផ្នែកស្តីអំពីដង្ហើម

ម្នាលភិក្ខុទាំងឡាយ,ចុះភិក្ខុតាំងនៅពិនិត្យមើលកាយក្នុងកាយនោះ តើយ៉ាងដូចម្តេច ?

ក្នុងទីនេះភិក្ខុបានទៅកាន់ទីព្រៃក្តី,ទៅកាន់គល់ឈើក្តី,ទៅកាន់ផ្ទះទំនេរស្ងាត់ក្តី, អង្គុយពែនភ្នែន,តាំងខ្លួនឱ្យត្រង់ហើយផ្ចង់សតិទៅត្រង់ផ្ទៃក្រោមរន្ធច្រមុះលើបបូរមាត់លើ ។ ដោយមានសតិដឹងតាមរបៀបនេះភិក្ខុដកដង្ហើមចូល ដោយមានសតិដឹងតាមរបៀបនេះភិក្ខុដកដង្ហើមចេញ ។ កាលដកដង្ហើមចូលវែង,ភិក្ខុដឹងច្បាស់(5)ថា «អាត្មាអញកំពុងដកដង្ហើមចូលវែង», កាលដកដង្ហើមចេញវែង,ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចេញវែង» ។ កាលដកដង្ហើមចូលខ្លី,ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចូលខ្លី»,កាលដកដង្ហើមចេញខ្លី ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចេញខ្លី», ភិក្ខុទំហាត់ហ្វឹកហ្វឺនខ្លួនឯងតាមរបៀបនេះគឺ : «ដោយដឹងកាយទាំងមូលក្នុងមួយដង្ហើម,អាត្មាអញដកដង្ហើមចូល »,«ដោយដឹងកាយទាំងមូលក្នុងមួយដង្ហើម, អាត្មាអញដកដង្ហើមចេញ»។ ភិក្ខុទំហាត់ហ្វឹកហ្វឺនខ្លួនឯងតាមរបៀបនេះគឺ : «ដោយចលនាកាយមានភាពស្ងប់, អាត្មាអញដកដង្ហើមចូល,«ដោយចលនាកាយមានភាពស្ងប់, អាត្មាអញដកដង្ហើមចេញ»។ ភិក្ខុទំហាត់ហ្វឹកហ្វឺនខ្លួនតាមរបៀបនេះឯង ។

គឺដូចជាជាងក្រឡឹងឬសិស្សជាងក្រឡឹងដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែងក៏ដឹងយ៉ាងច្បាស់ថា «អាត្មាអញកំពុងទាញខ្សែក្រឡឹងវែង», កាលទាញខ្សែក្រឡឹងខ្លីក៏ដឹងយ៉ាងច្បាស់ថា «អាត្មាអញកំពុងទាញខ្សែក្រឡឹងខ្លី» ។ យ៉ាងណាមិញកាលដកដង្ហើមចូលវែង,ភិក្ខុដឹងយ៉ាងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចូលវែង», កាលដកដង្ហើមចេញវែងភិក្ខុដឹងយ៉ាងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចេញវែង», កាលដកដង្ហើមចូលខ្លីភិក្ខុដឹងយ៉ាងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចូលខ្លី», កាលដកដង្ហើមចេញខ្លីភិក្ខុដឹងយ៉ាងច្បាស់ថា «អាត្មាអញកំពុងដកដង្ហើមចេញខ្លី» ក៏យ៉ាងនោះដែរ។ ភិក្ខុទំហាត់ហ្វឹកហ្វឺនខ្លួនឯងតាមរបៀបនេះគឺ «ដោយដឹងកាយទាំងមូលក្នុងមួយដង្ហើម អាត្មាអញដកដង្ហើមចូល», «ដោយដឹងកាយទាំងមូលក្នុងមួយដង្ហើម អាត្មាអញដកដង្ហើមចេញ» ។ ភិក្ខុទំហាត់ហ្វឹកហ្វឺនខ្លួនឯងតាមរបៀបនេះគឺ «ដោយចលនាកាយមានភាពស្ងប់ អាត្មាអញដកដង្ហើមចូល » «ដោយចលនាកាយមានភាពស្ងប់ អាត្មាអញដកដង្ហើមចេញ »។

ឥតិ(6)អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា (7) វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ (8) វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ (9) អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

តាមរបៀបនេះ(៦) : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង(7)។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ(៨)» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ(៩)។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅពិនិត្យមើលកាយក្នុងកាយ ។

## ២-ខ-ឥរិយាបថបព្វំ

បុន ច បរំ, ភិក្ខវេ, ភិក្ខុ គច្ឆន្តោ វា «គច្ឆាមី»តិ បជានាតិ, ឋិតោ វា «ឋិតោម្ហី»តិ បជានាតិ, និសិន្នោ វា «និសិន្នោម្ហី»តិ បជានាតិ សយានោ វា «សយានោម្ហី»តិ បជានាតិ ។ យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ, តថា តថា នំ បជានាតិ *(10)* ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ»តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

## ២.១.ផ្នែកស្តីអំពីឥរិយាបថនៃកាយ

ម្នាលភិក្ខុទាំងឡាយ, គទៅទៀតនេះ កាលភិក្ខុដើរក្តីក៏ដឹងច្បាស់ថា «អាត្មាអញកំពុងដើរ» ។ កាលឈរក្តីក៏ដឹងច្បាស់ថា «អាត្មាអញកំពុងឈរ»។ កាលអង្គុយក្តីក៏ដឹងច្បាស់ថា «អាត្មាអញកំពុងអង្គុយ»។ កាលដេកក្តីក៏ដឹងច្បាស់ថា «អាត្មាអញកំពុងដេក»។ ទោះបីតាំងខ្លួននៅក្នុងឥរិយាបថណាទីមួយក៏ដោយ, ភិក្ខុដឹងច្បាស់នូវឥរិយាបថនោះៗ (10)។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលជាមួយគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ»បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុនាំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

# ២-គ-សម្បជានបព្វំ

បុន ច បរំ, ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ, អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ, (11) សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ, សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ, អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ, ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ, គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

## ២.គ. ផ្នែកស្ដីអំពីការយល់ច្បាស់ជាប់ជានិច្ចចំពោះសេចក្ដីមិនទៀង

ម្នាលភិក្ខុទាំងឡាយ, តទៅនេះទៀត កាលដើរទៅមុខឬថយក្រោយភិក្ខុដឹងច្បាស់នូវកិរិយានេះ ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង (11)។ កាលក្រឡេកមើលត្រង់ទៅមុខឬក្រឡេកមើលទិសសងខាង ភិក្ខុដឹងច្បាស់នូវកិរិយានេះ ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង ។ កាលបត់ឬលាដៃជើង ភិក្ខុដឹងច្បាស់នូវកិរិយានេះ ដោយមានសេចក្ដីដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង ។ កាលគ្រងចីវរនិងសង្ឃាដី ឬកាន់បាត្រក្ដីភិក្ខុដឹងច្បាស់នូវកិរិយានេះ ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង ។ កាលបរិភោគអាហារ,ផឹកទឹក,ទំពារឬលេបរសជាតិអាហារក្ដី ភិក្ខុដឹងច្បាស់នូវកិរិយានេះដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង ។ កាលបន្ទោរបង់នូវឧច្ចារៈឬបស្សាវៈគឺបត់ជើងធំឬបត់ជើងតូច ភិក្ខុដឹងច្បាស់នូវកិរិយានេះ ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង ។ កាលដើរ,ឈរ អង្គុយ,ដេកឬភ្ញាក់ដឹងខ្លួន កាលនិយាយស្ដីឬនៅស្ងៀម ភិក្ខុដឹងច្បាស់នូវកិរិយានេះ ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្ដីមិនទៀងផង ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលជាមួយគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខិតប្រឹងសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ។

# ២-ឃ-បដិក្កូលមនសិការបព្វំ

បុន ច បរំ, ភិក្ខវេ, ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា, តចបរិយន្តំ បូរំ នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ៖ «អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារុ អដ្ឋិ អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ» តិ ។

សេយ្យថាបិ ភិក្ខវេ ឧភតោមុខា បុតោឡិ បូរា នានាវិហិតស្ស ធញ្ញស្ស សេយ្យថីទំ សាលីនំ វីហីនំ មុគ្គានំ មាសានំ តិលានំ តណ្ឌុលានំ។ តមេនំ ចក្ខុមា បុរិសោ មុញ្ចិត្វា បច្ចវេក្ខេយ្យ «ឥមេ សាលី ឥមេ វីហី ឥមេ មុគ្គា ឥមេ មាសា ឥមេ តិលា ឥមេ តណ្ឌុលា» តិ ។

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរំ នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ«អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារុ អដ្ឋិ អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សង្ឃាណិកា លសិកា មុត្តំ» តិ ។

# ២.ឃ.ផ្នែកស្ដីអំពីការត្រិះរិះពិចារណា អំពីភាពខ្ពើមរអើមក្នុងកាយ

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ ភិក្ខុត្រិះរិះពិចារណាឃើញច្បាស់អំពីកាយនេះដែលមានស្បែកបិទបាំងប្រកបដោយគ្រឿងមិនស្អាតគ្រប់បែបយ៉ាងតាំងពីបាតជើងឡើងទៅលើ និងតាំងពីចុងសក់ចុះមកក្រោមដោយពិនិត្យពិចារណាយ៉ាងនេះថា : «នៅក្នុងកាយនេះមាន សក់.រោម.ក្រចក.ធ្មេញ.ស្បែក.សាច់.សរសៃ.ឆ្អឹង.ខួរក្នុងឆ្អឹង តម្រងនោម.បេះដូង.ថ្លើម.វាវ.ក្រពះ.សួត.ពោះវៀនធំ.ពោះវៀនតូច.អាហារថ្មី.អាហារចាស់. ប្រមាត់.ស្លេស្ម.ខ្ទុះ.ឈាម.ញើស.ខ្លាញ់ខាប់.ទឹកភ្នែក.ខ្លាញ់រាវ.ទឹកមាត់.ទឹកសម្បោរ.ទឹករំអិល.ទឹកមូត្រ» ។

គឺដូចជាថង់មួយដែលមានមាត់ទាំងសងខាងពេញទៅដោយធញ្ញជាតិផ្សេងៗ ដូចជាស្រូវសាលី.ស្រូវខ្សាយ.សណ្ដែកបាយ.សណ្ដែករាជមាស.ល្ង.អង្ករ ហើយមានមនុស្សម្នាក់ភ្នែកភ្លឺបានបើកមាត់ថង់នេះពិនិត្យមើលរបស់នៅក្នុងថង់នោះ ដោយពោលថា : នេះជាស្រូវសាលី.នេះជាស្រូវខ្សាយ.នេះជាសណ្ដែកបាយ.នេះជាសណ្ដែករាជមាស.នេះជាល្ង. នេះជាអង្ករ ។

តាមរបៀបដូចគ្នានេះដែរ ម្នាលភិក្ខុទាំងឡាយ.ភិក្ខុត្រិះរិះពិចារណាឃើញច្បាស់អំពីកាយនេះដែលមានស្បែកបិទបាំងប្រកបដោយគ្រឿងមិនស្អាតគ្រប់បែបយ៉ាង តាំងពីបាតជើងឡើងទៅលើនិងតាំងពីចុងសក់ចុះមកក្រោមដោយពិនិត្យពិចារណាយ៉ាងនេះថា: «នៅក្នុងកាយនេះមាន សក់.រោម.ក្រចក.ធ្មេញ.ស្បែក.សាច់.សរសៃ.ឆ្អឹង.ខួរក្នុងឆ្អឹង តម្រងនោម.បេះដូង.ថ្លើម.វាវ.ក្រពះ.សួត.ពោះវៀនធំ.ពោះវៀនតូច.អាហារថ្មី.អាហារចាស់. ប្រមាត់.ស្លេស្ម.ខ្ទុះ.ឈាម.ញើស.ខ្លាញ់ខាប់.ទឹកភ្នែក.ខ្លាញ់រាវ.ទឹកមាត់.ទឹកសម្បោរ.ទឹករំអិល.ទឹកមូត្រ» ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញ្ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ., នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

# ២-៤-ធាតុមនសិការបព្វំ

បុន ច បរំ, ភិក្ខវេ, ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ (12) បច្ចវេក្ខតិ : «អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូ» តិ ។

សេយ្យថាបិ, ភិក្ខវេ, ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា ចតុមហាបថេ (13) ពិលសោ វិភជិត្វា និសិន្នោ អស្ស : ឯវមេវ ខោ, ភិក្ខវេ, ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ : «អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

## ២_ង_ផ្នែកស្ដីអំពីការត្រិះរិះពិចារណាអំពីរូបធាតុ

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ ភិក្ខុត្រិះរិះពិចារណាឃើញច្បាស់អំពីកាយនេះដែលស្ថិតនៅយ៉ាងណាឬតាំងនៅយ៉ាងណាក្ដី ដោយពិនិត្យពិចារណាអំពីធាតុនីមួយៗ(12) ស្របតាមចរិតលក្ខណៈរបស់ធាតុទាំងនេះថា : «នៅក្នុងកាយនេះ មានធាតុដី, ធាតុទឹក, ធាតុភ្លើង និង ធាតុខ្យល់»។

ម្នាលភិក្ខុទាំងឡាយ, គឺដូចជាអ្នកពិឃាតគោឬសិស្សអ្នកពិឃាតគោដែលប៉ិនប្រសប់ ក្រោយពីបានពិឃាតគោនិងវះកាត់ជាចំណែកៗរួចហើយ អង្គុយនៅទៀបផ្លូវបែកជាបួន (13) ។ យ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ, ភិក្ខុពិចារណាឃើញច្បាស់អំពីកាយនេះដែលស្ថិតនៅយ៉ាងណាឬ តាំងនៅយ៉ាងណាក្ដី ដោយពិនិត្យពិចារណាអំពីធាតុនីមួយៗស្របទៅតាមចរិតលក្ខណៈរបស់ធាតុនេះថា : «នៅក្នុងកាយនេះមានធាតុដី, ធាតុទឹក, ធាតុភ្លើងនិងធាតុខ្យល់»ក៏យ៉ាងនោះដែរ ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំប្រឹងសតិដឹងរបស់ខ្លួនឲ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនេះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

# ២-ច-នវសិវថិកបព្វំ

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

## ២.ច.ផ្នែកស្ដីអំពីការពិនិត្យមើលទីស្មសាន៩យ៉ាង

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលស្លាប់បាន១ថ្ងៃ,២ថ្ងៃឬ៣ថ្ងៃ ដែលគេបោះបង់ចោលនៅក្នុងទីស្មសានដែលហើមប៉ោងមានពណ៌ខៀវ,មានខ្ទុះហូរចេញ,ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង,ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ, វានឹងប្រែទៅជាយ៉ាងដូច្នេះ,វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលជំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុទំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ កុលលេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ កង្កេហិ វា ខជ្ជមានំ សុនខេហិ វា ខជ្ជមានំ ព្យគ្ឃេហិ វា ខជ្ជមានំ ទីបីហិ វា ខជ្ជមានំ សិង្គាលេហិ វា ខជ្ជមានំ វិវិធេហិ វា បាណកជាតេហិ ខជ្ជមានំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ»តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសាន ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី, ត្មាតទាំងឡាយកំពុងចឹកស៊ីក្តី,ស្ទាំងទាំងឡាយកំពុងចឹកស៊ីក្តី,ត្រដក់ត្រមង់ទាំងឡាយកំពុងចឹកស៊ីក្តី, ឆ្កែទាំងឡាយកំពុងកកេរស៊ីក្តី, ខ្លាទាំងឡាយកំពុងកកេរស៊ីក្តី,ខ្លារខិនទាំងឡាយកំពុងកកេរស៊ីក្តី,ស្វានទាំងឡាយកំពុងកកេរស៊ីក្តី,សត្វផ្សេងៗដទៃទៀតកំពុងស៊ីក្តី : ភិក្ខុនឹកដល់រូបកាយរបស់ខ្លួនឯង,ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ, វានឹងប្រែទៅជាយ៉ាងដូច្នេះ,វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកសង្ខលិកំ សមំសលោហិតំ ន្ហារុសម្ពន្ធំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសាន សល់តែឆ្អឹង ប្រកបដោយសាច់ខ្លះនិងឈាមតភ្ជាប់គ្នាដោយសរសៃ ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង,ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ, វានឹងប្រែទៅជាយ៉ាងដូច្នេះ,វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ»បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកសង្ខលិកំ និម្មំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ ៖ «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសាន សល់តែឆ្អឹងទទេ គ្មានសាច់តែប្រឡាក់ឈាមតភ្ជាប់គ្នាដោយសរសៃ ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង,ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ, វានឹងប្រែទៅជាយ៉ាងដូច្នេះ,វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលជំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកសង្ខលិកំ អបគតមំសលោហិតំ ន្ហារុសម្ពន្ធំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ. តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសាន សល់តែឆ្អឹងទទេ ឥតមានសាច់ និងឈាមឡើយ តភ្ជាប់គ្នាដោយសរសៃ ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង.ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ. វានឹងប្រែទៅជាយ៉ាងដូច្នេះ.វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង. ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ. ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ. ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ. ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលជំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ. នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ អបគតសម្ពន្ធានិ ទិសា វិទិសា វិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន គោប្ផកដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន បិដ្ឋិដ្ឋិកំ អញ្ញេន ខន្ធដ្ឋិកំ អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុកដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសានសល់តែឆ្អឹងទទេ គ្មានសរសៃចងភ្ជាប់គ្នា នៅខ្ចាត់ខ្ចាយរាត់រាយគ្រប់ទិសទី, ឆ្អឹងដៃនៅត្រង់នេះ,ឆ្អឹងជើងនៅត្រង់នោះ,ឆ្អឹងកែងជើងនៅត្រង់នេះ,ឆ្អឹងជង្គង់នៅត្រង់នោះ, ឆ្អឹងភ្លៅនៅត្រង់នេះ,ឆ្អឹងត្រគាកនៅត្រង់នោះ, ឆ្អឹងខ្នងនៅត្រង់នេះ,ឆ្អឹងទ្រូងខ្នងនៅត្រង់នោះ, ឆ្អឹងស្មានៅត្រង់នោះទៀត, ឆ្អឹងកនៅត្រង់នេះ, ឆ្អឹងចង្កានៅត្រង់នោះ, ឆ្អឹងធ្មេញនៅត្រង់នេះ,ឆ្អឹងលលាដ៍ក្បាលនៅត្រង់នោះ, ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង,ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ, វានឹងប្រែទៅជាយ៉ាងដូច្នេះ,វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុទំពប្រើកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុខសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិភាគានិ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសានសល់តែឆ្អឹងខ្នង មានសម្បុរ ស ដូចសម្បុរខ្យងស័ង្ខ ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង,ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ, វានឹងប្រែទៅជាយ៉ាងដូច្នេះ,វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុទំពប្រើកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ បុញ្ជកិតានិ តេរោវស្សិកានិ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ. តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសានសល់តែឆ្អឹងទទេ គររាយជាគំនរៗកន្លងហួសមួយឆ្នាំមកហើយ ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង.ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ. វានឹងប្រែទៅជាយ៉ាងដូច្នេះ.វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង. ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ. ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ. ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ. ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ»បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ. នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

បុន ច បរំ, ភិក្ខវេ, ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ បូតីនិ ចុណ្ណកជាតានិ ។ សោ ឥមមេវ កាយំ ឧបសំហរតិ : «អយម្បិ ខោ កាយោ ឯវំ ធម្មោ ឯវំ ភាវី ឯវំ អនតីតោ» តិ ។

ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ, ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ, វយធម្មានុបស្សី វា កាយស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ, «អត្ថិ កាយោ» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ.. តទៅទៀតនេះ កាលដែលភិក្ខុឃើញ សាកសពដែលគេបោះបង់ចោលនៅក្នុងទីស្មសានសល់តែឆ្អឹងទទេ ពុកផុយខ្ទេចខ្ទីអស់ ប្រែទៅជាល្អងធូលី ភិក្ខុនឹកដល់កាយរបស់ខ្លួនឯង.ហើយគិតឃើញថា :

«តាមការពិតកាយរបស់អាត្មាអញក៏មានលក្ខណៈយ៉ាងដូច្នេះដែរ. វានឹងប្រែទៅជាយ៉ាងដូច្នេះ.វាមិនអាចចៀសផុតពីលក្ខណៈនេះបានឡើយ» ។

តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុង. ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្រៅ. ឬតាំងនៅពិនិត្យមើល កាយក្នុងកាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ : ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងកាយ. ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងកាយ. ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងកាយ ក្នុងពេលជំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាកាយ» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ : ភិក្ខុខំពម្រើកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅជាប់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ. នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលកាយក្នុងកាយ ។

# ៣- វេទនានុបស្សនា

កថញ្ច បន, ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ? ឥធ, ភិក្ខវេ, ភិក្ខុ សុខំ វា វេទនំ វេទយមានោ «សុខំ វេទនំ វេទយាមី» តិ បជានាតិ; ទុក្ខំ វា វេទនំ វេទយមានោ «ទុក្ខំ វេទនំ វេទយាមី» តិ បជានាតិ; អទុក្ខមសុខំ វា វេទនំ វេទយមានោ «អទុក្ខមសុខំ វេទនំ វេទយាមី» តិ បជានាតិ ។ សាមិសំ វា សុខំ វេទនំ វេទយមានោ «សាមិសំ សុខំ វេទនំ វេទយាមី» តិ បជានាតិ; និរាមិសំ វា សុខំ វេទនំ វេទយមានោ «និរាមិសំ សុខំ វេទនំ វេទយាមី» តិ បជានាតិ ។ សាមិសំ វា ទុក្ខំ វេទនំ វេទយមានោ «សាមិសំ ទុក្ខំ វេទនំ វេទយាមី» តិ បជានាតិ; និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ «និរាមិសំ ទុក្ខំ វេទនំ វេទយាមី» តិ បជានាតិ ។ សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ «សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមី» តិ បជានាតិ; និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ «និរាមិសំ អទុក្ខមសុខំ វេទនំ វេទយាមី» តិ បជានាតិ(14) ។

# ៣_ការពិនិត្យមើលវេទនា

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុតាំងនៅពិនិត្យមើលវេទនា ក្នុងវេទនាទាំងឡាយនោះ តើធ្វើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ, នៅពេលពិសោធឃើញវេទនាជាសុខ ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញវេទនាជាសុខ » នៅពេលពិសោធឃើញវេទនាជាទុក្ខ ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញវេទនាជាទុក្ខ» នៅពេលពិសោធឃើញវេទនាដែលមិនមែនទុក្ខមិនមែនសុខ ភិក្ខុដឹងច្បាស់ថា«អាត្មាអញកំពុងពិសោធឃើញវេទនាដែលមិនមែនទុក្ខមិនមែនសុខ »។ នៅពេលពិសោធឃើញវេទនាជាសុខប្រកបដោយការជំពាក់ចិត្ត ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញវេទនាជាសុខប្រកបដោយការជំពាក់ចិត្ត »; នៅពេលពិសោធឃើញវេទនាជាសុខដោយគ្មានការជំពាក់ចិត្ត ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញវេទនាជាសុខដោយគ្មានការជំពាក់ចិត្ត» ។ នៅពេលពិសោធឃើញវេទនាជាទុក្ខប្រកបដោយការជំពាក់ចិត្ត ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញវេទនាជាទុក្ខប្រកបដោយការជំពាក់ចិត្ត» ។ នៅពេលពិសោធឃើញវេទនាជាទុក្ខដោយគ្មានការជំពាក់ចិត្ត ភិក្ខុដឹងច្បាស់ថា«អាត្មាអញកំពុងពិសោធឃើញវេទនាជាទុក្ខដោយគ្មានការជំពាក់ចិត្ត» ។ នៅពេលពិសោធឃើញវេទនាដែលមិនមែនទុក្ខមិនមែនសុខប្រកបដោយការជំពាក់ចិត្ត ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញ វេទនាដែលមិនមែនទុក្ខមិនមែនសុខប្រកបដោយការជំពាក់ចិត្ត» ។ នៅពេលពិសោធឃើញវេទនាដែលមិនមែនទុក្ខមិនមែនសុខដោយគ្មានការជំពាក់ចិត្ត ភិក្ខុដឹងច្បាស់ថា «អាត្មាអញកំពុងពិសោធឃើញវេទនាដែលមិនមែនទុក្ខមិនមែនសុខដោយគ្មានការជំពាក់ចិត្ត » *(14)* ។

ឥតិ អជ្ឈត្តំ វា វេទនាសុ វេទនានុបស្សី វិហរតិ, ពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា វេទនាសុ វិហរតិ, វយធម្មានុបស្សី វា វេទនាសុ វិហរតិ. សមុទយវយធម្មានុបស្សី វា វេទនាសុ វិហរតិ. «អត្ថិ វេទនា» តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។

*ខ. ការពិនិត្យមើលវេទនា*

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល វេទនាក្នុងវេទនាទាំងឡាយនៅខាងក្នុង, ឬតាំងនៅពិនិត្យមើលវេទនាក្នុងវេទនាទាំងឡាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើលវេទនាក្នុងវេទនាទាំងឡាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងវេទនាទាំងឡាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលរលត់បាត់ទៅវិញនៅក្នុងវេទនាទាំងឡាយ, ឬតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងវេទនាទាំងឡាយ ក្នុងពេលដំណាលគ្នា ។ សតិដែលដឹងថា « នេះគ្រាន់តែជាវេទនា » បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ ភិក្ខុនាំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ : ភិក្ខុតាំងនៅដោយស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលវេទនាក្នុងវេទនាទាំងឡាយ ។

# ៤-ចិត្តានុបស្សនា

កថញ្ច បន, ភិក្ខវេ, ភិក្ខុ ចិត្តេ (15) ចិត្តានុបស្សី វិហរតិ ? ឥធ, ភិក្ខវេ, ភិក្ខុ សរាគំ វា ចិត្តំ «សរាគំ ចិត្តន្តិ» បជានាតិ, វីតរាគំ វា ចិត្តំ «វីតរាគំ ចិត្តន្តិ» បជានាតិ, សទោសំ វា ចិត្តំ «សទោសំ ចិត្តំ»តិ បជានាតិ,«វីតទោសំ វា ចិត្តំ «វីតទោសំ ចិត្តន្តិ» បជានាតិ, សមោហំ វា ចិត្តំ «សមោហំ ចិត្តន្តិ » បជានាតិ, វីតមោហំ វា ចិត្តំ «វីតមោហំ ចិត្តន្តិ » បជានាតិ, សង្ខិត្តំ វា ចិត្តំ «សង្ខិត្តំ ចិត្តន្តិ» បជានាតិ, វិក្ខិត្តំ វា ចិត្តំ «វិក្ខិត្តំ ចិត្តន្តិ» (16) បជានាតិ, មហគ្គតំ វា ចិត្តំ «មហគ្គតំ ចិត្តន្តិ» បជានាតិ, អមហគ្គតំ វា ចិត្តំ «អមហគ្គតំ ចិត្តន្តិ» (17) បជានាតិ, សឧត្តរំ វា ចិត្តំ «សឧត្តរំ ចិត្តន្តិ» បជានាតិ, អនុត្តរំ វា ចិត្តំ «អនុត្តរំ ចិត្តន្តិ» (18) បជានាតិ, សមាហិតំ វា ចិត្តំ«សមាហិតំ ចិត្តន្តិ» បជានាតិ អសមាហិតំ វា ចិត្តំ «អសមាហិតំ ចិត្តន្តិ» (19) បជានាតិ, វិមុត្តំ វា ចិត្តំ «វិមុត្តំ ចិត្តន្តិ» បជានាតិ, អវិមុត្តំ វា ចិត្តំ «អវិមុត្តំ ចិត្តន្តិ» បជានាតិ ។

# ៤_ការពិនិត្យមើលចិត្ត

ម្នាលភិក្ខុទាំងឡាយ. តទៅទៀតនេះ ចុះភិក្ខុតាំងនៅពិនិត្យមើលចិត្តក្នុងចិត្ត. នុ៎ះតើធ្វើយ៉ាងដូចម្តេច (15)?

ម្នាលភិក្ខុទាំងឡាយ. ក្នុងទីនេះ : កាលចិត្តប្រកបដោយរាគៈ ភិក្ខុដឹងច្បាស់ថាជាចិត្តប្រកបដោយរាគៈ. កាលចិត្ត ប្រាសចាករាគៈ ក៏ដឹងច្បាស់ថាជាចិត្តប្រាសចាករាគៈ. កាលចិត្ត ប្រកបដោយទោសៈ ភិក្ខុដឹងច្បាស់ថាជាចិត្តប្រកបដោយទោសៈ. កាលចិត្ត ប្រាសចាកទោសៈ ក៏ដឹងច្បាស់ថាជាចិត្តប្រាសចាកទោសៈ. កាលចិត្ត ប្រកបដោយមោហៈ ភិក្ខុដឹងច្បាស់ថាជាចិត្ត ប្រកបដោយមោហៈ. កាលចិត្តប្រាសចាកមោហៈ. ក៏ដឹងច្បាស់ថាជាចិត្តប្រាសចាកមោហៈ. កាលចិត្តនឹងនគ្មានតក់ស្លុត. ភិក្ខុដឹងច្បាស់ថាជាចិត្ត នឹងនគ្មានតក់ស្លុត,កាលចិត្តរាយមាយ. ក៏ដឹងច្បាស់ថាជា ចិត្តរាយមាយ (16) ។ កាលចិត្តរីកចំរើន. ភិក្ខុដឹងច្បាស់ថាជាចិត្តរីកចំរើន. កាលចិត្តមិនរីកចំរើន ក៏ដឹងច្បាស់ថាជា ចិត្តមិនរីកចំរើន (17) ។ កាលចិត្តដែលមានចិត្តដទៃប្រសើរជាង. ភិក្ខុក៏ដឹងច្បាស់ថាជា ចិត្តមានចិត្តដទៃប្រសើរជាង. កាលចិត្ត ដែលគ្មានចិត្តដទៃប្រសើរជាង ក៏ដឹងច្បាស់ថា ជាចិត្តគ្មានចិត្តដទៃប្រសើរជាង (18) ។ កាលចិត្ត ដែលតាំងនៅមាំ ភិក្ខុដឹងច្បាស់ថាជាចិត្ត តាំងនៅមាំ. កាលចិត្តដែលមិនទាន់តាំងនៅមាំ.ក៏ដឹងច្បាស់ថាជាចិត្តមិនទាន់តាំងនៅមាំ (19) ។ កាលចិត្តដែលបានរួចរដោះ.ភិក្ខុដឹងច្បាស់ថា ចិត្តបានរួចរដោះ. កាលចិត្តដែលមិនទាន់បានរួចរដោះ. ភិក្ខុដឹងច្បាស់ថាជាចិត្តមិនទាន់បានរួចរដោះ ។

ឥតិ អជ្ឈត្តំ វា ចិត្តេ ចិត្តានុបស្សី វិហរតិ, ពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ, (20) សមុទយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ, វយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ, សមុទយវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ, «អត្ថិ ចិត្តន្តិ» វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល ចិត្តក្នុងចិត្តនៅខាងក្នុង ឬ តាំងនៅពិនិត្យមើល ចិត្តក្នុងចិត្តនៅខាងក្រៅ. ឬតាំងនៅពិនិត្យមើល ចិត្តក្នុងចិត្តនៅខាងក្នុងផងនៅខាងក្រៅផង (20)។ តាមរបៀបនេះភិក្ខុតាំងនៅពិនិត្យមើលធម៌ ដែលកើតឡើងនៅក្នុងចិត្ត ឬតាំងនៅពិនិត្យមើល ធម៌ដែលរលត់បាត់ទៅវិញនៅក្នុងចិត្ត. ឬតាំងនៅពិនិត្យមើល ធម៌ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងចិត្តក្នុងពេលជំណាលគ្នា ។ សតិដែលដឹងថា «នេះគ្រាន់តែជាចិត្ត» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ.ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ. ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ. នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលចិត្តក្នុងចិត្ត ។

## ៥-ធម្មានុបស្សនា
### ៥-ក-នីវរណបព្វ

កថញ្ច បន ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ?

ឥធ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។

កថញ្ច បន ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ?

ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ (21)«អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោ» តិ បជានាតិ អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ «នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោ» តិ បជានាតិ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

# ៥_ការពិនិត្យមើលធម៌ទាំងឡាយ
## ៥_ក_ផ្នែកស្តីអំពីធម៌រាំង

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ ចុះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនោះ តើធ្វើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះ ភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី នីវរណៈ គឺធម៌រាំង៥យ៉ាង ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពីនីវរណៈ គឺធម៌រាំង៥យ៉ាងនោះតើធ្វើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះ,កាលកាមច្ឆន្ទៈ សេចក្តីប្រាថ្នាក្នុងកាម(21) មាននៅក្នុងខ្លួន, ភិក្ខុដឹងច្បាស់ថា «កាមច្ឆន្ទៈមាននៅក្នុងខ្លួនរបស់អាត្មាអញ»។ កាលកាមច្ឆន្ទៈមិនមាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា «កាមច្ឆន្ទៈមិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ» កាលកាមច្ឆន្ទៈដែលមិនទាន់មាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, កាលកាមច្ឆន្ទៈ ដែលកើតមានឡើងក្នុងខ្លួន, ហើយរលត់បាត់ទៅវិញដោយហេតុណា, ភិក្ខុដឹងច្បាស់នូវហេតុនោះ, កាលកាមច្ឆន្ទៈ ដែលរលត់បាត់ទៅវិញ ហើយមិនកើតមានទៀតតទៅអនាគតដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

សន្តំ វា អជ្ឈត្តំ ព្យាបាទំ (22) «អត្ថិ មេ អជ្ឈត្តំ ព្យាបាទោ»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ«នត្ថិ មេ អជ្ឈត្តំ ព្យាបាទោ»តិ បជានាតិ យថា ច អនុប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ (23) «អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ» បជានាតិ អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ «នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធំ»តិ បជានាតិ យថា ច អនុប្បន្នស្ស ថីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ថីនមិទ្ធស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ថីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

កាលព្យាបាទ (22) មាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា «ព្យាបាទ មាននៅក្នុងខ្លួនរបស់អាត្មាអញ »។ កាលព្យាបាទ មិនមាននៅក្នុងខ្លួន, ភិក្ខុដឹងច្បាស់ថា «ព្យាបាទ មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ »។ កាលព្យាបាទ មិនទាន់មាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលព្យាបាទ កើតមានឡើងក្នុងខ្លួន, ហើយរលត់ចាត់ទៅវិញដោយហេតុណា,ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលព្យាបាទ ដែលរលត់ចាត់ទៅវិញ ហើយមិនកើតមានទៀតទៅអនាគតដោយហេតុណា, ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

កាលថីនមិទ្ធៈភាពច្រអូសកាយ,ច្រអូសចិត្ត(23) មាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា «ថីនមិទ្ធៈ មាននៅក្នុងខ្លួនរបស់អាត្មាអញ »។ កាលថីនមិទ្ធៈ មិនមាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា«ថីនមិទ្ធៈមិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ »។ កាលថីនមិទ្ធៈមិនទាន់មាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលថីនមិទ្ធៈ កើតមានឡើងក្នុងខ្លួន, ហើយរលត់ចាត់ទៅវិញដោយហេតុណា,ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលថីនមិទ្ធៈ ដែលរលត់ចាត់ទៅវិញ ហើយមិនកើតមានទៀតទៅអនាគតដោយហេតុណា,ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ «អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ» បជានាតិ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ «នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ» បជានាតិ យថា ច អនុប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ឧទ្ធច្ចកុក្កុច្ចស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ *(24)* «អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆា»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ «នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆា»តិ បជានាតិ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

កាលឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរំជើបរំជួលចិត្តជាខ្លាំងនិងសេចក្តីស្តាយក្រោយ មាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា : «ឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងខ្លួនរបស់អាត្មាអញ »។ កាលឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅក្នុងខ្លួន, ភិក្ខុដឹងច្បាស់ថា «ឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅ ក្នុងខ្លួនរបស់អាត្មាអញទេ »។ កាលឧទ្ធច្ចកុក្កុច្ចៈ មិនទាន់មាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលឧទ្ធច្ចកុក្កុច្ចៈ កើតមានឡើងក្នុងខ្លួន, ហើយរលត់បាត់ទៅវិញដោយហេតុណា,ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលឧទ្ធច្ចកុក្កុច្ចៈ ដែលរលត់បាត់ទៅវិញហើយមិនកើតមានទៀតទៅអនាគតដោយហេតុណា, ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

kal vickics(24) គឺសេចក្តីសង្ស័យមាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា «វិចិកិច្ឆា មាននៅក្នុងខ្លួនរបស់អាត្មាអញ », កាលវិចិកិច្ឆា មិនមាននៅក្នុងខ្លួន, ភិក្ខុដឹងច្បាស់ថា «វិចិកិច្ឆា មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ »,កាលវិចិកិច្ឆា មិនទាន់មាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, កាលវិចិកិច្ឆា កើតមានឡើងក្នុងខ្លួន, ហើយរលត់បាត់ទៅវិញដោយហេតុណា,ភិក្ខុដឹងច្បាស់នូវហេតុនោះ, កាលវិចិកិច្ឆា ដែលរលត់បាត់ទៅវិញ ហើយមិនកើតមានទៀតទៅអនាគតដោយហេតុណា,ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

---

*(A) ឧទ្ធច្ច : សេចក្តីរំជើបរំជួលចិត្តជាខ្លាំង*(agitation) + *កុក្កុច្ចៈ : វិប្បដិសារី,សេចក្តីស្តាយក្រោយ* (remorse)

ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ, ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ, វយធម្មានុបស្សី វា ធម្មេសុ វិហរតិ, សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ, «អត្ថិ ធម្មា»តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល ធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុង ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ, ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងធម៌ទាំងឡាយ ឬតាំងនៅពិនិត្យមើល ធម៌ដែលរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយ.ឬតាំងនៅពិនិត្យមើល ធម៌ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយក្នុងពេលដំណាលគ្នា ។សតិដែលដឹងថា « នេះគ្រាន់តែជាធម៌» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ,ភិក្ខុនំាពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ,ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ. នេះហើយជារបៀបដែលភិក្ខុតាំងនៅ ពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី ធម៌រាំង៥យ៉ាង ។

# ៥-២-ខន្ធបព្វំ

បុន ច បរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។

កថញ្ច បន ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ (25)?

ឥធ ភិក្ខវេ ភិក្ខុ «ឥតិ រូបំ ឥតិ រូបស្ស សមុទយោ, ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ, ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ, ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ, ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ, ឥតិ វិញ្ញាណស្ស អត្ថង្គមោ» តិ ។

ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ, ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ, វយធម្មានុបស្សី វា ធម្មេសុ វិហរតិ, សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ, «អត្ថិ ធម្មា»តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។

# ៥.១.ផ្នែកស្តីអំពីខន្ធ៥

ម្នាលភិក្ខុទាំងឡាយ ! តទៅទៀតនេះ,ភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ ស្តីអំពី ឧបាទានក្ខន្ធ (ការប្រកាន់មាំក្នុងខ័ន្ធ៥ថាជារបស់ខ្លួន) ៥យ៉ាង ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ គឺ ឧបាទានក្ខន្ធ៥យ៉ាងនោះ(25) តើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះភិក្ខុដឹងច្បាស់ថា : « នេះជារូប,នេះជាការកើតឡើងនៃរូប,នេះជាការរលត់បាត់ទៅវិញនៃរូប, នេះជាវេទនាទាំងឡាយ,នេះជាការកើតឡើងនៃវេទនាទាំងឡាយ,នេះជាការរលត់បាត់ទៅវិញនៃវេទនាទាំងឡាយ,នេះជាសញ្ញា,នេះជាការកើតឡើងនៃសញ្ញា,នេះជាការរលត់បាត់ទៅវិញនៃសញ្ញា,នេះជាសង្ខារទាំងឡាយ,នេះជាការកើតឡើងនៃសង្ខារទាំងឡាយ,នេះជាការរលត់បាត់ទៅវិញនៃសង្ខារទាំងឡាយ,នេះជាវិញ្ញាណ,នេះជាការកើតឡើងនៃវិញ្ញាណ,នេះជាការរលត់បាត់ទៅវិញនៃវិញ្ញាណ» ។

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល ធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុង ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ, ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងធម៌ទាំងឡាយ ឬតាំងនៅពិនិត្យមើល ធម៌ដែលរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយ,ឬតាំងនៅពិនិត្យមើល ធម៌ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយក្នុងពេលដំណាលគ្នា ។សតិដែលដឹងថា « នេះគ្រាន់តែជាធម៌» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ,ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ,ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ,នេះហើយជារបៀបដែលភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ ស្តីអំពី ឧបាទានក្ខន្ធ៥យ៉ាង ។

# ៥-គ-អាយតនបព្វំ

បុន ច បរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។

កថញ្ច បន ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិក-ពាហិរេសុ អាយតនេសុ ?

ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ រូបេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ តញ្ច បជានាតិ យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស សំយោជនស្ស អាយត អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

សោតញ្ច បជានាតិ សទ្ទេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ តញ្ច បជានាតិ យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស សំយោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

# ៥.គ.ផ្នែកស្តីអំពីអាយតនៈ

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី អាយតនៈខាងក្នុង៦និងអាយតនៈខាងក្រៅ៦ ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពីអាយតនៈខាងក្នុង៦និងអាយតនៈខាងក្រៅ៦នោះ តើធ្វើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះភិក្ខុដឹងច្បាស់នូវភ្នែក,ដឹងច្បាស់នូវ រូបារម្មណ៍(រូបភាព)ទាំងឡាយហើយដឹងច្បាស់នូវចំណងដែលកើតមកអំពីភ្នែកនិងរូបារម្មណ៍ ប្រាស្រ័យគ្នានេះផង, ចំណងដែលមិនទាន់កើតមាន,អាចកើតមានឡើងដោយហេតុណាភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានកើតឡើងវេលានេះ,ហើយរលត់បាត់ទៅវិញដោយហេតុណាភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានរលត់បាត់ទៅវិញក្នុងពេលឥឡូវនេះហើយដែលមិនកើតមានទៀតទៅអនាគតដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ។

ភិក្ខុដឹងច្បាស់នូវត្រចៀក,ដឹងច្បាស់នូវសទ្ទារម្មណ៍(សម្លេង)ទាំងឡាយហើយដឹងច្បាស់នូវចំណងដែលកើតឡើងអំពីត្រចៀក និង សទ្ទារម្មណ៍ ប្រាស្រ័យគ្នានេះផង, ចំណងដែលមិនទាន់កើតមាន អាចកើតមានឡើងដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានកើតឡើងវេលានេះ ហើយរលត់បាត់ទៅវិញដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានរលត់បាត់ទៅវិញក្នុងពេលឥឡូវនេះហើយដែលមិនកើតមានទៀតទៅអនាគតដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ។

ឃានញ្ច បជានាតិ គន្ធេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ តញ្ច បជានាតិ, យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ តញ្ច បជានាតិ, យថា ច បហីនស្ស សំយោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

ជិវ្ហញ្ច បជានាតិ រសេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ តញ្ច បជានាតិ, យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ តញ្ច បជានាតិ, យថា ច បហីនស្ស សំយោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

កាយញ្ច បជានាតិ ផោដ្ឋព្វេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ តញ្ច បជានាតិ, យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស សំយោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

ភិក្ខុដឹងច្បាស់នូវច្រមុះ ដឹងច្បាស់នូវគន្ធារម្មណ៍(ក្លិន)ទាំងឡាយ,ហើយដឹងច្បាស់នូវចំណងដែលកើតមកអំពី ច្រមុះនិងគន្ធារម្មណ៍ ប្រាស្រ័យគ្នានេះផង,ចំណងដែលមិនទាន់កើតមាន អាចកើតមានឡើងដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានកើតឡើងវេលានេះ ហើយរលត់បាត់ទៅវិញដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ,ចំណងដែលបានរលត់បាត់ទៅវិញក្នុងពេលឥឡូវនេះ ហើយដែលមិនកើតមានទៀតទៅអនាគតដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

ភិក្ខុដឹងច្បាស់នូវអណ្តាតដឹងច្បាស់នូវរសារម្មណ៍(រសជាតិ)ទាំងឡាយ,ហើយដឹងច្បាស់នូវចំណងដែលកើតមកអំពីអណ្តាតនិងរសារម្មណ៍ប្រាស្រ័យគ្នានេះផង, ចំណងដែលមិនទាន់កើតមាន អាចកើតមានឡើងដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានកើតឡើងវេលានេះ ហើយរលត់បាត់ទៅវិញដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានរលត់បាត់ទៅវិញក្នុងពេលឥឡូវនេះ ហើយដែលមិនកើតមានទៀតទៅអនាគតដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

ភិក្ខុដឹងច្បាស់នូវកាយ ដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយ,ហើយដឹងច្បាស់នូវចំណងដែលកើតមកអំពីកាយ និងផោដ្ឋព្វារម្មណ៍ប្រាស្រ័យគ្នានេះផង,ចំណងដែលមិនទាន់កើតមានអាចកើតមានឡើងដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ,ចំណងដែលបានកើតឡើងវេលានេះហើយរលត់បាត់ទៅវិញដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានរលត់បាត់ទៅវិញក្នុងពេលឥឡូវនេះ, ហើយដែលមិនកើតមានទៀតទៅអនាគតដោយហេតុណាភិក្ខុដឹងច្បាស់នូវហេតុនោះ ។

មនញ្ច បជានាតិ ធម្មេ ច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ តញ្ច បជានាតិ, យថា ច អនុប្បន្នស្ស សំយោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស សំយោជនស្ស បហានំ ហោតិ តញ្ច បជានាតិ, យថា ច បហីនស្ស សំយោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ, ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ, វយធម្មានុបស្សី វា ធម្មេសុ វិហរតិ, សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ, «អត្ថិ ធម្មា»តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិក ពាហិរេសុ អាយតនេសុ ។

*៥.ការពិនិត្យមើលធម៌ទាំងឡាយ. ៥.គ. ផ្នែកស្តីអំពីអាយតនៈ*

ភិក្ខុដឹងច្បាស់នូវចិត្ត ដឹងច្បាស់នូវធម្មារម្មណ៍(គំនិត) ទាំងឡាយ.ហើយដឹងច្បាស់នូវចំណងដែលកើតមកអំពី ចិត្ត និង ធម្មារម្មណ៍ ព្រាស្រ័យគ្នានេះផង. ចំណងដែលមិនទាន់កើតមាន អាចកើតមានឡើងដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, ចំណងដែលបានកើតឡើងវេលានេះ ហើយរលត់បាត់ទៅវិញដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ. ចំណងដែលបានរលត់បាត់ទៅវិញក្នុងពេលឥឡូវនេះ ហើយដែលមិនកើតមានទៀតទៅអនាគតដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល ធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុង ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ, ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងធម៌ទាំងឡាយ ឬតាំងនៅពិនិត្យមើល ធម៌ដែលរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយ.ឬតាំងនៅពិនិត្យមើល ធម៌ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយក្នុងពេលជំណាលគ្នា។សតិដែលដឹងថា «នេះគ្រាន់តែជាធម៌» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ,ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ,ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ.នេះហើយជារបៀបដែលភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី អាយតនៈខាងក្នុង៦ និង អាយតនៈខាងក្រៅ៦ ។

# ៥-ឃ-ពោជ្ឈង្គបព្វំ

បុន ច បរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។

កថញ្ច បន, ភិក្ខវេ, ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ?

ឥធ, ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ «អត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោ»តិ បជានាតិ, អសន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោ»តិ បជានាតិ, យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស សតិពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ ។

សន្តំ វា អជ្ឈត្តំ ធម្មវិចយសម្ពោជ្ឈង្គំ(26) «អត្ថិ មេ អជ្ឈត្តំ ធម្មវិចយ-សម្ពោជ្ឈង្គោ» តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ធម្មវិចយសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ ធម្មវិចយសម្ពោជ្ឈង្គោ» តិ បជានាតិ, យថា ច អនុប្បន្នស្ស ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស ធម្មវិចយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ ។

# ៥-ឃ-ផ្នែកស្តីអំពីអង្គ៧នៃការត្រាស់ដឹង

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះភិក្ខុតាំងនៅពិនិត្យមើល ធម៌ក្នុងធម៌ទាំងឡាយ ស្តីអំពី អង្គ៧នៃការត្រាស់ដឹង ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី អង្គ៧នៃការត្រាស់ដឹងនោះ តើធ្វើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ,ក្នុងទីនេះ,កាលអង្គនៃការត្រាស់ដឹងគឺសតិ មាននៅក្នុងខ្លួន, ភិក្ខុដឹងច្បាស់ថា «សតិ មាននៅក្នុងខ្លួនរបស់អាត្មាអញ»,កាលអង្គនៃការត្រាស់ដឹងគឺសតិ មិនមាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា«សតិ មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ»,កាល អង្គនៃការត្រាស់ដឹងគឺសតិ ដែលមិនទាន់កើតមាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយ ហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលអង្គនៃការត្រាស់ដឹងគឺសតិ ដែលបាន កើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរឹងរឹតតែរីកចំរើនឡើង ពេញបរិបូណ៌ ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

កាលអង្គនៃការត្រាស់ដឹងគឺធម្មវិចយ (ការពិនិត្យពិច័យធម៌ (26))មាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា «ធម្មវិចយ មាននៅក្នុងខ្លួនរបស់អាត្មាអញ» ។ កាលអង្គនៃការត្រាស់ដឹង គឺធម្មវិចយ មិនមាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា«ធម្មវិចយ មិនមាននៅក្នុងខ្លួន របស់អាត្មាអញទេ», កាលអង្គនៃការត្រាស់ដឹងគឺធម្មវិចយ ដែលមិនទាន់កើតមានហើយ កើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ,កាលអង្គនៃការ ត្រាស់ដឹងគឺ ធម្មវិចយ ដែលបានកើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរឹងរឹត តែរីកចំរើនឡើងពេញបរិបូណ៌ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

សន្តំ វា អជ្ឈត្តំ វីរិយសម្ពោជ្ឈង្គំ «អត្ថិ មេ អជ្ឈត្តំ វីរិយសម្ពោជ្ឈង្គោ»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ វីរិយសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ វីរិយសម្ពោជ្ឈង្គោ»តិ បជានាតិ យថា ច អនុប្បន្នស្ស វីរិយសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស វីរិយសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ ។

សន្តំ វា អជ្ឈត្តំ បីតិសម្ពោជ្ឈង្គំ[27] «អត្ថិ មេ អជ្ឈត្តំ បីតិសម្ពោជ្ឈង្គោ»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ បីតិសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ បីតិសម្ពោជ្ឈង្គោ»តិ បជានាតិ យថា ច អនុប្បន្នស្ស បីតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស បីតិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ ។

*៥.ឃ. ផ្នែកស្តីអំពីអង្គ៧ប្រការនៃការត្រាស់ដឹង*

កាលអង្គនៃការត្រាស់ដឹងគឺវិរិយៈ សេចក្តីព្យាយាម មាននៅក្នុងខ្លួន.ភិក្ខុដឹងច្បាស់ថា «វិរិយៈ មាននៅក្នុងខ្លួនរបស់អាត្មាអញ». កាលអង្គនៃការត្រាស់ដឹងគឺ វិរិយ មិនមាននៅក្នុងខ្លួន.ភិក្ខុដឹងច្បាស់ថា «វិរិយៈ មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ». កាលអង្គនៃការត្រាស់ដឹងគឺ វិរិយៈដែលមិនទាន់កើតមាន.ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ. កាលអង្គនៃការត្រាស់ដឹងគឺ វិរិយៈ ដែលបានកើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរីងរឹតតែរីកចំរើនឡើងពេញបរិបូណ៌ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

កាលអង្គនៃការត្រាស់ដឹងគឺបីតិ សេចក្តីត្រេកអរខ្លាំង (27) មាននៅក្នុងខ្លួន.ភិក្ខុដឹងច្បាស់ថា«បីតិ មាននៅក្នុងខ្លួនរបស់អាត្មាអញ». កាលអង្គនៃការត្រាស់ដឹងគឺបីតិ មិនមាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា «បីតិ មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ». កាលអង្គនៃការត្រាស់ដឹងគឺ បីតិ ដែលមិនទាន់កើតមាន ហើយកើតមានឡើងនៅក្នុងខ្លួនដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ. កាលអង្គនៃការត្រាស់ដឹងគឺ បីតិ ដែលបានកើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរីងរឹតតែរីកចំរើនឡើងពេញបរិបូណ៌ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

សន្តំ វា អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គំ (28) «អត្ថិ មេ អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គោ»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គោ»តិ បជានាតិ, យថា ច អនុប្បន្នស្ស បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស បស្សទ្ធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ។

សន្តំ វា អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គំ «អត្ថិ មេ អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គោ»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គោ»តិ បជានាតិ, យថា ច អនុប្បន្នស្ស សមាធិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស សមាធិសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ។

កាលអង្គនៃការត្រាស់ដឹងគឺ បស្សទ្ធិ សេចក្តីស្ងប់(28)មាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា «បស្សទ្ធិ មាននៅក្នុងខ្លួនរបស់អាត្មាអញ», កាលអង្គនៃការត្រាស់ដឹងគឺ បស្សទ្ធិ មិនមាននៅក្នុងខ្លួន,ភិក្ខុដឹងច្បាស់ថា «បស្សទ្ធិ មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ»,កាលអង្គនៃការត្រាស់ដឹងគឺបស្សទ្ធិ ដែលមិនទាន់កើតមាន ហើយកើតមានឡើងនៅក្នុងខ្លួន ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, កាលអង្គនៃការត្រាស់ដឹងគឺបស្សទ្ធិ ដែលបានកើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរីងរឹតតែរីកចំរើនឡើងពេញបរិបូណ៌ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

កាលអង្គនៃការត្រាស់ដឹងគឺសមាធិ កិរិយាតាំងមាំនៃចិត្តមាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា«សមាធិ មាននៅក្នុងខ្លួនរបស់អាត្មាអញ», កាលអង្គនៃការត្រាស់ដឹងគឺសមាធិ មិនមាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា «សមាធិ មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ», កាលអង្គនៃការត្រាស់ដឹងគឺសមាធិ ដែលមិនទាន់កើតមាន ហើយកើតមានឡើងនៅក្នុងខ្លួន ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ, កាលអង្គនៃការត្រាស់ដឹងគឺសមាធិ ដែលបានកើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរីងរឹតតែរីកចំរើនឡើងពេញបរិបូណ៌ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

សន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ «អត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោ»តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ «នត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោ»តិ បជានាតិ, យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ, យថា ច ឧប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាយ បារិបូរី ហោតិ តញ្ច បជានាតិ។

ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ, ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ, វយធម្មានុបស្សី វា ធម្មេសុ វិហរតិ, សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ, «អត្ថិ ធម្មា»តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។

*៥.ឃ. ផ្នែកស្តីអំពីអង្គ៧ប្រការនៃការត្រាស់ដឹង*

កាលអង្គនៃការត្រាស់ដឹងគឺ ឧបេក្ខា ភាពឥតលំអៀង មាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា«ឧបេក្ខា មាននៅក្នុងខ្លួនរបស់អាត្មាអញ» ។ កាលអង្គនៃការត្រាស់ដឹងគឺឧបេក្ខា មិនមាននៅក្នុងខ្លួន ភិក្ខុដឹងច្បាស់ថា «ឧបេក្ខា មិនមាននៅក្នុងខ្លួនរបស់អាត្មាអញទេ »។ កាលអង្គនៃការត្រាស់ដឹងគឺឧបេក្ខា ដែលមិនទាន់កើតមាន ហើយកើតមានឡើងនៅក្នុងខ្លួន ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។ កាលអង្គនៃការត្រាស់ដឹងគឺឧបេក្ខា ដែលបានកើតឡើងនៅក្នុងខ្លួនក្នុងពេលឥឡូវនេះ ហើយរឹងរឹតតែរីកចំរើនឡើងពេញបរិបូណ៌ដោយហេតុណា ភិក្ខុដឹងច្បាស់នូវហេតុនោះ ។

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល ធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុង ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្រៅ ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងធម៌ទាំងឡាយ ឬតាំងនៅពិនិត្យមើល ធម៌ដែលរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយ ឬតាំងនៅពិនិត្យមើល ធម៌ដែលកើតឡើងនិងរលត់បាត់ទៅវិញនៅក្នុងធម៌ទាំងឡាយក្នុងពេលដំណាលគ្នា ។សតិដែលដឹងថា « នេះគ្រាន់តែជាធម៌» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ ភិក្ខុខំពង្រីកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ នេះហើយជារបៀបដែលភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី អង្គទាំង៧ នៃការត្រាស់ដឹង ។

# ៥-១-ចតុសច្ចបព្វំ

បុន ច បរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។

កថញ្ច បន ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ?

ឥធ ភិក្ខវេ ភិក្ខុ «ឥទំ ទុក្ខំ»តិ យថាភូតំ បជានាតិ, «អយំ ទុក្ខសមុទយោ»តិ យថាភូតំ បជានាតិ, «អយំ ទុក្ខនិរោធោ» តិ យថាភូតំ បជានាតិ, «អយំ ទុក្ខនិរោធគាមិនី បដិបទា»តិ យថាភូតំ បជានាតិ ។

# ៥.ង. ផ្នែកស្តីអំពីអរិយសច្ចៈ៤

ម្នាលភិក្ខុទាំងឡាយ, តទៅទៀតនេះ ភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ ស្តីអំពីអរិយសច្ចៈ៤ ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពីអរិយសច្ចៈ៤ នោះ តើធ្វើយ៉ាងដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះ, ភិក្ខុដឹងច្បាស់តាមភាពពិតរបស់វាថា « នេះជាទុក្ខ », ដឹងច្បាស់តាមភាពពិតរបស់វាថា « នេះជាមូលហេតុរបស់ទុក្ខ », ដឹងច្បាស់តាមភាពពិតរបស់វាថា « នេះជាការរលត់ទៅនៃទុក្ខ », ដឹងច្បាស់តាមភាពពិតរបស់វាថា « នេះជាមាគ៌ាឆ្ពោះទៅរកការរលត់ទុក្ខ » ។

# ទុក្ខសច្ចំ

កតមញ្ច ភិក្ខវេ, ទុក្ខំ អរិយសច្ចំ ?

ជាតិ បិ ទុក្ខា, ជរា បិ ទុក្ខា, ព្យាធិ បិ ទុក្ខា,(29)មរណម្បិ ទុក្ខំ,សោកបរិទេវទុក្ខទោមនស្សុបាយាសា បិ ទុក្ខា, អប្បិយេហិ សម្បយោគោ បិ ទុក្ខោ, បិយេហិ វិប្បយោគោ បិ ទុក្ខោ, យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ, សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។

កតមា ច ភិក្ខវេ ជាតិ ?

យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភិក្ខវេ, ជាតិ ។

កតមា ច ភិក្ខវេ ជរា ?

យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ, ភិក្ខវេ, ជរា ។

កតមញ្ច ភិក្ខវេ មរណំ ?

យំ តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្សុបច្ឆេទោ, ឥទំ វុច្ចតិ, ភិក្ខវេ, មរណំ ។

# សេចក្តីពិតអំពីទុក្ខ

ម្នាលភិក្ខុទាំងឡាយ, ចុះសេចក្តីពិតអំពីទុក្ខនោះ តើយ៉ាងដូចម្តេច ? ជាតិ(កំណើត) ជាទុក្ខ, ជរា(សេចក្តីចាស់) ជាទុក្ខ,ព្យាធិ(ជម្ងឺ) ជាទុក្ខ(29), មរណៈ(សេចក្តីស្លាប់)ជាទុក្ខ,សោកៈ(សេចក្តីស្តាយស្រណោះ) ជាទុក្ខ,បរិទេវៈ(សេចក្តីខ្សឹកខ្សួល) ជាទុក្ខ, ទុក្ខៈ(សេចក្តីលំបាកកាយ) ជាទុក្ខ, ទោមនស្ស(សេចក្តីអាក់អន់ចិត្ត) ជាទុក្ខ, ឧបាយាសៈ(សេចក្តីចង្អៀតចង្អល់ក្នុងចិត្ត) ជាទុក្ខ, ការជួបប្រសព្វនឹងរបស់ដែលមិនចូលចិត្តជាទុក្ខ, ការព្រាត់ប្រាសអំពីរបស់ដែលស្រឡាញ់ចូលចិត្តជាទុក្ខ ។ ដោយសង្ខេប, ការប្រកាន់ខ្ជាប់ទៅលើ ខន្ធ៥ ជា ទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថា ជាតិ ឬ កំណើត ?

កំណើតគឺការកើតនៃសត្វទាំងឡាយក្នុងសត្តនិកាយផ្សេងៗ, ការចាប់បដិសន្ធិ, ការកើតចេញពីផ្ទៃ, ការវិវឌ្ឍន៍ទៅរកកំណើត, ការកើតឡើងនៃខន្ធ, ការបានមកនូវអាយតនៈរបស់សត្វទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថាជាតិ ឬ កំណើត ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថា ជរា (សេចក្តីចាស់)?

ជរា គឺ សេចក្តីចាស់គ្រាំគ្រារបស់សត្វទាំងឡាយក្នុងសត្តនិកាយផ្សេងៗ,ការចុះទន់ខ្សោយនិងការទ្រុឌទ្រោម, ភាពបាក់ធ្មេញ, សក់ស្កូវ,ស្បែកជ្រីវជ្រួញ, ការរួញថយនៃអាយុ, ការទ្រុឌទ្រោមនៃឥន្ទ្រីយ៍ទាំងឡាយរបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថា ជរា ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថា មរណៈ (សេចក្តីស្លាប់) ?

មរណៈគឺ ការបាត់បង់,ការចេញចាករបស់សត្វទាំងឡាយពីសត្តនិកាយផ្សេងៗ, ការបែកធ្លាយ, ការបាត់បង់, ការរលត់ទៅនៃជីវិត, សេចក្តីស្លាប់, កាលកិរិយា,ការបែកធ្លាយនៃខន្ធទាំងឡាយ, ការបោះបង់ចោលកាយ, ការផ្តាច់ផ្តិលជីវិតិន្ទ្រីយ៍របស់សត្វទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ, នេះ ហើយហៅថា មរណៈ ។

កតមោ ច ភិក្ខវេ សោកោ ?

យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោ បរិសោកោ អយំ វុច្ចតិ. ភិក្ខវេ. សោកោ ។

កតមោ ច ភិក្ខវេ បរិទេវោ ?

យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ អយំ វុច្ចតិ ភិក្ខវេ បរិទេវោ ។

កតមញ្ច ភិក្ខវេ ទុក្ខំ (30) ?

យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ទុក្ខំ ។

កតមញ្ច ភិក្ខវេ ទោមនស្សំ (30) ?

យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សំ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថាសោកៈ (សេចក្តីស្ពាយស្រណោះ)?

កាលណាគេជួបប្រទះនឹងការខាតបង់ ឬ អពមង្គលផ្សេងៗ ដែលនាំឱ្យមានសេចក្តីព្រួយចិត្តបែបណាមួយ, សេចក្តីស្ពាយស្រណោះ, សេចក្តីស្រងេះស្រងោច, សេចក្តីសង្រេងសង្រៃ, សេចក្តីក្រៀមក្រំក្នុងចិត្តរបស់សត្វ។ ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថាសោកៈ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថា បរិទេវៈ (សេចក្តីខ្សឹកខ្សួល) ?

កាលណាគេជួបប្រទះនឹងការបាត់បង់ ឬ អពមង្គលផ្សេងៗ ដែលនាំសត្វឱ្យមានសេចក្តីព្រួយចិត្តបែបណាមួយ , ការយំសោកខ្សឹកខ្សួលខ្ញុរខ្ញៀបរាប់, ខ្ញុរខ្ញួលខ្ញែ, យំអណ្តឺតអណ្តក់, ភាពនៃការយំសោកខ្សឹកខ្សួល, យំអណ្តឺតអណ្តក់, ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថា បរិទេវៈ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថាទុក្ខៈ (សេចក្តីលំបាកកាយ)(30)?

កាលណាមានការលំបាកនៅក្នុងកាយ, មានសេចក្តីមិនសប្បាយ, មានការឈឺចុកចាប់ ដែលបណ្តាលមកពីកាយសម្ផស្ស គឺ ការប៉ះពាល់តាមផ្លូវកាយ, ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ! ចុះដូចម្តេចហៅថាទោមនស្សៈ (សេចក្តីអាក់អន់ចិត្ត)(30) ?

សេចក្តីអាក់អន់ចិត្ត, សេចក្តីមិនសប្បាយចិត្ត, សេចក្តីលំបាកដែលបណ្តាលមកអំពីមនោសម្ផស្ស, ការប៉ះពាល់តាមផ្លូវចិត្ត, ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថា ទោមនស្ស។

កតមោ ច ភិក្ខវេ ឧបាយាសោ ?

យោ ខោ ភិក្ខវេ, អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ, ភិក្ខវេ, ឧបាយាសោ ។

កតមោ ច ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ?

ឥធ យស្ស តេ ហោន្តិ អនិដ្ឋា អកន្តា អមនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា, យេ វា បនស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកកាមា អយោគក្ខេមកាមា, យា តេហិ សទ្ធិំ សង្គតិ សមាគមោ សមោធានំ មិស្សីភាវោ, អយំ វុច្ចតិ, ភិក្ខវេ, អប្បិយេហិ សម្បយោគោ ទុក្ខោ ។

កតមោ ច ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ ?

ឥធ យស្ស តេ ហោន្តិ ឥដ្ឋា កន្តា មនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា យេ វា បនស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា មិត្តា វា អមច្ចា វា ញាតិសាលោហិតា វា, យា តេហិ អសង្គតិ អសមាគមោ អសមោធានំ អមិស្សីភាវោ, អយំ វុច្ចតិ ភិក្ខវេ, បិយេហិ វិប្បយោគោ ទុក្ខោ ។

ម្នាលភិក្ខុទាំងឡាយ,ចុះដូចម្ដេចហៅថាឧបាយាស (សេចក្ដីចង្អៀតចង្អល់ចិត្ត)?

កាលណាគេជួបប្រទះនឹងការបាត់បង់ ឬ អពមង្គលផ្សេងៗដែលនាំឱ្យមានសេចក្ដីព្រួយចិត្តបែបណាមួយ,ភាពតានតឹងនៅក្នុងចិត្ត, សេចក្ដីចង្អៀតចង្អល់ចិត្ត, សេចក្ដីខ្លោចផ្សាចិត្ត, ភាពនៃការតានតឹងនិងសេចក្ដីចង្អៀតចង្អល់នៅក្នុងចិត្ត ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថា ឧបាយាសៈ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្ដេចហៅថាអប្បិយេហិសម្បយោគទុក្ខោ ឬ ទុក្ខដោយការជួបប្រសព្វជាមួយនឹងរបស់មិនចូលចិត្ត ? នៅទីណានិងនៅពេលណាគេជួបប្រទះនឹងរូបារម្មណ៍ (រូបភាព ),សទ្ទារម្មណ៍ (សម្លេង),គន្ធារម្មណ៍ (ក្លិន),រសារម្មណ៍(រសជាតិ ),ផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ),ធម្មារម្មណ៍(ធម៌),រូប,សម្លេង,ក្លិន,រស,សម្ផស្ស,ឬធម្មារម្មណ៍ដែលមិនជាទីប្រាថ្នា, មិនជាទីត្រេកអរ,មិនជាទីគាប់ចិត្ត ពុំនោះសោត នៅទីណានិងនៅពេលណាគេជួបប្រទះនឹងជនទាំងឡាយណាដែលប្រាថ្នាឱ្យគេមានអពមង្គល,សេចក្ដីឈឺចាប់,សេចក្ដីលំបាកផ្សេងៗ ឬ ឱ្យគេមានអសន្តិសុខ, ការដែលជួបប្រសព្វ,ជួបប្រទះ, ជួបទាក់ទងនៅប្រឡូកប្រឡំជាមួយនឹងអារម្មណ៍ឬជនទាំងឡាយនោះ, ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថា អប្បិយេហិសម្បយោគទុក្ខោ ឬ ទុក្ខដោយការជួបប្រសព្វជាមួយនឹងរបស់មិនចូលចិត្ត ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្ដេចហៅថាបិយេហិ វិប្បយោគទុក្ខោ ឬទុក្ខដោយការព្រាត់ប្រាសអំពីរបស់ដែលស្រឡាញ់ចូលចិត្ត ? នៅទីណានិងនៅពេលណាគេមិនជួបប្រទះនឹងរូបារម្មណ៍(រូបភាព),សទ្ទារម្មណ៍ (សម្លេង),គន្ធារម្មណ៍ (ក្លិន),រសារម្មណ៍(រសជាតិ),ផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ),ធម្មារម្មណ៍(ធម៌),រូប,សម្លេង,ក្លិន,រស,សម្ផស្សឬធម្មារម្មណ៍ដែលជាទីប្រាថ្នា,ជាទីត្រេកអរ,ជាទីគាប់ចិត្ត, ពុំនោះសោត នៅទីណានិងនៅពេលណាគេជួបប្រទះនឹងជនទាំងឡាយណាដែលប្រាថ្នាឱ្យគេមានសុភមង្គល,មានភាពរុងរឿង,មានសេចក្ដីសុខនិងមានសេចក្ដីចំរើន,សេចក្ដីក្សេមក្សាន្ត ដូចជាមាតានិងបិតាក្ដី,បងប្អូនប្រុសនិងបងប្អូនស្រីក្ដី,មិត្តភក្តិនិងសហសេវិកក្ដី,ឬញាតិសាលោហិតក្ដី, កាលណាគេត្រូវព្រាត់ប្រាស,មិនបានជួប,មិនបានប្រាស្រ័យទាក់ទងគ្នា ឬក៏មិនបាននៅប្រឡូកប្រឡំជាមួយនឹងអារម្មណ៍ឬជនទាំងឡាយនោះ,ម្នាលភិក្ខុទាំងឡាយ, នេះហើយហៅថាបិយេហិវិប្បយោគទុក្ខោ ឬទុក្ខដោយការព្រាត់ប្រាសអំពីរបស់ដែលស្រឡាញ់ចូលចិត្ត ។

កតមញ្ច ភិក្ខវេ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ?

ជាតិធម្មានំ, ភិក្ខវេ, សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ : «អហោ វត មយំ ន ជាតិធម្មា អស្សាម ន ច វត នោ ជាតិ អាគច្ឆេយ្យា»តិ ។ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ។ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។

ជរាធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ : «អហោ វត មយំ ន ជរាធម្មា អស្សាម ន ច វត នោ ជរា អាគច្ឆេយ្យា» តិ ។ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ។ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។

ព្យាធិធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ : «អហោ វត មយំ ន ព្យាធិធម្មា អស្សាម ន ច វត នោ ព្យាធិ អាគច្ឆេយ្យា» តិ ។ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ។ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។

មរណធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ : «អហោ វត មយំ ន មរណធម្មា អស្សាម ន ច វត នោ មរណំ អាគច្ឆេយ្យា» តិ ។ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ។ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថា យម្បិច្ឆំ ន លភតិ តម្បិទុក្ខំ ឬទុក្ខដោយការចង់បានរបស់ណា ហើយមិនបានរបស់នោះ ?

ម្នាយភិក្ខុទាំងឡាយ, ពួកសត្វដែលមាន ជាតិកំណើត ជាធម្មតាតែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា : ធ្វើដូចម្តេចហ្ន៎ កុំឱ្យយើងទាំងឡាយមានជាតិកំណើតជាធម្មតា ? ពុំនោះសោតធ្វើដូចម្តេចហ្ន៎ កុំឱ្យជាតិកំណើតកើតមានដល់យើងទាំងឡាយ ? តែពួកសត្វមិនអាចសំរេចសេចក្តីប្រាថ្នានេះបានដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ. ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ, ពួកសត្វដែលមាន ជរា គឺសេចក្តីចាស់គ្រាំគ្រាជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា : ធ្វើដូចម្តេចហ្ន៎ កុំឱ្យយើងទាំងឡាយមានជរាជាធម្មតា ? ពុំនោះសោតធ្វើម្តេចហ្ន៎ កុំឱ្យជរា កើតមានដល់យើងទាំងឡាយ ? តែពួកសត្វមិនអាចសំរេចសេចក្តីប្រាថ្នានេះបានដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ. ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ, ពួកសត្វដែលមាន ព្យាធិ គឺជម្ងឺជាធម្មតាតែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា : ធ្វើដូចម្តេចហ្ន៎ កុំឱ្យយើងទាំងឡាយមានជម្ងឺជាធម្មតា ? ពុំនោះសោតធ្វើដូចម្តេចហ្ន៎ កុំឱ្យជម្ងឺ កើតមានដល់យើងទាំងឡាយ ? តែពួកសត្វមិនអាចសំរេចសេចក្តីប្រាថ្នានេះបានដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ. ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ, ពួកសត្វដែលមានមរណៈ គឺសេចក្តីស្លាប់ជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា : ធ្វើដូចម្តេចហ្ន៎ កុំឱ្យយើងទាំងឡាយមានសេចក្តីស្លាប់ជាធម្មតា ? ពុំនោះសោត,ធ្វើដូចម្តេចហ្ន៎ កុំឱ្យសេចក្តីស្លាប់កើតមានដល់យើងទាំងឡាយ ? តែពួកសត្វមិនអាចសំរេចសេចក្តីប្រាថ្នានេះបាន ដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ. ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បាននុ៎ះ ជាទុក្ខ ។

សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មានំ ភិក្ខវេ, សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ «អហោ វត មយំ ន សោកបរិទេវទុក្ខទោមនស្សុបា-យាសធម្មា អស្សាម ន ច វត នោ សោកបរិទេវទុក្ខទោមនស្សុបា-យាសធម្មា អាគច្ឆេយ្យុន្តិ» ។ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ។ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។

កតមេ ច ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ?

សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ។ ឥមេ វុច្ចន្តិ, ភិក្ខវេ, សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។

ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។

ម្នាលភិក្ខុទាំងឡាយ. ពួកសត្វដែលមានសេចក្តីស្តាយស្រណោះ, សេចក្តីខ្សឹកខ្សួល, សេចក្តីលំបាកកាយ, សេចក្តីអាក់អន់ចិត្ត ឬសេចក្តីចង្អៀតចង្អល់ចិត្ត តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា : ធ្វើដូចម្តេចហ្ន៎ កុំឱ្យយើងទាំងឡាយមានសេចក្តីស្តាយស្រណោះ, សេចក្តីខ្សឹកខ្សួល, សេចក្តីលំបាកកាយ, សេចក្តីអាក់អន់ចិត្តឬសេចក្តីចង្អៀតចង្អល់ចិត្ត ? កុំនោះសោត : ធ្វើដូចម្តេចហ្ន៎ កុំឱ្យសេចក្តីស្តាយស្រណោះ, សេចក្តីខ្សឹកខ្សួល, សេចក្តីលំបាកកាយ, សេចក្តីអាក់អន់ចិត្តឬសេចក្តីចង្អៀតចង្អល់ចិត្តកើតមានដល់យើងទាំងឡាយ ? តែពួកសត្វមិនអាចសំរេចសេចក្តីប្រាថ្នានេះបាន ដោយគ្រាន់តែប្រាថ្នាទទេៗនោះកើតឡើយ. ហើយការមិនបានរបស់ដែលគេប្រាថ្នាចង់បានទុះ ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅដោយសង្ខេបថា បញ្ចុបាទានក្ខន្ធាទុក្ខា គឺការប្រកាន់ខ្ជាប់ទៅលើខន្ធ៥នោះជាទុក្ខ ? សេចក្តីនេះមានដូចតទៅ : ការប្រកាន់ខ្ជាប់ទៅលើរូបក្ខន្ធជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើវេទនាខន្ធជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើសញ្ញាខន្ធជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើសង្ខារក្ខន្ធជាទុក្ខ, ការប្រកាន់ខ្ជាប់ទៅលើវិញ្ញាណក្ខន្ធជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ, នេះជាទុក្ខដោយការប្រកាន់ខ្ជាប់ទៅលើខន្ធ៥ ។

ម្នាលភិក្ខុទាំងឡាយ, នេះហើយគឺ ទុក្ខអរិយសច្ចំ គឺសេចក្តីពិតអំពីទុក្ខ ។

# សមុទយសច្ចំ

កតមញ្ច ភិក្ខវេ ទុក្ខសមុទយំ អរិយសច្ចំ ?

យាយំ តណ្ហា បោនោព្ភវិកា នន្ទីរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថិទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។

សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ ?

យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។

# សេចក្តីពិតអំពីមូលហេតុរបស់ទុក្ខ

ម្នាលភិក្ខុទាំងឡាយ !ចុះដូចម្តេចហៅថាសេចក្តីពិតអំពីមូលហេតុរបស់ទុក្ខ ? គឺ តណ្ហា សេចក្តីប្រាថ្នាចង់បាននេះ. ដែលជាធម្មជាតិនាំសត្វឱ្យមានកំណើតជាថ្មីទៀត ប្រកបដោយតម្រេករីករាយនិងសេចក្តីត្រេកត្រអាលនៅទីនេះ. រួចហើយ នៅទីនោះតទៅទៀត. គឺ : កាមតណ្ហា សេចក្តីប្រាថ្នាក្នុង កាមគុណ. ភវតណ្ហា សេចក្តីប្រាថ្នាក្នុង ជាតិកំណើត ជាថ្មីទៀត. វិភវតណ្ហា សេចក្តីប្រាថ្នាក្នុងភាពសូន្យ ។

ម្នាលភិក្ខុទាំងឡាយ. ចុះតណ្ហានេះកើតនៅទីណាហើយតាំងនៅនៅទីណា ?

ក្នុងលោកនេះ ទោះនៅទីណាក៏ដោយ ដរាបណាមានរបស់គួរជាទីស្រឡាញ់. គួរជាទីរីករាយ. ដរាបនោះតណ្ហាកើតឡើង ហើយតាំងនៅត្រង់ទីនោះឯង ។

កិញ្ច លោកេ (31) បិយរូបំ សាតរូបំ ?

ចក្ខុំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សោតំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ឃានំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ជិវ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ កាយោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ មនោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានោ ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។

រូបា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សទ្ទា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ គន្ធា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រសា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧបជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ផោដ្ឋព្វា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ធម្មា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។

ចុះក្នុងលោកនេះ *(31)* តើមានរបស់អ្វីដែលគួរជាទីស្រឡាញ់, គួរជាទីរីករាយ ? ភ្នែកជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុះ ។ ត្រចៀកជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុះ ។ ច្រមុះជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។ អណ្តាត ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុះ ។ កាយជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។ ចិត្តជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។

រូបារម្មណ៍(រូប) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុះ ។ សទ្ទារម្មណ៍ (សម្លេង) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។ គន្ធារម្មណ៍ (ក្លិន) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។ រសារម្មណ៍ (រសជាតិ) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។ ផោដ្ឋព្វារម្មណ៍ (ការប៉ះពាល់ត្រូវដោយកាយ) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។ ធម្មារម្មណ៍ (ធម៌) ជារបស់គួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយ ដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុះ ។

ចក្ខុវិញ្ញាណំ (32) លោកេ បិយរូបំ, សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សោតវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ឃានវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ជិវ្ហាវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ កាយវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ និវិសមានា និវិសតិ ។ មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។

ចក្ខុសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ. ឯត្ថ និវិសមានា និវិសតិ ។ សោតសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ឃានសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ជិវ្ហាសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ កាយសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។

ចក្ខុវិញ្ញាណ (32) ការប៉ះរបស់ភ្នែកមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោកគឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សោតវិញ្ញាណ ការប៉ះរបស់ត្រចៀក មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ឃានវិញ្ញាណ ការប៉ះរបស់ច្រមុះ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ជិវ្ហាវិញ្ញាណ ការប៉ះរបស់អណ្តាត មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយ, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។ កាយវិញ្ញាណ ការប៉ះរបស់កាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ។ មនោវិញ្ញាណ ការប៉ះរបស់ចិត្ត មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

ចក្ខុសម្ផស្ស (ការប៉ះរបស់ភ្នែក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយ នៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សោតសម្ផស្ស (ការប៉ះរបស់ត្រចៀក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ឃានសម្ផស្ស (ការប៉ះរបស់ច្រមុះ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ជិវ្ហាសម្ផស្ស (ការប៉ះរបស់អណ្តាត) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយ, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ កាយសម្ផស្ស (ការប៉ះរបស់កាយ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ មនោសម្ផស្ស (ការប៉ះរបស់ចិត្ត) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

ចក្ខុសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ សោតសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ឃានសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ជិវ្ហាសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ កាយសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។

រូបសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ សទ្ទសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ គន្ធសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រសសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ផោដ្ឋព្វសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។

វេទនាកើតមកពីចក្ខុសម្ផស្ស(ការប៉ះរបស់ភ្នែក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ វេទនាកើតមកពីសោតសម្ផស្ស (ការប៉ះរបស់ត្រចៀក ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ វេទនាកើតមកពីឃានសម្ផស្ស(ការប៉ះរបស់ច្រមុះ ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើង ហើយតាំងនៅត្រង់នុ៎ះ ។ វេទនាកើតមកពីជិវ្ហាសម្ផស្ស (ការប៉ះរបស់អណ្តាត )មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ វេទនាកើតមកពីកាយសម្ផស្ស (ការប៉ះរបស់កាយ )មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ វេទនាកើតមកពីមនោសម្ផស្ស(ការប៉ះរបស់ចិត្ត)មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

សញ្ញាសំគាល់នូវរូបារម្មណ៍(រូប)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សញ្ញាសំគាល់នូវ សទ្ទារម្មណ៍(សម្លេង) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សញ្ញាសំគាល់នូវ គន្ធារម្មណ៍(ក្លិន) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សញ្ញាសំគាល់នូវ រសារម្មណ៍(រសជាតិ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សញ្ញាសំគាល់នូវផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សញ្ញាសំគាល់នូវ ធម្មារម្មណ៍ (ធម៌)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

រូបសញ្ចេតនា (32a)លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សទ្ទសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ គន្ធសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ រសសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ផោដ្ឋព្វសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។

រូបតណ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សទ្ទតណ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ គន្ធតណ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ រសតណ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ផោដ្ឋព្វតណ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។

ចិត្តដែលធ្វើប្រតិកម្ម(32a) ចំពោះរូបារម្មណ៍(រូប) ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ សទ្ទារម្មណ៍ (សម្លេង) ទាំងឡាយមានភាពគួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ គន្ធារម្មណ៍ (ក្លិន) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះរសារម្មណ៍ (រសជាតិ) ទាំងឡាយ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ ផោដ្ឋព្វារម្មណ៍ (ការប៉ះពាល់ត្រូវដោយកាយ) ទាំងឡាយ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ ធម្មារម្មណ៍ (ធម៌) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

សេចក្តីប្រាថ្នាចំពោះរូបារម្មណ៍(រូប) ទាំងឡាយ មានភាពគួរជាទីស្រឡាញ់, គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីប្រាថ្នាចំពោះសទ្ទារម្មណ៍ (សម្លេង) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីប្រាថ្នាចំពោះ គន្ធារម្មណ៍ (ក្លិន) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីប្រាថ្នាចំពោះរសារម្មណ៍ (រសជាតិ) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីប្រាថ្នាចំពោះផោដ្ឋព្វារម្មណ៍ (ការប៉ះពាល់ត្រូវដោយកាយ) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីប្រាថ្នាចំពោះធម្មារម្មណ៍(ធម៌) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

រូបវិតក្កោ (33) លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សទ្ទវិតក្កោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ គន្ធវិតក្កោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ រសវិតក្កោ លោកេ បិយរូបំ, សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ផោដ្ឋព្វវិតក្កោ លោកេ បិយរូបំ, សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។

រូបវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ សទ្ទវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ គន្ធវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ រសវិចារោ លោកេ បិយរូបំ, សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ផោដ្ឋព្វវិចារោ លោកេ បិយរូបំ, សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថ និវិសមានា និវិសតិ ។ ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ, ឯត្ថនិវិសមានា និវិសតិ ។

ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយំ អរិយសច្ចំ ។

សេចក្តីនឹកភ្នកអំពីរូបារម្មណ៍(រូប)ទាំងឡាយ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីនឹកភ្នកអំពីសទ្ទារម្មណ៍ (សម្លេង )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីនឹកភ្នកអំពីគន្ធារម្មណ៍ (ក្លិន )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីនឹកភ្នកអំពីរសារម្មណ៍ (រសជាតិ )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ សេចក្តីនឹកភ្នកអំពីផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

ការវិលវល់ក្នុងរូបារម្មណ៍(រូប)ទាំងឡាយ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ការវិលវល់ក្នុង សទ្ទារម្មណ៍ (សម្លេង )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ការវិលវល់ក្នុង គន្ធារម្មណ៍ (ក្លិន )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ការវិលវល់ក្នុង រសារម្មណ៍ (រសជាតិ )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។ ការវិលវល់ក្នុង ផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលតណ្ហាកើតឡើងហើយតាំងនៅត្រង់នុ៎ះ ។

ម្នាលភិក្ខុទាំងឡាយ នេះគឺ ទុក្ខសមុទយំ អរិយសច្ចំ,សេចក្តីពិតអំពីមូលហេតុរបស់ទុក្ខ ។

## និរោធសច្ចំ

កតមញ្ច ភិក្ខវេ ទុក្ខនិរោធំ អរិយសច្ចំ ?

យោ តស្សា យេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ បហីយមានា បហីយតិ, កត្ថ និរុជ្ឈមានា និរុជ្ឈតិ ?
យំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

កិញ្ច លោកេ បិយរូបំ សាតរូបំ ?

ចក្ខុ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សោតំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ឃានំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ជិវ្ហា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ កាយោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ មនោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

# សេចក្តីពិតអំពីការរលត់ទុក្ខ

ម្នាលភិក្ខុទាំងឡាយ. ចុះដូចម្តេចហៅថាសេចក្តីពិតអំពីការរលត់ទុក្ខ ? គឺការរលត់ចាត់ទាំងស្រុងគ្មានសេសសល់នៃតណ្ហានេះឯង.ការលះបង់និងការលះបង់ចោលទាំងស្រុងនូវតណ្ហានេះ ការរួចរំដោះនិងការផ្តាច់ចេញស្រឡះពីតណ្ហានេះ ។ ម្នាលភិក្ខុទាំងឡាយ.តើគេអាចរំលត់និងកំចាត់បង់នូវតណ្ហានេះនៅទីណា ? នៅក្នុងលោកនេះ ទោះនៅទីណាក៏ដោយ ដរាបណានៅមានរបស់គួរជាទីស្រឡាញ់.គួរជាទីរីករាយ ដរាបនោះគេអាចរំលត់និងកំចាត់នូវតណ្ហានេះនៅត្រង់ទី នោះឯង ។

តែនៅក្នុងលោក(នៃចិត្តនិងរូប)នេះ តើមានអ្វីដែលគួរជាទីស្រឡាញ់គួរជាទីរីករាយ? ភ្នែកជារបស់មានភាពគួរជាទីស្រឡាញ់.គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ត្រចៀកជារបស់មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយ ដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ច្រមុះជារបស់មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ អណ្តាតជារបស់មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ។ កាយជារបស់មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ចិត្តជារបស់មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងឯងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

រូបា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សទ្ទា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ គន្ធា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រសា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ផោដ្ឋព្វា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ធម្មា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

ចក្ខុវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សោតវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ឃានវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ជិវ្ហាវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ កាយវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

• រូបារម្មណ៍ (រូប) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សទ្ទារម្មណ៍ (សម្លេង) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ គន្ធារម្មណ៍ (ក្លិន) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ រសារម្មណ៍ (រសជាតិ) ទាំងឡាយ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ផោដ្ឋព្វារម្មណ៍ (ការប៉ះពាល់ត្រូវដោយកាយ) ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ធម្មារម្មណ៍ (ធម៌ ) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

ចក្ខុវិញ្ញាណ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សោតវិញ្ញាណ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ឃានវិញ្ញាណ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ជិវ្ហាវិញ្ញាណ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ កាយវិញ្ញាណ មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ មនោវិញ្ញាណ មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

ចក្ខុសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សោតសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ឃានសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ជិវ្ហាសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ កាយសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

ចក្ខុសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សោតសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ឃានសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ជិវ្ហាសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ កាយសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

ចក្ខុសម្ផស្ស (ការប៉ះរបស់ភ្នែក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សោតសម្ផស្ស (ការប៉ះរបស់ត្រចៀក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ឃានសម្ផស្ស (ការប៉ះរបស់ច្រមុះ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ជិវ្ហាសម្ផស្ស (ការប៉ះរបស់អណ្តាត) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ កាយសម្ផស្ស (ការប៉ះរបស់កាយ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ មនោសម្ផស្ស (ការប៉ះរបស់ចិត្ត) មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

វេទនាកើតមកអំពីចក្ខុសម្ផស្ស(ការប៉ះរបស់ភ្នែក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ វេទនាកើតមកអំពីសោតសម្ផស្ស (ការប៉ះរបស់ត្រចៀក) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ វេទនាកើតមកអំពី ឃានសម្ផស្ស (ការប៉ះរបស់ច្រមុះ) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ។ វេទនាកើតមកអំពីជិវ្ហាសម្ផស្ស(ការប៉ះរបស់អណ្តាត) មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ វេទនាកើតមកអំពី កាយសម្ផស្ស (ការប៉ះរបស់កាយ) មានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ វេទនាកើតមកអំពីមនោសម្ផស្ស (ការប៉ះរបស់ចិត្ត) មានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

រូបសញ្ញា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សទ្ទសញ្ញា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ គន្ធសញ្ញា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រសសញ្ញា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ផោដ្ឋព្វសញ្ញា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

រូបសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សទ្ទសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ គន្ធសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រសសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ផោដ្ឋព្វសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

សញ្ញាសំគាល់នូវរូបារម្មណ៍(រូប)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សញ្ញាសំគាល់នូវ សទ្ទារម្មណ៍ (សម្លេង )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សញ្ញាសំគាល់នូវ គន្ធារម្មណ៍(ក្លិន)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សញ្ញាសំគាល់នូវរសារម្មណ៍(រសជាតិ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក .គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សញ្ញាសំគាល់នូវផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សញ្ញាសំគាល់នូវ ធម្មារម្មណ៍(ធម៌)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

ចិត្តដែលធ្វើប្រតិកម្ម (32a) ចំពោះរូបារម្មណ៍ (រូប )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ សទ្ទារម្មណ៍(សម្លេង )ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ គន្ធារម្មណ៍(ក្លិន)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះរសារម្មណ៍(រសជាតិ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយ. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ ) ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ ចិត្តដែលធ្វើប្រតិកម្មចំពោះ ធម្មា-រម្មណ៍(ធម៌)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក.គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

រូបតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សទ្ទតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ គន្ធតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រសតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ផោដ្ឋព្វតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

រូបវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សទ្ទវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ គន្ធវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រសវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ផោដ្ឋព្វវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

*សេចក្តីពិតអំពីការរលត់ទុក្ខ*

សេចក្តីប្រាថ្នាចំពោះ រូបារម្មណ៍(រូប)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីប្រាថ្នាចំពោះសទ្ទារម្មណ៍(សម្លេង)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីប្រាថ្នាចំពោះគន្ធារម្មណ៍(ក្លិន)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីប្រាថ្នាចំពោះរសារម្មណ៍ (រសជាតិ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក .គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីប្រាថ្នាចំពោះផោដ្ឋព្វារម្មណ៍ (ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីប្រាថ្នាចំពោះធម្មារម្មណ៍ (ធម៌)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

សេចក្តីនឹកភ្នកអំពីរូបារម្មណ៍(រូប)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីនឹកភ្នកអំពីសទ្ទារម្មណ៍(សម្លេង )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីនឹកភ្នកអំពីគន្ធារម្មណ៍(ក្លិន)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីនឹកភ្នកអំពីរសារម្មណ៍ (រសជាតិ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក .គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីនឹកភ្នកអំពីផោដ្ឋព្វារម្មណ៍ (ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្តីនឹកភ្នកអំពី ធម្មារម្មណ៍ (ធម៌)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

រូបវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សទ្ទវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ គន្ធវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រសវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ផោដ្ឋព្វវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ, ឯត្ថេសា តណ្ហា បហីយមានា បហីយតិ, ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។

ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធំ អរិយសច្ចំ ។

*សេចក្ដីពិតអំពីការរលត់ទុក្ខ*

សេចក្ដីរីករាយក្នុងរូបារម្មណ៍(រូប)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក,គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្ដីរីករាយក្នុងសទ្ទារម្មណ៍(សម្លេង )ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក, គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្ដីរីករាយក្នុងគន្ធារម្មណ៍(ក្លិន)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្ដីរីករាយក្នុងរសារម្មណ៍ (រសជាតិ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក .គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្ដីរីករាយក្នុងផោដ្ឋព្វារម្មណ៍(ការប៉ះពាល់ត្រូវដោយកាយ)ទាំងឡាយមានភាពគួរជាទីស្រឡាញ់ គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។ សេចក្ដីរីករាយក្នុង ធម្មារម្មណ៍(ធម៌)ទាំងឡាយមានភាពគួរជាទីស្រឡាញ់គួរជាទីរីករាយនៅក្នុងលោក. គឺនៅត្រង់ហ្នឹងហើយដែលគេអាចរំលត់និងកំចាត់តណ្ហានេះ ។

ម្នាលភិក្ខុទាំងឡាយ. នេះគឺ ទុក្ខនិរោធអរិយសច្ចំ. សេចក្ដីពិតអំពីការរលត់ទុក្ខ ។

# មគ្គសច្ចំ

កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ? អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។

កតមា ច ភិក្ខវេ សម្មាទិដ្ឋិ ? យំ ខោ ភិក្ខវេ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាទិដ្ឋិ ។

កតមោ ច ភិក្ខវេ សម្មាសង្កប្បោ ? នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសា សង្កប្បោ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសង្កប្បោ ។

កតមា ច ភិក្ខវេ សម្មាវាចា ? មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី ។ អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា ។

# សេចក្ដីពិតអំពីមាគ៌ា ( ផ្លូវប្រតិបត្តិ )

ម្នាលភិក្ខុទាំងឡាយ. ចុះដូចម្ដេចហៅថាសេចក្ដីពិតអំពីមាគ៌ាឆ្ពោះទៅរកការរលត់ទុក្ខ ? គឺជាមាគ៌ាដ៏ប្រសើរប្រកបដោយអង្គ៨នេះឯងគឺ : ការយល់ឃើញត្រូវ, ការត្រិះរិះត្រូវ, ការប្រើសំដីត្រូវ, ការប្រកបការងារត្រូវ, ការចិញ្ចឹមជីវិតត្រូវ, ការព្យាយាមត្រូវ, ការតាំងសតិដឹងត្រូវ, ការដំកល់ចិត្តឱ្យមូលត្រូវ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្ដេចហៅថា : ការយល់ឃើញត្រូវ ? គឺការដឹងច្បាស់នូវទុក្ខ ការដឹងច្បាស់នូវមូលហេតុនៃទុក្ខ, ការដឹងច្បាស់នូវហេតុផលនៃការរលត់ទុក្ខ, ការដឹងច្បាស់នូវមាគ៌ាឆ្ពោះទៅរកការរលត់ទុក្ខ, ម្នាលភិក្ខុទាំងឡាយនេះហើយដែលហៅថា ការយល់ឃើញត្រូវ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្ដេចហៅថាការត្រិះរិះត្រូវ ? គឺការត្រិះរិះដើម្បីលះបង់កាមគុណ, ការត្រិះរិះដើម្បីប្រាសចាកការព្យាបាទ, ការត្រិះរិះដើម្បីប្រាសចាកការប្រើកម្លាំងឃោរឃៅ គឺការមិនបៀតបៀនអ្នកដទៃ ។ ម្នាលភិក្ខុទាំងឡាយ, នេះហើយដែលហៅថាការត្រិះរិះត្រូវ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្ដេចហៅថាការប្រើសំដីត្រូវ ? កិរិយាវៀរចាកការពោលនូវពាក្យកុហក, កិរិយាវៀរចាកការនិយាយបង្កាច់និងនិយាយដើមគេ គឺកិរិយាវៀរចាកការនិយាយញុះញង់ធ្វើឱ្យគេបែកបាក់សាមគ្គី, កិរិយាវៀរចាកការពោលពាក្យគ្រោះគោះបោក, និងកិរិយាវៀរចាកការនិយាយពាក្យរោយរាយឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ, នេះហើយដែលហៅថា ការប្រើសំដីត្រូវ ។

កតមោ ច ភិក្ខវេ សម្មាកម្មន្តោ ? បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុមិច្ឆាចារា វេរមណី ។ អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ ។

កតមោ ច ភិក្ខវេ សម្មាអាជីវោ ? ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាអាជីវោ ។

កតមោ ច ភិក្ខវេ សម្មាវាយាមោ ? ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាវាយាមោ ។

★- ក្បួនមាន 10 [illegible] ។

★- វិនាស 12 [illegible] ។

★- [illegible] 16 [illegible] ។.

ម្នាលភិក្ខុទាំងឡាយ.ចុះដូចម្តេចហៅថា ការប្រកបការងារត្រូវ ? កិរិយាវៀរចាកការសម្លាប់សត្វ. កិរិយាវៀរចាកការយករបស់ដែលម្ចាស់គេមិនបានឱ្យ.និងកិរិយាវៀរចាកការប្រព្រឹត្តិខុសក្នុងកាម. ម្នាលភិក្ខុទាំងឡាយ.នេះហើយហៅថា ការប្រកបការងារត្រូវ ។

ម្នាលភិក្ខុទាំងឡាយ.ចុះដូចម្តេចហៅថា ការចិញ្ចឹមជីវិតត្រូវ ? ក្នុងទីនេះគឺ អរិយ.សាវកដែលបានលះបង់ការចិញ្ចឹមជីវិតខុសហើយរស់នៅដោយការចិញ្ចឹមជីវិតត្រូវ. ម្នាលភិក្ខុទាំងឡាយ. នេះហើយហៅថា ការចិញ្ចឹមជីវិតត្រូវ ។

ម្នាលភិក្ខុទាំងឡាយ.ចុះដូចម្តេចហៅថា ការព្យាយាមត្រូវ ? ក្នុងទីនេះភិក្ខុញ៉ាំងឆន្ទៈឱ្យកើតឡើង ប្រឹងប្រែងទំព្រារព្ធព្យាយាម.ផ្គងចិត្តតាំងព្យាយាមយ៉ាងមាំដើម្បីការពារអកុសលធម៌ទាំងឡាយដែលមិនទាន់កើត កុំឱ្យកើតឡើងបាន ។ ភិក្ខុញ៉ាំងឆន្ទៈឱ្យកើតឡើងប្រឹងប្រែងទំព្រារព្ធព្យាយាមផ្គងចិត្តតាំងព្យាយាមយ៉ាងមាំដើម្បីកំចាត់បង់នូវអកុសលធម៌ទាំងឡាយដែលបានកើតរួចមកហើយ ។ ភិក្ខុញ៉ាំងឆន្ទៈឱ្យកើតឡើងប្រឹងប្រែងទំព្រារព្ធព្យាយាមផ្គងចិត្តតាំងព្យាយាមយ៉ាងមាំដើម្បីញ៉ាំងកុសលធម៌ទាំងឡាយដែលមិនទាន់កើតមានឱ្យកើតមានឡើង ។ ភិក្ខុញ៉ាំងឆន្ទៈឱ្យកើតឡើងប្រឹងប្រែងទំព្រារព្ធព្យាយាមផ្គងចិត្តតាំងព្យាយាមយ៉ាងមាំដើម្បីញ៉ាំងកុសលធម៌ទាំងឡាយដែលបានកើតរួចមកហើយឱ្យស្ថិតស្ថេរចិរកាល ឱ្យរីកចំរើនពេញបរិបូណ៌ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយ.នេះហើយដែលហៅថាសេចក្តី ព្យាយាមត្រូវ ។

កតមោ ច ភិក្ខវេ សម្មាសតិ ? ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ. វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ. ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ. ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ ។

កតមោ ច ភិក្ខវេ សម្មាសមាធិ ? ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ, វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ, វិហរតិ, បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខំ ច កាយេន បដិសំវេទេតិ យំ តំ អរិយា អាចិក្ខន្តិ : «ឧបេក្ខកោ សតិមា សុខវិហារី» តិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ, សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ ។

ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។

ម្នាលភិក្ខុទាំងឡាយ,ដូចម្តេចហៅថាសតិដឹងត្រូវ ?ក្នុងទីនេះភិក្ខុតាំងនៅស៊ប់ប្រកបដោយសតិដឹងនិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង, ពិនិត្យមើលកាយក្នុងកាយ ដោយបានកំចាត់ចោលនូវលោភៈនិងទោសៈចំពោះរបស់ក្នុងលោកនេះ,ភិក្ខុតាំងនៅប្រកបដោយសតិដឹងនិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង,ពិនិត្យមើលវេទនាក្នុងវេទនាទាំងឡាយ ដោយបានកំចាត់ចោលនូវ លោភៈនិងទោសៈចំពោះរបស់ក្នុងលោកនេះ, ភិក្ខុតាំងនៅប្រកបដោយសតិដឹងនិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ពិនិត្យមើលចិត្តក្នុងចិត្តទាំងឡាយ ដោយបានកំចាត់ចោលនូវលោភៈនិងទោសៈចំពោះរបស់ក្នុងលោកនេះ, ភិក្ខុតាំងនៅប្រកបដោយសតិដឹងនិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយ ដោយបានកំចាត់ចោលនូវលោភៈនិងទោសៈចំពោះរបស់ក្នុងលោកនេះ ។

ម្នាលភិក្ខុទាំងឡាយ,នេះហើយដែលហៅថា សតិដឹង ត្រូវ ។

ម្នាលភិក្ខុទាំងឡាយ, ចុះដូចម្តេចហៅថា ការដំកល់ចិត្តឱ្យនឹងត្រូវ ? ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះភិក្ខុបានរួចចាកកាមទាំងឡាយ,បានរួចចាកអកុសលធម៌ទាំងឡាយរួចចូលទៅកាន់ បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ,មានបីតិនិងសេចក្តីសុខដែលកើតមកអំពីសេចក្តីស្ងប់ស្ងាត់ហើយក៏តាំងនៅក្នុងបឋមជ្ឈាននេះ ។ លុះវិតក្កៈនិងវិចារៈបានរម្ងាប់ហើយ ភិក្ខុក៏ចូលទៅកាន់ទុតិយជ្ឈាន ដោយមានសេចក្តីស្ងប់ស្ងាត់នៅខាងក្នុងនិងសភាពជាចិត្តខ្ពស់ឯកគ្មានវិតក្កៈ,គ្មានវិចារៈមានតែបីតិនិងសេចក្តីសុខដែលកើតមកអំពីសមាធិចិត្ត ហើយក៏តាំងនៅក្នុងទុតិយជ្ឈាននេះ ។ លុះបីតិចិត្តបានរម្ងាប់ហើយភិក្ខុតាំងនៅក្នុងភាពឧបេក្ខាដោយមានសតិដឹងពេញបរិបូណ៌ចំពោះវេទនានិងការយល់ច្បាស់ជាប់ជានិច្ចអំពី សេចក្តីមិនទៀងហើយពិសោធឃើញសេចក្តីសុខតែម្យ៉ាងនៅក្នុងខ្លួន ដែលព្រះអរិយបុគ្គលសំដែងថា «មានតែបុគ្គលដែលប្រកបដោយភាពឧបេក្ខានិងសតិដឹងទេ ដែលអាចពិសោធឃើញសេចក្តីសុខនេះ», ភិក្ខុចូលទៅកាន់តតិយជ្ឈាន ហើយតាំងនៅក្នុង តតិយជ្ឈាន នេះ ។ លុះបានរម្ងាប់សេចក្តីសុខនិងទុក្ខ,ហើយដោយសេចក្តីសោមនស្សនិងទោមនស្សក៏បានរលាយបាត់អស់ពីមុនមកដែរ, ភិក្ខុចូលទៅកាន់សភាពមួយដែលនៅផុតពីសេចក្តីសុខនិងសេចក្តីទុក្ខគឺចតុត្ថជ្ឈាន ដែលមានភាពបរិសុទ្ធទាំងស្រុងដោយមានភាពឧបេក្ខា និងសតិដឹងហើយក៏តាំងនៅក្នុងចតុត្ថជ្ឈាននេះ ។

ម្នាលភិក្ខុទាំងឡាយ,នេះហើយហៅថាការដំកល់ចិត្តឱ្យនឹងត្រូវ ។ ម្នាលភិក្ខុទាំងឡាយ,នេះហើយហៅថាសេចក្តីពិតអំពីមាគ៌ាឆ្ពោះទៅរកការរលត់ទុក្ខ ។

(5)



ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ, ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ, សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ, វយធម្មានុបស្សី វា ធម្មេសុ វិហរតិ, សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ, «អត្ថិ ធម្មា»តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ ។ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ, ន ច កិញ្ចិ លោកេ ឧបាទិយតិ ។

ឯវម្បិ ខោ, ភិក្ខវេ, ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។

[illegible]

- [illegible]

(ព្រះត្រៃបិដក លេខ 19 ទំព័រ 230)

តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើល ធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុង ឬ តាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្រៅ, ឬតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយនៅខាងក្នុងផងនៅខាងក្រៅផង ។ តាមរបៀបនេះ, ភិក្ខុតាំងនៅពិនិត្យមើលធម៌ដែលកើតឡើងនៅក្នុងធម៌ទាំងឡាយ ឬតាំងនៅពិនិត្យមើល ធម៌ដែលរលត់ទៅវិញនៅក្នុងធម៌ទាំងឡាយ,ឬតាំងនៅពិនិត្យមើល ធម៌ដែលកើតឡើងនិងរលត់ទៅវិញនៅក្នុងធម៌ទាំងឡាយក្នុងពេលដំណាលគ្នា ។សតិដែលដឹងថា« នេះគ្រាន់តែជាធម៌» បានតាំងស៊ប់នៅក្នុងចិត្តរបស់ភិក្ខុ ។ តាមរបៀបនេះ,ភិក្ខុធ្វើឱ្យប្រើកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើងរហូតទៅដល់កំរិតមួយដែលគ្មានអ្វីក្រៅអំពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ តាមរបៀបនេះ,ភិក្ខុតាំងនៅដាច់ស្រឡះគ្មានជាប់ជំពាក់ចិត្តឬលោភលន់អ្វីចំពោះរបស់នៅក្នុងលោកនេះសោះឡើយ ។

ម្នាលភិក្ខុទាំងឡាយ,នេះហើយជារបៀបដែលភិក្ខុតាំងនៅពិនិត្យមើលធម៌ក្នុងធម៌ទាំងឡាយស្តីអំពី អរិយសច្ច៤ ។

# ៦.សតិបដ្ឋានភាវនានិសំសោ

យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ (34) ភាវេយ្យ សត្តវស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ : ទិដ្ឋេវ ធម្មេ អញ្ញា (35) សតិ វា ឧបាទិសេសេ អនាគាមិតា (36) ។

តិដ្ឋន្តុ ភិក្ខវេ សត្តវស្សានិ ។ យោហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ ឆ វស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ : ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។

តិដ្ឋន្តុ ភិក្ខវេ ឆ វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ បញ្ច វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ ចត្តារិ វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ តីណិ វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ ទ្វេ វស្សានិ ... បេ ...

តិដ្ឋន្តុ ភិក្ខវេ ឯកំ វស្សំ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្តមាសានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ : ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។

[illegible]
[illegible]
[illegible]
[illegible]
[illegible]

# ៦.លទ្ធផលនៃការចំរើនសតិបដ្ឋាន

ម្នាលភិក្ខុទាំងឡាយ,ជាការពិតណាស់, បើបុគ្គលណាម្នាក់បានចំរើនសតិបដ្ឋានទាំង៤ ឥតខ្ចោះតាមរបៀបនេះ (34) អស់៧ឆ្នាំ,បុគ្គលនោះគង់នឹងបានសំរេចផលណាមួយ ក្នុងចំណោមផលទាំងពីរនេះ : ថ្នាក់យ៉ាងខ្ពស់បំផុតគឺ ភាវៈជាព្រះអរហន្ត (35) ឬបើមាន ឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់ អនាគាមី ដែរ (36) ។

ម្នាលភិក្ខុទាំងឡាយ, កុំថាឡើយអស់៧ឆ្នាំ, បើបុគ្គលណាម្នាក់បានចំរើនសតិបដ្ឋាន ទាំង៤ឥតខ្ចោះតាមរបៀបនេះ អស់៦ឆ្នាំ,បុគ្គលនោះគង់នឹងបានសំរេចផលណាមួយ ក្នុងចំណោមផលទាំងពីរនេះ : ថ្នាក់យ៉ាងខ្ពស់បំផុតគឺ ភាវៈជាព្រះអរហន្ត ឬបើមាន ឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់ អនាគាមី ដែរ ។

ម្នាលភិក្ខុទាំងឡាយ, កុំថាឡើយអស់៦ឆ្នាំ ...។ល។
ម្នាលភិក្ខុទាំងឡាយ, កុំថាឡើយអស់៥ឆ្នាំ ...។ល។
ម្នាលភិក្ខុទាំងឡាយ, កុំថាឡើយអស់៤ឆ្នាំ ...។ល។
ម្នាលភិក្ខុទាំងឡាយ, កុំថាឡើយអស់៣ឆ្នាំ ...។ល។
ម្នាលភិក្ខុទាំងឡាយ, កុំថាឡើយអស់២ឆ្នាំ ...។ល។

ម្នាលភិក្ខុទាំងឡាយ,កុំថាឡើយអស់១ឆ្នាំ បើបុគ្គលណាម្នាក់បានចំរើនសតិបដ្ឋាន ទាំង៤ឥតខ្ចោះតាមរបៀបនេះអស់៧ខែ,បុគ្គលនោះគង់នឹងបានសំរេចផលណាមួយក្នុង ចំណោមផលទាំងពីរនេះ : ថ្នាក់យ៉ាងខ្ពស់បំផុតគឺ ភាវៈជាព្រះអរហន្ត ឬបើមាន ឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់ អនាគាមី ដែរ ។

តិដ្ឋន្តុ ភិក្ខវេ សត្តវស្សានិ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ ឆ វស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ : ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។

តិដ្ឋន្តុ ភិក្ខវេ ឆ វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ បញ្ច វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ ចត្តារិ វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ តីណិ វស្សានិ ... បេ ...
តិដ្ឋន្តុ ភិក្ខវេ ទ្វេ វស្សានិ ... បេ ...

តិដ្ឋន្តុ ភិក្ខវេ ឯកំ វស្សំ ។ យោហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ អឌ្ឍមាសំ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ : ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។

តិដ្ឋន្តុ ភិក្ខវេ អឌ្ឍមាសំ ។ យោហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្តាហំ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ : ទិដ្ឋេវ ធម្មេ អញ្ញាសតិ វា ឧបាទិសេសេ អនាគាមិតា ។

«ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិបដ្ឋានា »តិ ។

ឥតិ យំ តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។ ឥទមវោច ភគវា ។
អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។
មហាសតិបដ្ឋានសុត្តំ និដ្ឋិតំ

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់៧ខែ.បើបុគ្គលណាម្នាក់បានចំរើនសតិបដ្ឋានទាំងបួនឥតខ្ចោះតាមរបៀបនេះអស់៦ខែ. បុគ្គលនោះគង់នឹងបានសំរេចផលណាមួយក្នុងចំណោមផលទាំងពីរនេះ : ថ្នាក់យ៉ាងខ្ពស់បំផុតគឺ ភាវៈជាព្រះអរហន្ត ឬបើមានឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់ អនាគាមី ដែរ ។

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់៦ខែ ...។ល។

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់៥ខែ ...។ល។

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់៤ខែ ...។ល។

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់៣ខែ ...។ល។

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់២ខែ ...។ល។

ម្នាលភិក្ខុទាំងឡាយ. កុំថាឡើយអស់១ខែ. បើបុគ្គលណាម្នាក់បានចំរើនសតិបដ្ឋានទាំងបួនឥតខ្ចោះតាមរបៀបនេះអស់កន្លះខែ.បុគ្គលនោះគង់នឹងបានសំរេចផលណាមួយក្នុងចំណោមផលទាំងពីរនេះ : ថ្នាក់យ៉ាងខ្ពស់បំផុតគឺ ភាវៈជាព្រះអរហន្ត ឬបើមានឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់ អនាគាមី ដែរ ។

ម្នាលភិក្ខុទាំងឡាយ.កុំថាឡើយអស់កន្លះខែ. បើបុគ្គលណាម្នាក់បានចំរើនសតិបដ្ឋានទាំងបួនឥតខ្ចោះតាមរបៀបនេះអស់៧ថ្ងៃ.បុគ្គលនោះគង់នឹងបានសំរេចផលណាមួយក្នុងចំណោមផលទាំងពីរនេះ : ថ្នាក់យ៉ាងខ្ពស់បំផុតគឺ ភាវៈជាព្រះអរហន្ត ឬបើមានឧបាទានក្ខន្ធនៅសេសសល់ខ្លះ ក៏បានថ្នាក់ អនាគាមី ដែរ ។

ដោយមកពីហេតុនេះហើយទើបព្រះពុទ្ធទ្រង់មានព្រះបន្ទូលថា : « ម្នាលភិក្ខុទាំងឡាយ. នេះជាផ្លូវមូលតែមួយគត់ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយដើម្បីឱ្យបានរួចចាកអំពីសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួលទាំងឡាយ. ដើម្បីកំចាត់បង់នូវសេចក្តីទុក្ខនិងទោមនស្សទាំងឡាយ. ដើម្បីឱ្យបានសំរេចអរិយមគ្គ.ដើម្បីឱ្យបានពិសោធឃើញព្រះនិព្វាន. ផ្លូវនេះគឺ សតិបដ្ឋានទាំង៤នេះឯង »។

ព្រះដ៏មានព្រះភាគទ្រង់បានសំដែងហើយយ៉ាងនេះ ។ ភិក្ខុទាំងឡាយក៏មានសេចក្តីត្រេកអររីករាយនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

( *ចប់មហាសតិបដ្ឋានសូត្រ* )

# អត្ថាធិប្បាយពាក្យយោង

(1) ពាក្យភិក្ខុ «អ្នកបួស» ប្រើសំរាប់ហៅផងទាំងអស់ដែលបានស្តាប់ធម្មទេសនារបស់ព្រះពុទ្ធ ។ ម្យ៉ាងទៀតអ្នកចំរើនកម្មដ្ឋានទាំងអស់ណាដែលបានដើរតាមមាគ៌ានេះ ទោះបីអ្នកនោះមិនមែនជាភិក្ខុ តាមន័យដើមរបស់ពាក្យនេះក៏ដោយ គឺសុទ្ធតែអាចទទួលបានផលបាន ឲ្យតែប្រតិបត្តិធ្វើតាមពាក្យ ប្រៀនប្រដៅដែលបានសំដែងនៅទីនេះ ។ (1a) សោក : សេចក្តីព្រួយចិត្ត, (1b) ទុក្ខ : សេចក្តីលំបាកកាយ, (1c) ទោមនស្ស : សេចក្តីអាក់អន់ចិត្ត ។

(2) សតិបដ្ឋាន ៖ ការតាំងស៊ប់របស់សតិ ។ សតិមានន័យថា : សេចក្តី ដឹង ។ សតិបដ្ឋាន មានន័យថា : អ្នកចំរើនកម្មដ្ឋានត្រូវតែធ្វើការដោយយកចិត្តទុកដាក់និងឲ្យបានជាប់ជានិច្ចដើម្បីបានតាំងស៊ប់នៅក្នុងសតិដឹង ឬក្នុងការប្រុងប្រយ័ត្ន ។ ហេតុនេះហើយ បានជាយើងប្រើពាក្យ «ការតាំងស៊ប់របស់សតិ» ដើម្បីឲ្យន័យថា គេត្រូវតែធ្វើការដោយសកម្មដើម្បីរក្សាសតិដឹងឲ្យបានជាប់ជានិច្ចអំពីវេទនា ។ សេចក្តីសំដែងនៃធម្មទេសនានេះ បញ្ជាក់ឲ្យឃើញច្បាស់ក្នុងរឿងហ្នឹង ។ ក្នុងធម្មទេសនារបស់ព្រះពុទ្ធ គ្រប់ផ្នែកខ្លះ, ពាក្យសតិ មានន័យថា «ការចងចាំ, ការនឹកឃើញ» (ទីឃនិកាយ VRII,4II ; II,374; PTS I, I80;II,292 ) ពាក្យ សតិ នេះ មានន័យយ៉ាងពិសេសនៅពេលដែលព្រះពុទ្ធទ្រង់សំដែងអំពីលទ្ធភាពអាចនឹកឃើញអតីតជាតិ តាមរយៈការប្រតិបត្តិឈាន ។ ប៉ុន្តែក្នុងអត្ថបទសតិបដ្ឋាន ការប្រតិបត្តិវិបស្សនាដែលមិនមែននាំឲ្យបានសំរេចឈានទេ តែនាំឲ្យចិត្តបានបរិសុទ្ធផូរផង់ ន័យរបស់ពាក្យសតិ មានតែយ៉ាងគឺសតិដឹងអំពីពេលបច្ចុប្បន្ននេះ មិនមែនការនឹកឃើញអំពីអតីតកាលឬការយល់សប្តិអំពីអនាគតទេ ។

(3) នៅគ្រប់ពេលដែលមានសំនួរអំពី សតិ ព្រះពុទ្ធទ្រង់បានឆ្លើយតបដោយបញ្ចូលពាក្យ «សម្បជញ្ញៈ» គឺការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង សម្បជានោ ដែលជាគុណនាមរបស់ពាក្យសម្បជញ្ញៈ ។ ជាឧទាហរណ៍សូមមើលសេចក្តីអធិប្បាយអំពី សម្មាសតិ គ្រប់ផ្នែកស្តីអំពីអរិយសច្ចៈគឺសេចក្តីពិតអំពីមាគ៌ា ។ ជាលទ្ធផលដោយមកអំពីការប្រើពាក្យទាំងពីរនេះបញ្ចូលគ្នាជាញឹកញាប់យ៉ាងនេះ ពាក្យសម្បជញ្ញៈក៏នៅជាមានន័យស្ទើរតែដូចគ្នានឹងពាក្យសតិដែរឬក៏មានន័យដូចជារលឹកយល់ក្លៀវក្លាត្រូវតែមានសតិដឹងជាប់ជានិច្ច ។ នៅក្នុងសុត្តន្តបិដក ព្រះពុទ្ធទ្រង់បានពន្យល់ឲ្យន័យពីរយ៉ាងអំពីពាក្យនេះ ។ ក្នុងសំយុត្តនិកាយ (VRI III មហាវគ្គ សំយុត្ត 401 PTS V, 180-1) ព្រះអង្គបានសំដែងដូចនេះ :

កថញ្ច ភិក្ខវេ, ភិក្ខុ សម្បជានោ ហោតិ ?<br>
ឥធ ភិក្ខវេ, ភិក្ខុនោ វិទិតា វេទនា ឧប្បជ្ជន្តិ,<br>
វិទិតា ឧបដ្ឋហន្តិ, វិទិតា អព្ភត្ថំ គច្ឆន្តិ ; វិទិតា<br>
សញ្ញា ឧប្បជ្ជន្តិ, វិទិតា ឧបដ្ឋហន្តិ, វិទិតា អព្ភត្ថំ<br>
គច្ឆន្តិ ; វិទិតា វិតក្កា ឧប្បជ្ជន្តិ, វិទិតា ឧបដ្ឋហន្តិ,<br>
វិទិតា អព្ភត្ថំ គច្ឆន្តិ ។ ឯវំ ខោ, ភិក្ខវេ, ភិក្ខុ សម្បជានោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុយល់យ៉ាងច្បាស់នុ៎ះ តើយ៉ាងដូចម្តេច ?<br>
ម្នាលភិក្ខុទាំងឡាយ, ក្នុងទីនេះ ភិក្ខុដឹងច្បាស់អំពីវេទនាដែលកើតឡើងនៅក្នុងខ្លួន<br>
អំពីការស្ថិតនៅរបស់វា និងអំពីការរលត់បាត់ទៅវិញរបស់វា ។ ភិក្ខុដឹងច្បាស់អំពី

អត្ថាធិប្បាយពាក្យគាថា

សញ្ញាដែលកើតឡើង គឺពីការស្ថិតនៅរបស់វានិងគឺពីការរលត់ចាកទៅវិញរបស់វា ។
ភិក្ខុដឹងច្បាស់អំពីវិតក្កៈ ការត្រិះរិះដែលកើតឡើងនៅក្នុងចិត្ត គឺ វិតក្កៈដែលស្ថិត
នៅនិងអំពីវិតក្កៈដែលរលត់ចាកទៅវិញនៅក្នុងចិត្ត ។ ម្នាលអ្នកចំរើនភិក្ខុ
ទាំងឡាយ, គឺតាមរបៀបនេះហើយដែលអ្នកចំរើនភិក្ខុត្រូវដឹងយ៉ាងច្បាស់ ។

តាមសេចក្តីអធិប្បាយខាងលើនេះយើងឃើញយ៉ាងច្បាស់ថា គេនឹងទៅជាសម្បជានោបាន លុះត្រាតែគេពិសោធឃើញចរិកលក្ខណៈនៃសេចក្តីមិនទៀងគឺ កើតឡើង,ស្ថិតនៅ,ហើយរលត់ចាកទៅវិញ ។ ការពិសោធន៍នេះត្រូវមានវេទនាជាមូលដ្ឋាន (វិទិតា វេទនា) ។ បើគេមិនទាន់បានពិសោធ ឃើញចរិកលក្ខណៈនៃសេចក្តីមិនទៀងតាមរយៈវេទនានៅឡើយទេនុះ គឺ គ្រាន់តែជាការពិសោធន៍ឃើញតាមប្រាជ្ញាសាវៃប៉ុណ្ណោះ ព្រោះថាមានតែតាមរយៈវេទនាទើបគេអាចពិសោធឃើញពិតប្រាកដជាក់ស្តែងបាន ។ ម្យ៉ាងទៀតសេចក្តីអធិប្បាយនេះបង្ហាញឱ្យឃើញថាសម្បជញ្ញៈត្រូវស្ថិតនៅក្នុងការពិសោធន៍នៃ សេចក្តីមិនទៀងរបស់វិតក្កៈនិងសញ្ញា ។ ក្នុងទីនេះ យើងត្រូវកត់សំគាល់ថាសេចក្តីមិនទៀងពិសោធឃើញតាមរយៈវេទនាតែងតែមានកន្លា ទាំងពីរនេះរួមជាមួយផង ក៏ព្រោះតាមគម្ពីរអង្គុត្តរនិកាយ ( VRI III ទសកនិបាត58-PTS V. 107 ) ព្រះពុទ្ធទ្រង់សំដែងថា : វេទនា សមោសរណា សព្វេ ធម្មា គឺថារឿងដែលកើតឡើងនៅក្នុងចិត្តសុទ្ធតែមានដំណើរហូរទៅជាមួយវេទនា ។

សេចក្តីពន្យល់ទីពីររបស់ព្រះពុទ្ធអំពីសម្បជានោគឺសង្កត់បញ្ជាក់ថាសម្បជញ្ញៈត្រូវតែមានបន្តជាប់ជានិច្ច ។ ជាច្រើនលើកច្រើនគ្រា ព្រះអង្គទ្រង់បានត្រាស់សំដែងដដែលៗអំពីពាក្យនៃវគ្គសម្បជានបទក្នុងមហាសតិប្បដ្ឋានសូត្រដូចជាអត្ថបទមួយក្នុងចុងមហាបរិនិព្វានសូត្រ (ទីឃនិកាយII VRI. 160; PTS 95 ) នេះថា :

កថញ្ច, ភិក្ខវេ, ភិក្ខុ សម្បជានោ ហោតិ ?
ឥធ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ
អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ
សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ
សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ
អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ
ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ
គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ
តុណ្ហីភាវេ សម្បជានការី ហោតិ ។

ម្នាលភិក្ខុទាំងឡាយ, ចុះភិក្ខុយល់យ៉ាងច្បាស់នុះ តើយ៉ាងដូចម្តេច ?
ក្នុងទីនេះ នោះដើរទៅមុខឬថយក្រោយ,ភិក្ខុដឹងច្បាស់អំពីអាកប្បកិរិយានេះ,ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ កាលមើលត្រង់ទៅមុខឬមើលទៅចំហៀងទាំងសងខាងភិក្ខុដឹងច្បាស់នូវកិរិយានេះដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ កាលបត់ដៃ,លាដៃ,បត់ជើងឬលាជើងក្តី ភិក្ខុដឹងច្បាស់នូវកិរិយានេះដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ កាលគ្រងសង្ឃាដិនិងចីវរឬទ្រង់បាត្រក្តី ភិក្ខុដឹងច្បាស់

នូវកិរិយានោះ ដោយមានសតិមិនដាច់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ កាលបរិភោគអាហារ, ផឹកទឹក, ទំពាឬស្រស់ស្រូបអាហារក្តី ភិក្ខុដឹងច្បាស់នូវកិរិយានោះ ដោយមានសតិមិនដាច់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ កាលភិក្ខុបន្ទោរបង់នូវឧច្ចារៈ (បត់ជើងធំ) ឬបស្សាវៈ (បត់ជើងតូច) ភិក្ខុដឹងច្បាស់នូវកិរិយានោះដោយមានសតិមិនដាច់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ កាលដើរ, ឈរ, អង្គុយ, ដេកលក់ឬភ្ញាក់ពីដំណេក, និយាយឬនៅស្ងៀមក្តី ភិក្ខុដឹងច្បាស់នូវកិរិយានោះដោយមានសតិមិនដាច់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។

ដោយមានការយល់យ៉ាងត្រឹមត្រូវនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ យើងឃើញច្បាស់ថា :

បើសម្បជញ្ញៈជាប់ជានិច្ចនេះគ្រាន់តែជាការដឹងច្បាស់អំពីអាកប្បកិរិយានៅខាងក្រៅរបស់ការដើរ, ការបរិភោគអាហារ ឬសកម្មភាពឯទៀតនៃកាយ នោះការប្រតិបត្តិគ្រាន់តែឱ្យមានសតិតែប៉ុណ្ណោះ ។ ប៉ុន្តែបើការដឹងច្បាស់ត្រូវបានដឹងរហូតទៅដល់លក្ខណៈនៃការកើតនិងការរលត់ទៅវិញនៃវេទនាផង នៅពេលដែលអ្នកចំរើនកម្មដ្ឋានបំពេញសកម្មភាពនុះ ទើបគេកំពុងប្រតិបត្តិសម្បជានោ សតិមា ហើយនឹងបញ្ញាញាណក៏ពិតជារីកចំរើនឡើងដែរ ។

ចំពោះរឿងនេះព្រះពុទ្ធទ្រង់បានធ្វើអត្ថាធិប្បាយយ៉ាងច្បាស់លាស់ថែមទៀតក្នុងអង្គុត្តរនិកាយ (VRI I ចតុក្កនិបាត 12; PTS II 14) ដោយប្រើពាក្យមានលំនាំដូចគ្នានឹងពាក្យក្នុងវគ្គសម្បជាន-បព្វៈ ។

យតំ ចរេ យតំ តិដ្ឋេ, យតំ អច្ឆេ យតំ សយេ យតំ
សមិញ្ជយេ ភិក្ខុ, យតមេនំ បសារយេ ឧទ្ធំ តិរិយំ អបាចីនំ,
យាវតា ជគតោ គតិ, សមវេក្ខិតា ច ធម្មានំ ខន្ធានំ ឧទយព្វយំ ។

នោះបើភិក្ខុដើរ ឈរ អង្គុយឬ ដេក នោះបើភិក្ខុបត់ ឬ លា ដៃជើង
នៅលើ នៅចំហៀងឬ នៅក្រោម នោះបើភិក្ខុធ្វើអ្វីក៏ដោយនៅក្នុងលោក
នេះ ភិក្ខុពិនិត្យមើលការកើតនិងការរលត់ទៅវិញនៃខន្ធទាំងឡាយ ។

ព្រះពុទ្ធទ្រង់សង្កត់យ៉ាងខ្លាំងទៅលើការយល់ច្បាស់អំពីអនិច្ចា សេចក្តីមិនទៀង នៅគ្រប់សកម្មភាពទាំងអស់នៃកាយនិងចិត្ត ។ ដូច្នេះ ដោយហេតុថាការយល់ដោយត្រឹមត្រូវនូវពាក្យបច្ចេកទេស « សម្បជញ្ញៈ » នេះជាកត្តាមួយសំខាន់ដើម្បីឱ្យដឹងន័យរបស់សូត្រនេះ យើងបានបកប្រែពាក្យនេះថា « ការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង » នោះបើការបកប្រែនេះវែងជាងការបកប្រែធម្មតាថា « ការយល់ច្បាស់ » ក៏ដោយ ។

(3a) ក្នុងទីនេះ លោក មានន័យថា : ចិត្តនិងកាយ ។

4- ក្នុងវគ្គចាប់ផ្តើមនេះ ព្រះពុទ្ធទ្រង់សំដែងម្តងហើយម្តងទៀតអំពីពាក្យបន្តជាច្រើនដើម្បីរំលឹកយើងឱ្យសង្កេតការពិនិត្យមើលឱ្យបានជាប់ជានិច្ចចំពោះ « កាយក្នុងកាយ » ឬ « វេទនាក្នុងវេទនាទាំងឡាយ » ឬ « ចិត្តក្នុងចិត្ត » ឬ « ធម៌ក្នុងធម៌ទាំងឡាយ » ។ ថ្វីបើការរៀបចំពាក្យបន្តនេះមានភាពចាក់មួយជាមិនធម្មតា តែពាក្យទាំងនេះយោលទៅរកការដាក់ផ្លែងថាការពិនិត្យមើលនេះត្រូវតែផ្តោះទៅរកការពិសោធន៍ឱ្យឃើញពិតៗ មិនមែនគ្រាន់តែឱ្យមានគំនិត មានការស្រមៃ មានការជញ្ជឹងគិតអំពីរបស់អ្វីមួយនោះឡើយ ។ ព្រះពុទ្ធទ្រង់សង្កត់លើចំណុចនេះនៅក្នុងអានាបានស្សតិសូត្រ (មជ្ឈិមនិកាយ III = VRI, 149, PTS.83,4) ត្រង់កន្លែងដែលព្រះអង្គទ្រង់សំដែងអំពីដំណាក់ថ្នាក់ក្នុងការរីកចំរើននៃការប្រតិបត្តិអានាបានៈ ។ នៅក្នុងផ្នែកដែលព្រះអង្គទ្រង់ពន្យល់អំពីរបៀបដែលគេប្រតិបត្តិសតិប្បដ្ឋានទាំង៤បានលួតលាស់តាមរយៈអានាបានៈព្រះពុទ្ធបានសំដែងថា :

... កាយេសុ កាយញ្ញតរាហំ, ភិក្ខវេ, ឯវំ វទាមិ យទិទំ អស្សាសបស្សាសា ។ តស្មាតិហ, ភិក្ខវេ, កាយេ កាយានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ម្នាលភិក្ខុទាំងឡាយ ! តថាគតពោលថា «ដង្ហើមចូលដង្ហើមចេញ» គឺដូចជាមានកាយមួយទៀតនៅក្នុងកាយ ។ ម្នាលភិក្ខុទាំងឡាយ, ដោយពិនិត្យមើលកាយក្នុងកាយតាមរបៀបនេះ នៅពេលនោះគឺភិក្ខុកំពុងនៅយ៉ាងខ្ជាប់ខ្ជួនប្រកបដោយសតិនិងប្រាជ្ញានិងការយល់ច្បាស់ដាច់ខាតនិងអំពីសេចក្ដីមិនទៀងដោយបោះបង់ចោលនូវលោភៈនិងទោសៈចំពោះរបស់នៅក្នុងលោកនេះ ។

នេះបង្ហាញឱ្យឃើញថា ការប្រតិបត្តិអានាបានសតិនាំឱ្យពិសោធឃើញកាយផ្ទាល់គឺថាឱ្យសង្កេតឃើញវេទនានៅក្នុងកាយ ។ វេទនាទាំងឡាយអាចមានការទាក់ទងជាមួយដង្ហើម ជាមួយខ្យល់អុកស៊ីហ្សែននៅក្នុងឈាមជាដើមប៉ុន្តែការរៀបរាប់លំអិតទាំងនេះមិនសំខាន់ទេ ។ ការពិសោធន៍ឃើញ កាយក្នុងកាយ មិនមែនកើតឡើងដោយសារការប្រតិបត្តិការចញ្ចឹងគិតនោះទេ តែជាការសង្កេតឃើញនៅពេលពេញកាយ ។ ពិសេសលើសនេះទៅទៀតព្រះអង្គទ្រង់បន្តថា :

... វេទនាសុ វេទនាញ្ញតរាហំ ភិក្ខវេ ឯវំ វទាមិ យទិទំ អស្សាសបស្សាសានំ សាធុកំ មនសិការំ ។ តស្មាតិហ, ភិក្ខវេ, វេទនាសុ វេទនានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ម្នាលភិក្ខុទាំងឡាយ, តថាគតពោលថា «ដោយការយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវចំពោះដង្ហើមចូល, ដង្ហើមចេញ» គឺដូចជាមានវេទនាផ្សេងទៀតនៅក្នុងវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ, ដោយពិនិត្យមើលវេទនានៅក្នុងវេទនាទាំងឡាយតាមរបៀបនេះ, នៅពេលនោះ ភិក្ខុកំពុងនៅយ៉ាងខ្ជាប់ខ្ជួនប្រកបដោយសតិនិងប្រាជ្ញានិងការយល់ច្បាស់ដាច់ខាតនិងអំពីសេចក្ដីមិនទៀងដោយបោះបង់ចោលនូវលោភៈនិងទោសៈ ចំពោះរបស់នៅក្នុងលោកនេះ ។

ដោយឱ្យតម្លៃទៅលើការពិនិត្យមើលដង្ហើមឱ្យស្មើនឹងការពិសោធន៍ឃើញវេទនាទាំងឡាយ ព្រះពុទ្ធទ្រង់បង្ហាញអំពីសារៈសំខាន់ដាច់ខាតរបស់កាយនិងវេទនាក្នុងការចំរើនកម្មដ្ឋានដោយត្រឹមត្រូវ ។ គឺការពិសោធន៍ផ្ទាល់នូវវេទនាទាំងនេះនៅពេលពេញកាយមួយអន្លើនិងសតិនិងអំពីសេចក្ដីមិនទៀង ព្រមទាំងការពិចារណាដែលធ្វើឱ្យសតិបដ្ឋានទាំង៤មានភាពល្អប្រសើរឥតខ្ចោះ ។

យើងសំគាល់ឃើញថានៅក្នុងអានាបានសតិសូត្រ ព្រះពុទ្ធទ្រង់រៀបរាប់អំពីការពិសោធន៍ឃើញកាយក្នុងកាយ និងវេទនាក្នុងវេទនាទាំងឡាយដូចជាគេពិនិត្យមើលដង្ហើម ។ ប៉ុន្តែកាលណាព្រះអង្គសំដែងអំពីការពិនិត្យមើលចិត្តព្រះអង្គមិនប្រើពាក្យបែបដូចដែលទេ ។ ផ្ទុយទៅវិញព្រះអង្គទាញអារម្មណ៍យើងឱ្យឆ្ពោះទៅរកសារៈសំខាន់នៃសម្បជញ្ញៈទៅវិញ :

... ចិត្តេ ចិត្តានុបស្សី, ភិក្ខវេ, តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ នាហំ, ភិក្ខវេ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតឹ វទាមិ ។

ម្នាលភិក្ខុទាំងឡាយ ! ដោយពិនិត្យមើលចិត្តក្នុងចិត្តនៅពេលនោះ ភិក្ខុតាំងនៅយ៉ាងសង្ឃឹមព្យាយាមដោយសតិនិង ត្រូវនឹងការយល់ច្បាស់ដាច់ដាតនិងអំពីសេចក្តីមិនទៀង ដោយបន្ទាបបង់នូវលោភៈនិងទោសៈចំពោះរបស់ នៅក្នុងលោកនេះ ។ ម្នាលភិក្ខុទាំងឡាយ ! កាលណាព្រះយោគាវចរណាមួយដែលមិនព្យាយាមដែលគ្មានសតិ មិនដាច់ដាតនិងអំពីសេចក្តីមិនទៀង អ្នកនោះមិនមែនចំរើនអានាបានៈទេ ។ *

ក្នុងរឿងនេះ យើងឃើញថាព្រះពុទ្ធទ្រង់សំដែងសង្កត់យ៉ាងខ្លាំងថា នោះមិនក្នុងពេលចំរើនអានាបានៈ គឺមានសតិនិងអំពីដង្ហើមចូលនិងដង្ហើមចេញក្តី, បើគ្មានសតិនិងអំពីសេចក្តីមិនទៀង ដោយការពិសោធន៍ផ្ទាល់ចំពោះវេទនាទេ, គុះគេមិនមែនប្រតិបត្តិដោយត្រឹមត្រូវទេ ។

5- បជានាតិ « ដឹងដោយត្រឹមត្រូវ » មានន័យថា ដឹងយ៉ាងជ្រៅជ្រះដោយខ្ជាប់ខ្ជួនព្យាយាមដោយបញ្ញាញាណ ។ ពាក្យនេះពិបាកនឹងបកប្រែឱ្យត្រូវដោយប្រើពាក្យតែមួយចំពោះនោះណាស់ ។ ពាក្យនេះជាលទ្ធផលនៃការធ្វើឱ្យកិរិយាសព្ទ « ជានាតិ » មានន័យរឹតតែខ្លាំងឡើង។ សព្ទ « ជានាតិ » ប្រែថា « វាដឹង » បូកនឹងបុព្វបទ « ប» ដែលមកពីពាក្យបញ្ញា « បញ្ញាញាណ » ។

6- ឥតិ អជ្ឈត្តំ ... កាយេ កាយានុបស្សី វិហរតិ (តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើលកាយក្នុងកាយ) ។ វគ្គនេះត្រូវបានប្រើដដែលៗចំនួន២១ដងក្នុងមហាសតិបដ្ឋានសូត្រ ដោយមានការកែប្រែខ្លះស្របទៅតាមផ្នែកសតិបដ្ឋាន៤ដែលគេបានទៅយល់ : កាយ,វេទនា,ចិត្តនិងធម៌ ។ ក្នុងវគ្គជាគន្លឹះនេះព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាស របៀបរាប់ពីចំហានរូបធាតុនៃវិបស្សនាកម្មដ្ឋាន ដែលអ្នកចំរើនកម្មដ្ឋានទាំងអស់ត្រូវឆ្លងកាត់ទោះបីគេចាប់ផ្តើមអំពីផ្នែកណាមួយនៃព្រះសូត្រក៏ដោយ ។ ក្នុងសេចក្តីរៀបរាប់ដដែលៗនីមួយៗ វគ្គនេះនាំយើងឱ្យផ្ចង់ស្មារតីទៅលើព្រឹត្តិការណ៍យ៉ាងសំខាន់គឺថា ទោះបីយើងពិនិត្យមើលកាយ, មើលវេទនា, មើលចិត្តឬមើលធម៌ក្តី, យើងត្រូវតែពិសោធឱ្យឃើញបរិតលក្ខណៈជាមូលដ្ឋាននៃការកើតឡើងនិងការរលត់បាត់ទៅវិញជាដរាប ។ ការយល់អំពីសេចក្តីមិនទៀងនឹងនាំយើងឆ្ពោះទៅរកការបកខ្លួនចេញឱ្យផុតពីលោភនៃចិត្តនិងរូបនេះ ដែលនឹងនាំយើងទៅរកព្រះនិព្វាន (ការរំដោះខ្លួន) ។

7- ពហិទ្ធា (នៅខាងក្រៅ) ជួនកាលគេបកប្រែថា របស់នៅខាងក្រៅឬការពិនិត្យមើលកាយរបស់អ្នកដទៃ ។ ក្នុងផ្នែកមួយភាគនេះដែលស្តី អំពីការពិនិត្យមើលវេទនាជួនកាលគេយល់ថា « ពិសោធឃើញវេទនារបស់អ្នកដទៃ » ។ ទោះបីការពិសោធន៍ឃើញបែបនេះមិនមែនធ្វើមិនកើតសុទ្ធតែដោយ តែការពិសោធន៍ឃើញបែបនេះធ្វើបានតែនៅថ្នាក់ខ្ពង់ខ្ពស់ណាស់ ។ តាមសូត្រនេះគេបង្គាប់ឱ្យអ្នកចំរើនកម្មដ្ឋានទៅអង្គុយម្នាក់ឯងនៅកន្លែងណាមួយនៅក្នុងព្រៃ នៅក្រោមដើមឈើ នៅក្នុងបន្ទប់ទទេស្ងាត់មួយ ហើយចាប់ផ្តើមចំរើនកម្មដ្ឋាននៅទីនោះ ។ តាមស្ថានការណ៍បែបនេះ ការពិនិត្យ មើលអ្នកដទៃគ្មានន័យអ្វីឡើយហើយវេទនារបស់អ្នកដទៃ របស់អ្វីផ្សេងទៀតក៏គ្មានប្រយោជន៍អ្វីសោះដែរ ។ ដូច្នេះ ចំពោះអ្នកចំរើនកម្មដ្ឋានពាក្យថា « នៅខាងក្រៅ » ដែលមានន័យថា « នៅផ្ទៃខាងលើរបស់កាយ » ជាន័យសមរម្យជាងគេសំរាប់ពាក្យ « ពហិទ្ធា » នេះ ។ សូមអានកំណត់យោងលេខ២០ ផង ។

8- ពាក្យពលីថា « អត្ថិ កាយោ » ប្រែថា នេះជាកាយបង្ហាញឱ្យឃើញថា មកដល់ចំណាក់នេះអ្នកចំរើនកម្មដ្ឋានយល់យ៉ាងច្បាស់តាមការពិសោធន៍តាមរយៈវេទនាអំពីកាយតាមធម្មជាតិពិតប្រាកដរបស់វាគឺបរិតលក្ខណៈនៃការកើតឡើងនិងការរលត់បាត់ទៅវិញរបស់វា ។ ដោយហេតុនេះ គេគ្មានកំណត់សំគាល់ថា កាយនេះជាប្រុសឬស្រី ក្មេងឬចាស់ ជាល្អឬអាក្រក់ ហើយគេគ្មានជាប់ជំពាក់ចិត្តទៅលើកាយនេះថាជាអញ ខ្លួនអញឬ របស់អញនោះឡើយ ។ ហេតុនេះហើយបានជាយើងបកប្រែប្រយោគនេះថា « នេះជាកាយ » ។

អត្ថាធិប្បាយពាក្យពេចន៍

ការបន្ថែមពាក្យក្នុងសូត្រនេះ វេទនា, ចិត្តនិងធម៌ ( គិតគិត ) នៅក្នុងវគ្គនីមួយៗខ្លួននោះ គេបកប្រែប្រយោគប្រហែលគ្នាថា « នេះជាវេទនា, នេះជាចិត្តនិងនេះជាធម៌ ( គិតគិត ) » ដើម្បីបង្ហាញឱ្យឃើញថាអ្នកចំរើនកម្មដ្ឋានគ្មានរួមបញ្ចូលខ្លួនគេទៅក្នុង របស់នោះឡើយ ហើយគេស្គាល់របស់នោះច្បាស់តាមចរិតលក្ខណៈនៃភាពអនិច្ចា គឺសេចក្តីមិនទៀងរបស់វាផង ។

9- យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ : តាមរបៀបនេះគឺថាគំព្រឹកសតិដឹងរបស់ខ្លួនឱ្យរីកចំរើនឡើង រហូតទៅដល់កំរិតមួយដែលគ្មានឃើញអ្វីក្រៅពីការយល់ច្បាស់និងសតិដឹងសុទ្ធសាធនោះឡើយ ។ មកដល់ដំណាក់នេះចិត្តរបស់អ្នកចំរើនកម្មដ្ឋានបានចូលស៊ប់ទៅក្នុងការដឹងច្បាស់អំពីសេចក្តីមិនទៀងគឺការកើតឡើង និង ការរលត់បាត់ទៅវិញនៃវេទនាទាំងឡាយ ដោយគ្មានឃើញអ្វីក្រៅពីសតិដឹងនេះ ឡើយ ។ ដោយមានសតិដឹងច្បាស់នេះជាមូលដ្ឋាន អ្នកចំរើនកម្មដ្ឋានក៏ប្រើការចេះដឹងតាមការពិសោធន៍ផ្ទាល់របស់គេ ។ នេះគឺ បញ្ញាញាណ ។ ដោយសតិដឹងតាំងស៊ប់នៅក្នុងសេចក្តីមិនទៀង តាមរបៀបនេះ គេគ្មានជំពាក់ចិត្តទៅលើរបស់អ្វីមួយក្នុងលោកនេះសោះឡើយ ។

10- ក្រៅពីនេះមានការបញ្ចូលការផ្លាស់ប្តូរកិរិយាបថ ក្រៅពីកិរិយាបថមួយទាំង៤នៃកាយផង ។ នោះបីគេធ្វើអ្វីក៏ដោយអ្នកចំរើនកម្មដ្ឋានត្រូវតែមានសតិដឹងច្បាស់ជាប់ជានិច្ច : « យថា យថា វា, ... តថា តថា នំ បជានាតិ » នោះបីគេធ្វើអ្វីក៏ដោយ ... គេដឹងច្បាស់ពីអំពើរបស់គេជានិច្ច ។

11- សម្បជានការី ហោតិ គឺយល់ដោយមានសតិដឹងជាប់ជានិច្ចអំពីសេចក្តីមិន ទៀង ។ តាមន័យដើមរបស់ពាក្យ គឺគេមានសម្បជញ្ញៈគ្រប់ពេលវេលា ។ គួរយើងកត់សំគាល់ការវិវត្តន៍របស់ពុទ្ធវចនៈនៅក្នុងភាសាបាលីមួយកទៅ : កាលណាព្រះអង្គទ្រង់ប្រើពាក្យ ជានាតិ ប្រែថា គេដឹង, បជានាតិ គឺថា គេដឹងច្បាស់ឬដឹងយ៉ាងជ្រៅដោយបញ្ញាញាណនិង សម្បជានាតិ គឺគេដឹងជាប់ជានិច្ច អំពីធម្មជាតិមិនទៀងនៃការពិសោធន៍របស់គេ ។ ពាក្យនីមួយៗបង្ហាញពីជាន់ថ្នាក់ចំរើនទៅមុខជាលំដាប់ដែលអ្នកចំរើនកម្មដ្ឋានបានឆ្លងកាត់ក្នុងការប្រតិបត្តិតាមបទបញ្ញានៃព្រះសូត្រនេះ ។ តាមរបៀបនេះ គេចាប់ផ្តើមអំពីការពិសោធន៍ឆ្ពោះទៅដល់ការយល់ច្បាស់ដោយត្រឹមត្រូវ គឺសតិដឹងជាប់ជានិច្ចតាមរយៈវេទនាដោយមានការយល់យ៉ាងច្បាស់ទាំងស្រុងអំពីសេចក្តីមិនទៀងនៅគ្រប់ការពិសោធន៍ទាំងអស់ផង ។

12- ធាតុសោ ( ស្របតាមចរិតលក្ខណៈនៃធាតុនីមួយៗ ) មានន័យថា គេពិនិត្យមើលគុណភាពទូទៅទាំងអស់នៃកាយ ហើយធ្វើវិភាគតាមលក្ខណៈនៃធាតុទាំង៤ ។

13- ឧទុមាតកំ គឺមកពី ឧទុ ( ឡើង ) + ធមាត ( ធំ ) + ក ( ខ្លួន ) ហើយក្នុងន័យនោះគេអាចយល់ថាជាទីព្រៃរបស់ទឹកខ្លែងដែលប្រជាជនបញ្ចុះសាកសពក្នុងកំណាត់មួយថ្ងៃឬច្រើនថ្ងៃក្នុងមួយអាទិត្យ ។ នៅក្រៅផ្លូវដែកដែលនេះ ប្រជាជនអាចមកជួបជុំគ្នាដើម្បីទិញរបស់ដែលគេត្រូវការ ហើយមានមនុស្សជាច្រើនដើរកាត់តាមទីនោះដែលជាទីការស្រួលសំរាប់អ្នកជំនួញប្រែកក្លាយនាយលក់ទំនិញរបស់ខ្លួន ។ តាមធម្មតាភូមិនិងទីក្រុងផ្សេងៗក៏កើតឡើងនៅទីនោះហើយមនុស្សកាន់តែច្រើនបានចូលមកតាំងទីនៅទីនោះ ។

14- សាមិស គឺប្រកបដោយការជាប់ចិត្តឬតណ្ហា ។ តាមន័យដើមគឺ ស + អាមិស = ដែលមានសាច់ ។ និរាមិស : គ្មានការជាប់ចិត្ត, គឺមកពី និរ + អាមិស : ដែលគ្មានសាច់ ។ គេអាចបកប្រែពាក្យទាំងពីរម៉ាត់នេះថា មិនបរិសុទ្ធ និង បរិសុទ្ធ ឬ មានរូបនិងគ្មានរូប ឬមានកាមរាគឬគ្មានកាមរាគ ។ តាមការបកស្រាយធម្មតា សាមិសវេទនា មានការទាក់ទងទៅនឹងការត្រេកត្រអាលលើកាមគុណ រីឯ និរាមិសវេទនា គ្មានការទាក់ទងទៅនឹងកាមគុណទេ, គឺវេទនាដែលកើតមកពីសមាធិជាន់ខ្ពស់ ។

ក្នុងទីនេះ និយាយពីអ្នកចំរើនកម្មដ្ឋានពិនិត្យមើលវេទនា ដោយគ្មានប្រតិកម្មជាលោភៈឬ ជាទោសៈ ហើយពាក្យបកប្រែថា ប្រកបដោយការជាប់ចិត្ត និង គ្មានការជាប់ចិត្ត ។ ក្នុងការប្រតិបត្តិ ពាក្យទាំងពីរនេះ មានន័យច្បាស់លាស់ជាង ។

15- ចិត្តក្នុងទីនេះមានន័យត្រូវគ្នានឹងចិត្តតាមភាសាខ្មែរសាមញ្ញ ។ អ្នកចំរើនកម្មដ្ឋានពិសោធឃើញស្ថានភាពផ្សេងៗរបស់ចិត្ត ហើយពិនិត្យមើលស្ថានភាពទាំងនេះដោយឥតលំអៀងនិងដោយគ្មានការជាប់ចិត្ត ។ ការបកប្រែពាក្យ ចិត្ត ថា គំនិតក្នុងទីនេះអាចនាំឱ្យមានការភាន់ច្រឡំ ។

ចិត្តេ ចិត្តានុបស្សី ( ចិត្តក្នុងចិត្ត ) គឺសំដៅទៅលើធម្មជាតិដែលពិសោធឃើញនៃការពិនិត្យមើលស្របតាមរបៀបដែលគេបង្គាប់ឱ្យពិនិត្យ ( សូមមើលកំណត់លេខ៩ ) ។

16- សង្ខិត្តំ គឺចិត្តរួមតូចនិង វិក្ខិត្តំ ចិត្តរាយមាយត្រូវគ្នានឹងស្ថានភាពរបស់ចិត្តដែលរាយមាយបណ្តាលមកពីនីវរណធម៌ទាំងឡាយក៏ដូចនឹងកាលណាគ្មាននីវរណធម៌ ។ សូមមើលផ្នែក៥.កស្តីអំពីនីវរណធម៌ ។

17- មហគ្គតំ ចិត្តំ គឺ ចិត្តរីកចំរើន ។ពាក្យន័យដើមគឺចិត្តដែលប្រែទៅជាធំ ។ ជាឧទាហរណ៍គឺដោយសារការប្រតិបត្តិនិងការរីកចំរើនខាងឈាន ។ គេសំដៅយកចិត្តដែលរីកចំរើនឡើងដោយសារការប្រតិបត្តិយ៉ាងត្រឹមត្រូវមិនមែនបានសំរេចថ្នាក់យ៉ាងខ្ពស់បំផុតក្នុងវិស័យចិត្តនិងកាយទេ ។ ដូច្នេះ អមហគ្គតំ ចិត្តំ៖ ចិត្តមិនរីកចំរើនមានន័យថា ចិត្តដែលមិនបានរីកចំរើនតាមរបៀបនេះ ។

18- សឧត្តរំ : ដែលអាចមានអ្វីផ្សេងប្រសើរជាង មានន័យថា ដែលមានរបស់អ្វីផ្សេងប្រសើរជាងនេះឬដែលមិនខ្ពង់ខ្ពស់ជាងគេ ។ ចិត្តបែបនេះគឺស្ថិតនៅក្នុងលោកនៅឡើយ ។ ដោយយោងទៅតាមលំនាំដូចគ្នា អនុត្តរំ : ដែលគ្មានអ្វីប្រសើរជាងគឺជាចិត្តដែលបានទៅដល់ថ្នាក់យ៉ាងខ្ពស់នៃសមាធិដែលគ្មានអ្វីខ្ពង់ខ្ពស់ជាង ។ ហេតុដូច្នេះ ការបកប្រែថា ដែលមានអ្វីផ្សេងប្រសើរជាង និង ដែលគ្មានអ្វីផ្សេងប្រសើរជាង ជាការបកប្រែដែលមានន័យជិតជាងគេទោះបីមិនសូវជាចំខ្លឹមក៏ដោយ ។

19- សមាហិតំ : ដែលតាំងនៅមាំ និង អសមាហិតំ : ដែលមិនតាំងនៅមាំ មានការទាក់ទងទៅនឹងប្រភេទសមាធិការធ្វើចិត្តឱ្យមូលដែលគេបានសំរេច : គឺថ្នាក់នៃឧបចារសមាធិដែលជិតទៅដល់ដំណើរតាំងមាំនៃចិត្ត និង អប្ប.នាសមាធិ ការទៅដល់ដំណើរតាំងមាំនៃចិត្ត ឬឈាន ។ ដូច្នេះ អសមាហិតំ ចិត្តំ គឺស្ថានភាពរបស់ចិត្តដែលមិនទាន់បានទៅដល់ថ្នាក់សមាធិយ៉ាងជ្រៅបែបនេះ ។

20- ឥតិ អជ្ឈត្តំ ...ពហិទ្ធា ...អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ ។ តាមរបៀបនេះ ភិក្ខុតាំងនៅពិនិត្យមើលចិត្តក្នុងចិត្តនៅខាងក្នុងនៅខាងក្រៅ..នៅខាងក្នុងផង នៅខាងក្រៅផង ។ និយាយអំពីចិត្ត ( ហើយផ្នែកជាបន្ទាប់ និយាយអំពីធម៌ ) ប្រការនេះដូចការនាំឱ្យយល់ថាអ្នកចំរើនកម្មដ្ឋានពិនិត្យមើលចិត្តខ្លួនឯងផ្ទាល់ ( នៅខាងក្នុង ) និងចិត្តរបស់អ្នកដទៃ ( នៅខាងក្រៅ ) ។ ក្នុងរឿងនេះ មានតែអ្នកចំរើនកម្មដ្ឋានដែលបានរីកចំរើនដល់ថ្នាក់យ៉ាងខ្ពស់ទេដែលអាចធ្វើបាន ។ ដូច្នេះ វាមិនមែនជាបទបញ្ជាដែលមនុស្សភាគច្រើន អាចអនុវត្តបានទេ ។

ក្នុងផ្នែកនេះ គេបង្គាប់ឱ្យអ្នកចំរើនកម្មដ្ឋានពិសោធឃើញចិត្តនៅក្នុងចិត្តដោយផ្ទាល់ខ្លួន : ចិត្តេ ចិត្តានុបស្សី ។ គេអាចធ្វើយ៉ាងនេះកើតតែដោយសារការពិនិត្យមើលនូវអ្វីៗដែលកើតឡើងនៅក្នុងចិត្ត។ ដូចជាគេអាចពិសោធឃើញកាយតាមរយៈអ្វីៗដែលកើតឡើងនៅលើកាយ ( ដូចជាវេទនា ). យ៉ាងណាមិញ គេក៏អាចពិសោធឃើញចិត្តបានតែតាមរយៈអ្វីមួយដែលកើតឡើងនៅក្នុងចិត្ត ( ដូចជាធម៌ទាំងឡាយ) ក៏ដូចនោះដែរ ។ កាលណាចិត្តពិនិត្យមើលរបស់នៅខាងក្នុង គឺសភាពផ្ទាល់របស់ចិត្តនៅខាងក្នុងចិត្ត គឺជាការពិនិត្យមើល

អត្ថាធិប្បាយពាក្យពោល

ចិត្តក្នុងចិត្តខាងក្នុង ។

ពិនិត្យមើលចិត្តនិងធម៌ខាងក្នុងខាងក្រៅមានន័យថា ពិនិត្យមើលតាមការពិសោធន៍នូវរបស់អ្វីមួយដែលមកប៉ះនឹងអាយតនៈតាមទ្វារវិញ្ញាណណាមួយក្នុងចំណោមទ្វារវិញ្ញាណទាំង៦ នេះគឺជាថ្នាំងរបស់មួយខាងក្រៅ បណ្តាលឱ្យមានប្រតិកម្មខាងក្នុង ។ រូប.សំឡេង.ក្លិន.រស.ជាដើមទូទៅគឺណាមួយបណ្តាលឱ្យមានវេទនាមួយ ហើយចិត្តពិសោធឃើញវេទនានោះ ។ ជាការពិតហើយសភាពរបស់ចិត្តខាងក្នុងនិងវេទនាដែលកើតមកពីការប៉ះជាមួយរបស់ខាងក្រៅនឹងលាយឡំជាមួយគ្នា ហើយមានដំណើរទៅជាមួយគ្នា ។

ហេតុដូច្នេះជាថ្មីទៀត យើងសង្កេតឃើញយ៉ាងច្បាស់នូវសារៈសំខាន់នៃពាក្យបញ្ញារបស់ព្រះពុទ្ធ :

## វេទនា សមោសរណា សព្វេ ធម្មា

អ្វីៗដែលកើតឡើងនៅក្នុងចិត្តមានដំណើរទៅជាមួយវេទនា ។

(អង្គុត្តរនិកាយ VRI III ទសកនិបាត 58 - PTS V. 107)

ទោះបីជារបស់ខាងក្នុងក្តី ខាងក្រៅក្តី បើចិត្តស្ថិតនៅក្នុងការពិនិត្យមើលវេទនានេះ គឺពិសោធឃើញចិត្តនិងធម៌ដោយផ្ទាល់តាមរបៀបជាក់ស្តែងមួយដែលនាំឱ្យអ្នកចំរើនកម្មដ្ឋានពិសោធឃើញធម្មជាតិមិនទៀងនៃបាតុភូតកាយរូបទាំងមូលបានដោយងាយ ។

21- កាមច្ឆន្ទ: សេចក្តីត្រេកអរក្នុងកាមគឺការសប្បាយការស្ញើចិត្តនិងកាមគុណ, គំនិតវិលវល់នៅក្នុងការសប្បាយនេះ ។

22- ព្យាបាទ : សេចក្តីព្យាបាទ ការស្អប់ខ្ពើមគឺសំដៅយកការស្អប់ខ្ពើមទៅប្រកបដោយការតានតឹងនៅក្នុងកាយនិងនៅក្នុងចិត្ត ។ រីឯទោសៈវិញ សូមមាននៅក្រោមផ្នែក ចិត្តានុបស្សនា គឺសំដៅយកចិត្តអាក្រក់ ឬ ការស្អប់ ។

23- ថីន : ភាពព្រួយស្រពោនមានលក្ខណៈជាការងោកងុយ រីឯ មិទ្ធ : ភាពមិនរវល់រវៃមានលក្ខណៈជាភាពខ្ជិលច្រអូសខាងផ្លូវចិត្តដែលរាំងមិនឱ្យមានកម្លាំងជាចាំបាច់សំរាប់គំទាត់ភាពច្រអូសបាន ។

24- វិចិកិច្ឆា : ការសង្ស័យ មានន័យថា ការសង្ស័យគ្រប់បែបយ៉ាង : សង្ស័យពីសមត្ថភាពខ្លួនឯង, ពីការប្តេជ្ញាចិត្តរបស់ខ្លួនឯង ។ វិចិកិច្ឆាអាចក្លាយទៅជាការសង្ស័យអំពីមាគ៌ា អំពីគ្រូសិក្សាពៃនមាគ៌ាឬអំពីព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

25- បញ្ច ឧបាទានក្ខន្ធា : ការប្រកាន់ជាប់ទៅលើខន្ធមានរូបក្ខន្ធគឺខន្ធរបស់រូបដែលទាក់ទងជាមួយកាយនិងនាមខន្ធគឺខន្ធរបស់ចិត្តដែលមាន វិញ្ញាណក្ខន្ធ : ការដឹង,សញ្ញាខន្ធ : ការស្គាល់ ការចាំបាន, វេទនាខន្ធ : ការសោយអារម្មណ៍នៅលើកាយ,សង្ខារក្ខន្ធ : ការធ្វើប្រតិកម្ម ។ បញ្ចឧបាទានក្ខន្ធ ជាខន្ធដែលកាន់ជាប់ ឬ ប្រកាន់ខ្ជាប់តាមរបៀប២យ៉ាង : គឺរបស់ជាមូលដ្ឋានដែលយើងប្រកាន់ជាប់ដោយមកពីយើងយល់ច្រឡំថា ខន្ធទាំង៥នេះរួមគ្នាកើតបានជា «អញ» ជា «ខ្លួនអញ» ។ ម៉្យាងទៀតការកើតមិនឈប់របស់ខន្ធដោយមានតណ្ហាមកជាមួយផងនៅក្នុងវដ្តសង្សារ គឺបណ្តាលមកអំពីការប្រកាន់ជាប់ទៅលើការភ័ន្តច្រឡំអំពី «អញ» នេះ ។ ខន្ធនិងការប្រកាន់ខ្ជាប់តែងតែប្រព្រឹត្តទៅជាមួយគ្នាជានិច្ច លើកលែងតែព្រះអរហន្តដែលមានខន្ធ៥តែគ្មានការប្រកាន់ខ្ជាប់ទៅលើខន្ធទាំងនេះ ។ មានតែព្រះអរហន្តទេ ដែលគ្មានឧបាទានគឺការប្រកាន់ខ្ជាប់ ។

26- ក្នុងទីនេះ ពាក្យធម៌ ត្រូវយល់ថាជាច្បាប់របស់ធម្មជាតិ ជាធម្មជាតិរបស់ច្បាប់ទាំងស្រុង ។ នៅផ្នាក់ស៊ីៗខាងលើនេះអាចយល់បានថា ធម្មវិចយ ជាការពិនិត្យពិច័យធម៌ការបង្រៀនក្នុងព្រះត្រៃបិដក ។ ប៉ុន្តែដើម្បីឱ្យបានទៅយល់អត្ថន័យនៃការក្រៅសឹង ធម្មវិចយ ត្រូវតែជាការពិនិត្យពិច័យតាមការពិសោធន៍ ការពិសោធន៍ផ្ទាល់ចំពោះបាតុភូតនៃការកើតនិងការរលត់បាត់ទៅវិញតាមរយៈវេទនា ។

27- បីតិ : សេចក្តីត្រេកអរខ្លាំង ពិបាកបកប្រែណាស់ ។ ជាភាសាអង់គ្លេស គេប្រើពាក្យបកប្រែពាក្យនេះ ថា JOY : សេចក្តីសប្បាយ ថា RAPTURE : សេចក្តីសប្បាយខ្លាំង ថា BLISS : សេចក្តីអណ្តែតអណ្តូង ឬថា THRILL : សេចក្តីរំភើបចិត្ត ។ ពាក្យនិមួយៗខាងលើនេះយ៉ាងហោចណាស់ក៏បញ្ជាក់ឲ្យឃើញការសប្បាយមួយផ្នែកខាងផ្លូវកាយនិងផ្លូវចិត្ត ។ ដើម្បីឲ្យបីតិប្រែទៅជាអង្គមួយនៃការត្រាស់ដឹង បីតិនេះត្រូវតែពិសោធឃើញតាមភាពពិតរបស់វា ជាធាតុរបស់ចិត្តដ៏ល្អិតស្មុគ្រស្មាញដែលកើតឡើងហើយរលត់ទៅវិញ ។ និងរាល់ពេលយ៉ាងនេះ ទើបអ្នកចំរើនកម្មដ្ឋានអាចជៀសវាងគ្រោះថ្នាក់បណ្តាលមកពីការប្រកាន់ខ្ជាប់ទៅលើសេចក្តីត្រេកអរខ្លាំងនៅចំណោតនេះបាន ។

28- ដូចជាអង្គនៃការត្រាស់ដឹងមុនៗដែរ បស្សទ្ធិ : សេចក្តីស្ងប់នឹងប្រែទៅជាអង្គនៃការត្រាស់ដឹងបាន លុះត្រាតែគេពិសោធឃើញ បស្សទ្ធិ នេះជាធាតុសភាវៈមិនទៀង ជាធាតុអនិច្ចំ កើតឡើងហើយរលត់ទៅវិញ ។ ចំពោះអ្នកចំរើនកម្មដ្ឋាន គ្រោះថ្នាក់នៃសេចក្តីស្ងប់យ៉ាងជ្រៅនៅចំណោតនេះគឺការយល់ច្រឡំដោយស្មានថាជាគោលដៅចុងក្រោយគឺព្រះនិព្វាន ។ ការយល់ច្រឡំពីមោហៈនេះអាចជៀសវាងបានតាមការពិសោធន៍សេចក្តីមិនទៀងនៅពេលដែលគេពិសោធឃើញសេចក្តីស្ងប់យ៉ាងជ្រៅនេះ ។

29- ក្នុងអត្ថបទដើម ពាក្យព្យាធិ : ជម្ងឺធ្ងន់នេះ ដូចការដែលមានទុក្ខ,ដូចការដែលគ្មានទុក្ខក្នុងអត្ថបទនេះ ។

30- នៅត្រង់នេះគេឃើញច្បាស់ថា ពាក្យ ទុក្ខ : ការឈឺចុកចាប់នេះទាក់ទងតែជាមួយកាយ ។ រីឯ ទោមនស្ស : ការអាក់អន់ចិត្ត ទាក់ទងតែជាមួយចិត្តប៉ុណ្ណោះ ។ ដូចគ្នានេះដែរ សុខ : សេចក្តីសប្បាយការផ្លូវកាយ ទាក់ទងជាមួយកាយ រីឯសោមនស្ស : សេចក្តីសប្បាយការផ្លូវចិត្ត ទាក់ទងតែជាមួយចិត្ត ។ ហើយ អទុក្ខមសុខ : មិនមែនទុក្ខមិនមែនសុខ គឺ អព្យាក្រឹតទាក់ទងទាំងពីរផ្លូវ គឺកាយផង ចិត្តផង ។

31- ពាក្យ លោក : លោក មានន័យយ៉ាងទូលំទូលាយណាស់ : សកលលោក,លោក,ជំពូក,មនុស្ស ។ ក្នុងផ្នែកនេះទាំងមូល គេប្រើពាក្យ លោក សំរាប់អ្វីៗទាំងអស់ដែលគេពិសោធឃើញនៅត្រង់ទ្វារទាំង៦ និងការប៉ះរវាងគ្រឿងវិញ្ញាណនិងអារម្មណ៍របស់វា ។ ដូច្នេះ នៅក្នុងអត្ថបទនេះ ពាក្យ លោក ត្រូវយល់ថាជាពាក្យក្លាយរូប ។ ហេតុដូច្នេះ គេពិសោធឃើញលោកទាំងមូលតាមរយៈវេទនានៅលើកាយដែលបណ្តាលមកពី អត្តភាព និងផ្លូវកាយខាងក្រៅមកវិញទៅមកនៅក្នុងលោកនេះ ។

32- វិញ្ញាណ : ការដឹង ក្នុងទីនេះ តាមគ្រប់តែកាយទ្វាររបស់វា ។ ដោយហេតុនេះយើងឃើញថា មានវិញ្ញាណ៦ផ្សេងគ្នា មិនមែនមានតែមួយទេ ។

32a- ចិត្តដែលធ្វើប្រតិកម្មចំពោះអារម្មណ៍ (reaction) មានន័យថាចិត្តត្រាច់ចរពីតម្រេះមួយទៅចិត្តដទៃ ឬចិត្តដែលចុះស៊ប់ជាប់ស្អិតក្នុង អារម្មណ៍, ...

33- វិក្ខេប : សេចក្តីដែលរ៉ោះរ៉ៅទៅលើការប៉ះពាល់មួយរវាងចិត្ត និងរបស់អ្វីមួយ ។ គឺអ័ព្ទាក វិក្ខេប : ការវិលវល់ក្នុងគំនិតឬចិត្តណាដែលសំដៅយកការជាប់ជំពាក់ទៅលើរបស់អ្វីមួយ ។

34- ធម៌ : កាលបើប្រៀបនេះ ដូចមានការស្រួលនៅក្នុងសូត្រនេះទាំងមូលគឺអាតាបី សម្បជានោ សតិមា : ដោយឆ្លាប់ខ្លួនប្រកបដោយសតិដឹងត្រូវចំពោះវេទនានិងការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀង ។ ដើម្បីឲ្យបានសំរេចផលអរហត្តនៅទាំងឡាយនេះ,ភាពបន្តជាប់ជានិច្ចត្រូវតែ «សម្បជញ្ញំ ន រិញ្ចតិ» អ្នកចំរើនកម្មដ្ឋានមិនត្រូវបាត់ការយល់ច្បាស់ជាប់ជានិច្ចអំពីសេចក្តីមិនទៀងសូម្បីតែមួយរយៈពេលក៏ដោយអព្ភិមានឡើយ ។

35- ថ្នាក់ចុងបំផុតនៃការរួចរំដោះរបស់ព្រះអរហត្តគឺព្រះនិព្វាន ។

36- ថ្នាក់អនាគាមីគឺមិនត្រឡប់មកវិញ ជាថ្នាក់ទីបួនគឺងទៅដល់ថ្នាក់ចុងបំផុតនៃការរួចរំដោះ ។ សោតា==> សកិទា ==> អនាគា ==> អរហត្ត (ថ្នាក់នៃការរួចរំដោះពេញបរិបូណ៌) ។ ឈ្មោះប្រភេទពី : សោតាបត្តិមគ្គ,សោតាបត្តិផល ==> សកិទាគាមិមគ្គ,សកិទាគាមិផល ==> អនាគាមិមគ្គ,អនាគាមិផល ==> អរហត្តមគ្គ,អរហត្តផល ។ ឈ្មោះបុគ្គល : សោតាបន្ន ==> សកិទាគាមី ==> អនាគាមី ==> អរហត្ត

អាសយដ្ឋាននៃ៤៤មជ្ឈមណ្ឌលវិបស្សនាក្នុងពិភពលោក (ធ្នូ១៩៩៧)

*World-Wide list of*

*44 VIPASSANA MEDITATION CENTERS (December 1997 )*

## Australia

**New South Wales :**
*Vipassana Meditation Centre ; **Dhamma Bhumi** ; P.O Box 103;*
*Blackheath, NSW 2785,*
*Tel.[61](02)4787-7436,4787-8431;Fax: [61](02)4787-7221*
*E-Mail : vmcbh@ozemail.com.au*

**Queensland :**
*Vipassana Centre Queensland ; **Dhamma Rasmi** ; P.O Box 119;*
*Rules Rd.;Pomona,QLD 4568*
*Tel.[61](07)5485-2452;Fax : [61](07)5485-2907*

**Tasmaina :**
*Vipassana Meditation Tasmaina ; **Dhamma Pabha** ; G.P.O Box 6;*
*Hobart,Tasmaina 7001.*
*Tel.[61](03)3228-6535;6231-1374*

**Victoria :**
*Vipassana Charitable Trust ; **Dhamma Aloka** ; P.O Box 11;*
*Woori Yallock,VIC 3139*
*Tel.[61](03)5961-5722;Fax: [61](03)5961-5765*
*E-Mail : vmcwy@softcentre.com.au*

## Cambodia

*Cambodia Vipassana Centre ; **Dhamma Kamboja** ;*
*next to Kompng Ko Budhist Temple,Dist. Koh Thom;Kandal Province,or Building13,Wat Unalom, Phone [855]023 210 850 or [855]012 842 534*
*Email : IVCC@FORUM.ORG.KH*

*ភូមិលេខ១៣ វត្តឧណ្ណាលោម, ទូរស័ព្ទលេខ : [855]023 210 850 ឬ [855]012 842 534*
*ទូរសារលេខ [855]023 210 850*

*Cambodia (Battambang)*
*Contact Mr.SOU Ear,86 Group 38, Phoum 20 May, Khum Svay Por. Battambang Ville.*
*Phone: [855](159)15132*

## France

*European Vipassana Centre/Centre Vipassana Européen, **Dhamma Mahi**,*
*«Le Bois Planté»,89350 Louesme,Champignelles, FRANCE*
*Tél.[33](03)86.45.75.14,Fax. [33](03)86.45.76.20*

## India

**Maharashtra :**
*Vipassana International Academy ; **Dhamma Giri** ; P.O Box 6;*
*Igatpuri 422 403; Dist. Nasik, Maharashtra.*
*Tel.[91] (2553) 84076, 84086 ou 84038; Fax. [91] (2553) 84176.*

*Deccan Vipassana Research Centre ; **Dhammalaya** ; near Majale bus stand*

Hatakanagale 416 109; Maharastra; India.
Tel. [91] (232) 483-316; Fax. [91] (0231) 658-519.

Nagpur Vipassana Centre ; **Dhamma Naga** ; Village Mahurjhari, near Nagpur-Kalmeshwar R.d. Nagpur 440 012 ; Maharashtra; India.
Tel. [91] (712) 522-169 ; Fax. 539-716.

Khandesh Vipassana Centre ; **Dhamma Sarovara** ; c/o Sri Prakash Borse ; Tulsiram Nagar Deopur, Dhule 424 002 ; Maharashtra ; India.Tel. [91] (0256) 222-741, 222-085.

## Gujarat :

Kutch Vipassana Centre ; **Dhamma Sindhu** ; Gram Bada ; Dist.
Mandvi, Kutch 370 475; Gujarat. Tel. [91] (28) 347-3303 ou 347-3304. Ou c/o Mukul Savla, Bhuj. Tel. [91] (2832) 50181.

Ahmedabad Vipassana Centre ; **Dhamma Sindhu** ; c/o Sri S.S. Choudhary ; 1 Patel Society; Opposite Office Of Police Commissioner; Ahmedabad 380 004 ; Gujarat; India.Tel. [91] (079) 334-631.

Rajkot Vipassana Centre ; **Dhamma Kota** ; c/o Rajesh Mehta ;
Bhabah Guest House; Panchnath Road; Rajkot; Gujarat 360 001 ; India.Tel. [91] (0281) 34789 / 32187.

## Nothern India :

Vipassana Centre ; **Dhamma Thali** ; Sisodia Baug-Galtaji Rd; P.O Box 208; Jaipur 302 001; Rajasthan. Tel. [91] (141) 49520.

Delhi Vipassana Centre ; **Dhamma Sota** ; Vipassana Sadhana Sansthan ; Hemkunt Towers 16th Floor ; 98 Nehru Place ;
New Delhi 110 019. India.Tel. [91] (011) 641-7071 ; 641-7072.
Dehradun Vipassana Centre ; **Dhamma Salila** ; c/o Sri T.S Bhandari; 16, Tagore Villa;Chakrata Road ; Dehradun 248 001 ; Uttar Pradesh;
India.Tel. [91] (135) 854-189 ; Fax. [91] (135) 655-580.

Dharamsala Vipassana Centre ; **Dhamma Sikhara** ; MacLeod Ganj;
Dharamsala 176 219 ; Dist. Kangra ; Himachal Pradesh ; India.
Tel. [91] (1892) 21309 ; Fax [91] (1892) 21578.

Sarnath Vipassana Centre ; **Dhamma Cakkaa** ; c/o Mr Parmanand Maheshwari; «Mangalam» C27/273 Indian Press Colony ; Madhala ;
Varanasi ; Uttar Pradesh 221 002 ; India.Tel. [91] (0542) 46644 /344712

Shravasti Vipassana Centre ; **Dhamma Suvatthi** ; c/o Ms. Tilaka Munsinghe ;
Mahabodhi Society Of India ; Shravasti ; Uttar Pradesh 271 213 ; India.

Kushinigar Vipassana Centre ; **Dhamma Vimutti** ; c/o Dr. V.D Modi ; Arogya Mandir ; Gorakhpur ; Uttar Pradesh 273 003 ; India.
Tel. [91] (0551) 335 805 / 336 469.

### Central India :

Balaghat Vipassana Centre ; **Dhamma Kanana** ; c/o Sri Haridas Meshram ; G-8, Bagh Colony; Civil Line Balaghat ; Madya Pradesh ; india. Tel. 2554 ; 2473.

Bhilai-Durg Vipassana Centre ; **Dhamma Kanana** ; c/o Mr S.L. Kathane ; B-269, Gali, No.5 Smrutinagar; District Durg ; Durg ; Madhya Pradesh 400 020 ; India. Tel. [91] (0788) 321 539.

*[illegible]*

Bophal Vipassana Centre ; **Dhamma Pala** ; c/o Mr.Ashok Kela; e-1/82 Arera Colony; Bophal ; Madhya Pradesh ; India.
Tel. [91] (0755) 563 113 ; Fax. [91] (0755) 564 520.

## Eastern India :

Vipassana Centre ; **Dhamma Ganga** ; Bara Mandir Ghat ; Harishchandra Dutta Rd.Panihati (Sodepur)Dist.24 Parganas ;West Bengal 743 176.Tel. [91] (33) 533-2855.
Ou City Office c/o D. Kajaria. Tel. [91] (33) 242-1767 , 242-8043.
Ou c/o M.K Badani Tel. [91] (33) 225-4719 , 475-8342, 475-7208 ;
Fax. [91] (033) 275-174.

Muzaffarpur Vipassana Centre ; **Dhamma Licchavi** ; c/o Dr. I.C Sinha ; khabadha Road. Muzaffarpur 842 001 ; India.
Tel & Fax. [91] (0281) 34789 / 32187.

Bodh Gaya Vipassana Centre ; **Dhamma Bodhi** ; c/o D.P Manraw ; Bodhi Gaya.International Meditation Centre ; Shanti-Dham ; Kankarbagh Road ; Patna ;Bihar 800 020 ; India.Tel & Fax . [91] (0612) 352 874.

## Southern India :

Vipassana International Meditation Centre ; **Dhamma Khetta** ; 12.6 Km Nagarjun Sagar Road;Kusum Nagar; Vanashthali Puram ; Hyderabad 500 070 , Andhra Pradesh.
Tel. [91] (40) 402-0290 ou [91] (40) 402-1746.
Ou City Office Tel. [91] (40) 473-2569 ; Fax. 241-005 ou [91] (40) 2?2-802 ; 318-780.

Mandras Vipassana Centre ; **Dhamma Setu** ; c/o The Mahabodhi Society ; Kenneth Lane; Madras 600 008 ; Tamil Nadu ; India.Tel. [91] (44) 825-2458.

Bangalore Vipassana Centre ; **Dhamma Sumara** ; c/o C.M Goenka ; 685 A 15th Cross. 2nd Phase J.P Nagar ; Bangalore ; Karnataka 560 078 ; India.
Tel. [91] (080) 663-6861 ; Fax. [91] (080) 221-5776.

# Nepal

## Kathmandu :

Nepal Vipassana Centre ; **Dharmashriga** ; Budhanilkantha ; Muhan Pokhari ; Kathmandu Nepal. Tel. [977] (1) 290-655 , 290-669.
Or P.O Box 12896 , Kathmandu. Tel. [977] (1) 371-655 , 371-007.
Ou City Office : Jyoti Bhavan ; Kantipath ; P.O Box 133 ; Kathmandu ; Nepal. Tel. [977] (1) 225-490, 248-949, 250-581, 233-968; Fax.[977] (1) 224-720, 226-314.

**Lumbini :**
**Dhamma Janini** ; Lumbini
City Office ; Jyoti Bhavan ; Kantipath ,P.O Box 133 , Kathmandu, Nepal. Tel. [977] (1) 225-490 ; Fax. [977] (1) 223-067.
**Birganj :**
Dhamma Terai ; Contact : S.Kumar Fancy Store ; Adarsh Nagar ; Birganj ; Nepal.Tel. [977] (1) 22894.

# New Zealand

Vipassana Meditation Centre ; Dhamma Medini ; Burnside Road ; RD3 ; Kaukapakapa. New Zealand. Tel. [64] (09) 420-5319

# Sri Lanka

Vipassana Centre : Dhamma Kuta : Mowbray Galaha Rd.; Hindagala; Peradeniya ; Sri Lanka Tel. [94] (08) 34649.

# Taiwan

Taiwan Vipassana Centre ; Dhammo Daya ; P.O Box 45 ; Yang Mae, Tao Yuan, Republic of China. Tel. [886] (2) 705-9432 ; Fax. [886] (3) 705-9433,
Ou Dr. Lin Chung-An Tel. [886] (3) 422-7151 , extension 5766 ;
Fax. [886] (3) 425-8073 E-Mail: wcliou@cc.nccu.edu.tw

# Japan

Japan Vipassana Centre, **Dhamma Bhanu,**92 Ginkakuji-cho, Sakyo-ku, Kyoto 606;
Tél& Fax : [81](075)752-3685; E-Mail : jvipa@mbox.kyoto-inet.or.jp

# Birman

Vipassana Centre, **Dhamma Joti**,Nga Htat Gyi Pagoda Rd;Bahan Township;Yangon, Mayanmar.Phone: [95](1)39290.

**MOGOK :**
Vipassana Centre, **Dhamma Ratana**.c/o Vipassana Centre Dhamma Joti
Nga Htat Gyi Pagoda Rd; Bahan Township;Yangon,Mayanmar.Phone: [95](1)39290.

# Thailand

Thailand Vipassana Centre, **Dhamma Kamala**
Contact Mrs.Pornphen Leenutaphong;929 Rama 1 Road; Patumwan, Bangkok
Phone: [66](2)216-4772 Fax [66](2)215-3408

# United Kingdom

Vipassana Centre, **Dhamma Dipa,**Harewoo End; Hereford HR2-8JS.
Phone: [44](1989)730-234; Fax [44](1989)730-450.
E-Mail : dhammadipa@compuserve.com

# United States

## California :

California Vipassana Centre, **Dhamma Mohavana,**P.O Box1167;North Fork,CA93643
Phone: [1](209)877-4386; Fax [1](209)877-4387
E-Mail : mahavana@aol.com

## Massachusetts :

Vipassana Centre, **Dhamma Dhara,**P.O Box24;Shelburne Falls,MA 01370
Phone: [1](413)625-2160; Fax [1](413)625-2170
E-Mail : vmcdharaa@aol.com

**Texas :**

Soutwest Vipassana Centre, **Dhamma Siri,** 10850 County Rd.155A;Kaufman,TX 75142
Phone: [1](972)932-7868; E-Mail : dhsiri@aol.com, contact center during courses, or contact :
Southwest Vipassana Association;POBox 190248;Dallas, TX75219
Phone: [1](214)521-5258; E-Mail : vip@onramp.net

**Washington :**

Northwest Vipassana Centre, **Dhamma Kunja,** POBox 345;Ethel,WA 98542.
Phone: [1](360)978-5434; Fax: [1](360)978-5433
E-Mail : dhkunja@aol.com

[illegible]

[illegible]

មហាសតិប្បដ្ឋានសូត្រ [illegible] 'Mahā Satipaṭṭhāna Sutta

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]


ឧបត្ថម្ភនិងបោះពុម្ពផ្សាយ

ដោយ

ក្រុមសិស្សវិបស្សនាវត្តសុរិយរង្សី

5415 Rising Sun Ave. Philadelphia , PA 19120

U.S.A

ផ្សាយចេញពី ស.ខ.គ.វ. សមាគមខ្មែរគាំទ្រវិបស្សនា នៅប្រទេសបារាំង
ខែមករា ឆ្នាំខាលសំរឹទ្ធិស័ក ព.ស. ២៥៤២ ត្រូវនឹងខែមករា គ.ស. ១៩៩៩
Published in January 1999 by AKSV
6, Chemin de la Moinerie, 17120, SAINTS (France)